# ផែនការសកម្មភាពរបស់
# សហព័ន្ធនិយោជក និងសមាគមពាណិជ្ជកម្មកម្ពុជា
# ស្តីពី
# ការលុបបំបាត់ពលកម្មកុមារ (ក្នុងទម្រង់ធ្ងន់ធ្ងរបំផុត)
# នៅក្នុងប្រទេសកម្ពុជា
# (២០១២-២០១៦)
# (CAMFEBA - PAECL)

ខែ សីហា ឆ្នាំ២០១២

ឯកសារនេះត្រូវបានបោះពុម្ពផ្សាយក្រោមការគាំទ្រផ្នែកហិរញ្ញវត្ថុពី
កម្មវិធីអន្តរជាតិស្តីអំពីការលុបបំបាត់ពលកម្មកុមាររបស់អង្គការពលកម្មអន្តរជាតិ ILO IPEC
តាមរយៈគម្រោងលេខ CMB/08/50P/USA, P.270.16.316.052

# ផែនការសកម្មភាពរបស់
# សហព័ន្ធនិយោជក និងសមាគមពាណិជ្ជកម្មកម្ពុជា
# ស្តីពី
# ការលុបបំបាត់ពលកម្មកុមារ (ក្នុងទម្រង់ធ្ងន់ធ្ងរបំផុត)
# នៅក្នុងប្រទេសកម្ពុជា
# (២០១២-២០១៦)

## (CAMFEBA - PAECL)

**ខែសីហា ឆ្នាំ២០១២**

# ពាក្យអក្សរកាត់

| | | |
|---|---|---|
| ASEAN | = | សមាគមប្រជាជាតិអាស៊ីអាគ្នេយ៍ |
| ADB | = | ធនាគារអភិវឌ្ឍន៍អាស៊ី |
| CMDG | = | គោលដៅអភិវឌ្ឍន៍សហស្សវត្សកម្ពុជា |
| CAMFEBA | = | សហព័ន្ធនិយោជក និងសមាគមពាណិជ្ជកម្មកម្ពុជា |
| CAPE | = | សម្ព័ន្ធនិយោជកអាស៊ីប៉ាស៊ីហ្វិក |
| CCLS | = | ការអង្កេតពលកម្មកុមារនៅកម្ពុជា |
| CL | = | ពលកម្មកុមារ |
| CLM | = | ការឃ្លាំមើលពលកម្មកុមារ |
| CC | = | សភាពាណិជ្ជកម្ម |
| CLE | = | ការលុបបំបាត់ពលកម្មកុមារ |
| CNCC | = | ក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ |
| CSES | = | ការអង្កេតសេដ្ឋកិច្ច-សង្គមកិច្ចកម្ពុជា |
| CSO | = | អង្គការសង្គមស៊ីវិល |
| CRS | = | ទំនួលខុសត្រូវចំពោះសង្គម |
| CSNACL | = | បណ្តាញសង្គមស៊ីវិលប្រឆាំងនឹងពលកម្មកុមារ |
| DoCL | = | នាយកដ្ឋានពលកម្មកុមារ |
| ILO-IPEC | = | អង្គការពលកម្មអន្តរជាតិ/កម្មវិធីអន្តរជាតិស្តីពីការលុបបំបាត់ពលកម្មកុមារ |
| IoE | = | សមាគមនិយោជកអន្តរជាតិ |
| ACE | = | សហព័ន្ធនិយោជកអាស៊ាន |
| INGO | = | អង្គការក្រៅរដ្ឋាភិបាលអន្តរជាតិ |
| IMF | = | មូលនិធិរូបិយវត្ថុអន្តរជាតិ |
| LNGO | = | អង្គការក្រៅរដ្ឋាភិបាលក្នុងស្រុក |
| MLVT | = | ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ |
| NPA | = | ផែនការសកម្មភាពជាតិ |
| NPA-WFCL | = | ផែនការសកម្មភាពជាតិស្តីពីការលុបបំបាត់ទម្រង់ធ្ងន់ធ្ងរបំផុតនៃពលកម្មកុមារ |
| NPRS | = | យុទ្ធសាស្ត្រលុបបំបាត់ភាពក្រីក្រ |

| | | |
|---|---|---|
| NPA-STSLS | = | ផែនការសកម្មភាពថ្នាក់ជាតិស្តីពីការបង្ក្រាបអំពើជួញដូរ ការរត់ពន្ធ ការធ្វើអាជីវកម្មពលកម្មលើមនុស្ស និងការធ្វើអាជីវកម្មផ្លូវភេទ |
| NSC-CL | = | អនុគណៈកម្មាធិការថ្នាក់ជាតិ ស្តីពីពលកម្មកុមារ និងទម្រង់ផ្សេងៗ នៃការជួញដូរ កេងប្រវ័ញ្ចផ្លូវភេទមកលើកុមារ |
| PCC | = | ក្រុមប្រឹក្សាខេត្តដើម្បីកុមារ |
| PAECL | = | ផែនការសកម្មភាពស្តីពីការលុបបំបាត់ពលកម្មកុមារ |
| RGC | = | រាជរដ្ឋាភិបាលកម្ពុជា |
| SLOM | = | កិច្ចប្រជុំមន្ត្រីការងារជាន់ខ្ពស់ |
| UCW | = | យល់ដឹងអំពីការងារកុមារ |
| UNCRC | = | អនុសញ្ញាអង្គការសហប្រជាជាតិស្តីពីសិទ្ធិកុមារ |
| UN Agencies | = | ភ្នាក់ងារអង្គការសហប្រជាជាតិ |
| UNICEF | = | អង្គការសហប្រជាជាតិមូលនិធិដើម្បីកុមារ |
| UNESCO | = | អង្គការសហប្រជាជាតិសម្រាប់ការអប់រំ វិទ្យាសាស្ត្រ និងវប្បធម៌ |
| UNDP | = | កម្មវិធីអភិវឌ្ឍន៍សហប្រជាជាតិប្រចាំកម្ពុជា |
| WFCL | = | ទម្រង់ធ្ងន់ធ្ងរបំផុតនៃពលកម្មកុមារ |
| WB | = | ធនាគារពិភពលោក |

# មាតិកា

**ពាក្យអក្សរកាត់**......................................................................................................៣

**១. ប្រវត្តិសង្ខេប**......................................................................................................៧

១.១. សេចក្តីផ្តើម......................................................................................................៧

១.២. និយមន័យនៃពលកម្មកុមារ......................................................................................................១០

១.៣. ការប្តេជ្ញាចិត្តរបស់រាជរដ្ឋាភិបាលកម្ពុជា ក្នុងការលុបបំបាត់ពលកម្មកុមារ និង ទម្រង់ធ្ងន់ធ្ងរបំផុត......................................................................................................១១

១.៣.១. ក្របខ័ណ្ឌគោលនយោបាយ ក្នុងការលុបបំបាត់ពលកម្មកុមារ......................................................................................................១២

១.៣.២. ការប្តេជ្ញាថ្នាក់ជាតិ និងថ្នាក់អន្តរជាតិ ក្នុងការលុបបំបាត់ពលកម្មកុមារ......................................................................................................១៥

១.៤. ការប្តេជ្ញាចិត្តរបស់ CAMFEBA – និយោជក......................................................................................................១៥

១.៥. ការប្តេជ្ញាចិត្តរបស់សហជីព......................................................................................................១៦

១.៦. ការប្តេជ្ញាចិត្តរបស់បណ្តាញសង្គមស៊ីវិលប្រឆាំងនឹងពលកម្មកុមារ (SCNACL)......................................................................................................១៧

១.៧. យន្តការ......................................................................................................១៧

**២. ការវិភាគពលកម្មកុមារ និងទម្រង់ធ្ងន់ធ្ងររបស់វា និង ការឆ្លើយតបនៅ ក្នុងប្រទេសកម្ពុជា**......................................................................................................**១៩**

២.១. ស្ថានភាពពលកម្មកុមារនៅក្នុងប្រទេសកម្ពុជា......................................................................................................១៩

២.២. បរិបទ និងមូលហេតុនៃពលកម្មកុមារ......................................................................................................២១

**៣. បញ្ហាជាអាទិភាពសម្រាប់ដោះស្រាយ**......................................................................................................**២៤**

**៤. ផែនការសកម្មភាពរបស់ CAMFEBA ស្តីពីការលុបបំបាត់ពលកម្មកុមារក្នុង ទម្រង់ធ្ងន់ធ្ងរបំផុតនៅក្នុងប្រទេស កម្ពុជា CAMFEBA - PAECL**......................................................................................................**២៧**

៤.១. ទស្សនវិស័យ បេសកកម្ម និងគោលដៅ......................................................................................................២៧

៤.១.១. ទស្សនវិស័យ......................................................................................................២៧

៤.១.២. បេសកកម្ម......................................................................................................២៧

៤.១.៣. គោលដៅ......................................................................................................២៧

៤.២. គោលបំណង/គោលដៅ......................................................................................................២៧

៤.៣. លទ្ធផលរំពឹងទុកចំបងៗ......................................................................................................២៨

៤.៤. យុទ្ធសាស្ត្ររបស់ CAMFEBA-PAECL (2012-2016)......................................................................................................២៩

៤.៥. លទ្ធផលរំពឹងទុក និងសកម្មភាពសំខាន់ៗ......................................................................................................៣១

**៥. ការអនុវត្តផែនការសកម្មភាពក្នុងការលុបបំបាត់ពលកម្មកុមារនៅក្នុងប្រទេសកម្ពុជា ............ ៣៨**

**៦. ការរាយការណ៍ ត្រួតពិនិត្យ និងការវាយតម្លៃ ............ ៣៨**

៦.១. ការត្រួតពិនិត្យ និងការវាយតម្លៃ ............ ៣៨

៦.២. យន្តការក្នុងការត្រួតពិនិត្យ និងការវាយតម្លៃ ............ ៣៨

**៧. ការសន្និដ្ឋាន ............ ៣៩**

**ឧបសម្ព័ន្ធទី ១ :** តារាងនៃការអនុវត្តផែនការសកម្មភាពរបស់ ក្នុងការលុបបំបាត់ទម្រង់ធ្ងន់ធ្ងរបំផុតនៃពលកម្មកុមារ (CAMFEBA – PAECL) នៅក្នុងប្រទេសកម្ពុជា (២០១២-២០១៦) ............ ៤០

**ឧបសម្ព័ន្ធ ក :** តារាងរចនាសម្ព័ន្ធ CAMFEBA គម្រោងលុបបំបាត់ពលកម្មកុមារ ............ ៦៨

**ឧបសម្ព័ន្ធ ខ :** សេចក្តីសង្ខេបនៃរបាយការណ៍ខាងលើ និងដំណើរការក្នុងការបង្កើតផែនការសកម្មភាពរបស់ CAMFEBA ក្នុងការលុបបំបាត់ពលកម្មកុមារ (PAECL) ............ ៦៩

# ១. ប្រវត្តិសង្ខេប

## ១.១. សេចក្តីផ្តើម

ពលកម្មកុមារ គឺបញ្ហាដ៏ធំមួយ និងដែលកំពុងចោទឡើងនៅពាសពេញពិភពលោក។ អង្គការពលកម្មអន្តរជាតិ (ILO) ប៉ាន់ប្រមាណថាមានកុមារា និងកុមារី[១] ចំនួន ២១៥ លាននាក់ បានធ្លាក់ទៅក្នុងបញ្ហាពលកម្មកុមារ[២]។ ក្នុងចំណោមកុមារទាំងនោះ មានកុមារចំនួន ១១៥ លាននាក់ ដែលស្ថិតនៅក្នុងទម្រង់ធ្ងន់ធ្ងរបំផុតនៃពលកម្មកុមារ[៣]។ ការដកហូតកុមារទាំងនោះចេញពីទម្រង់ធ្ងន់ធ្ងរបំផុត និងផ្តល់ឱ្យពួកគេនូវអនាគតមួយដែលគ្មានពលកម្មកុមារ គឺជាបញ្ហាអាទិភាពបន្ទាន់មួយ។ ភាគច្រើននៃកុមារដែលបម្រើសកម្មភាពសេដ្ឋកិច្ច (៩០%) គឺមកពីប្រទេសកំពុងអភិវឌ្ឍន៍។

ប្រទេសកម្ពុជា ក៏ដូចជាប្រទេសកំពុងអភិវឌ្ឍន៍ផ្សេងៗទៀតដែរ ភាពក្រីក្រគឺជាមូលហេតុចម្បងដែលនាំឱ្យកើតមានបញ្ហាពលកម្មកុមារ។ ក្រុមគ្រួសារក្រីក្រដែលខ្វះខាតធនធានមានជំនាញនិងការអប់រំទាប និងមានប្រាក់ចំណូលតិចអាចនឹងបញ្ជូនកូនរបស់ពួកគាត់ទៅធ្វើការ។ ការប៉ាន់ប្រមាណភាពក្រីក្ររបស់ប្រទេសកម្ពុជាបានបង្ហាញថា មួយភាគបីនៃចំនួនប្រជាជនទូទាំងប្រទេសដែលមាន ១៤ លាននាក់ រស់នៅក្រោមបន្ទាត់នៃភាពក្រីក្រ។ ប្រមាណជា ៥០ភាគរយនៃចំនួនប្រជាជនទាំងអស់គឺជាយុវវ័យដែលមានអាយុក្រោម ១៨ ឆ្នាំ។ ការស្រាវជ្រាវអំពីពលកម្មកុមារក្នុងប្រទេសកម្ពុជា[៤] (២០០១) បានប៉ាន់ស្មានថា កុមារដែលមានអាយុចាប់ពី ៥ ដល់ ១៤ ឆ្នាំមានប្រមាណជា ៤៥ % ជា "កុមារបំរើការងារ" នេះមានន័យថា មានកុមារស្ទើរតែមួយនាក់ក្នុងចំណោមកុមារ ២នាក់ គឺធ្វើការងារ។ ចំនួនកុមារាធ្វើការងារ មានច្រើនជាងចំនួនកុមារី។ ស្ទើរតែ ៩០% នៃចំនួនកុមារបំរើការងារដែលមានអាយុពី ៥ ដល់ ១៧ ឆ្នាំ បានកំពុងរៀនផង និងធ្វើការងារផង។ កុមារដែលបម្រើការងារភាគច្រើនមកពីតំបន់ជនបទ។ ការងារមួយចំនួនរបស់ពួកគេគឺជាការងារដែលស្ថិតនៅក្នុងទម្រង់ធ្ងន់ធ្ងរបំផុតនៃពលកម្មកុមារ។

ជាធម្មតាបញ្ហាពលកម្មកុមារ ច្រើនតែកើតមានឡើងនៅក្នុងវិស័យសេដ្ឋកិច្ចមិនរៀបរយ នៅតាមតំបន់ជនបទ និងនៅតាមបណ្តាកន្លែងឧស្សាហកម្មនានាដែលលាក់កំបាំងពីភ្នែកសាធារណៈជន។ កុមារដែលត្រូវបានគេចាត់ទុកថាជាពលករកុមារ គឺនៅពេលដែលពួកគេចាប់ធ្វើការនៅក្រោមអាយុស្របច្បាប់ដែលអនុញ្ញាឱ្យចូលបម្រើការងារ ឬនៅពេលដែលពួកគេធ្វើការនៅក្នុងការងារដែលប្រកបដោយគ្រោះថ្នាក់ មិនស្របច្បាប់ ឬ

---

[១] របាយការណ៍ ILO ពិភពលោកស្តីពីពលកម្មកុមារ – ២០១០

[២] ពលកម្មកុមារ គឺការងារធ្វើឡើងដោយកុមារដែលឋិតនៅក្រោមអាយុអប្បបរមាក្នុងការបម្រើការងារជាក់លាក់ ដែលត្រូវបានកំនត់នៅក្នុងច្បាប់ជាតិស្របទៅនឹងសេចក្តីថ្លែងការណ៍របស់ILOស្តីពីសិទ្ធិមូលដ្ឋាន និងសិទ្ធិនៅកន្លែងការងារ (១៩៩៨) និងអនុសញ្ញា ILO លេខ ១៣៨ និង ១៨២

[៣] ទម្រង់ធ្ងន់ធ្ងរបំផុតនៃពលកម្មកុមារ ត្រូវបានឱ្យនិយមន័យ នៅក្នុងអនុសញ្ញាទម្រង់ធ្ងន់ធ្ងរបំផុតនៃពលកម្មកុមារនៅឆ្នាំ ១៩៩៩ (លេខ ១៨២) ដូចខាងក្រោមៈ

ក. គ្រប់ទម្រង់ទាសភាព ឬ ការអនុវត្តន៏ប្រហាក់ប្រហែលទៅនឹងទាសភាពដូចជាការលក់ និងការជួញដូរកុមារ ការងារដោះបំណុល និង ការងារជាខ្ញុំកញ្ជះ ការងារដោយបង្ខំ ឬការងារដោយកាតព្វកិច្ច រួមទាំងការជ្រើសរើសកុមារដោយបង្ខំ ឬដោយកាតព្វកិច្ច ដើម្បីឱ្យបម្រើក្នុងជំលោះប្រដាប់អាវុធ

ខ. ការប្រើប្រាស់ ការអូសទាញ ឬការអនុញ្ញាតអោយកុមារបម្រើក្នុងពេស្យាកម្ម ការផលិតរូបភាព អាសគ្រាម ឬការសំដែងអាសគ្រាម

គ.ការប្រើប្រាស់កុមារបម្រើក្នុងសកម្មភាពខុសច្បាប់ ជាពិសេសការផលិត និងរត់ពន្ធគ្រឿងញៀនដែលត្រូវបានកំនត់នៅក្នុងអនុសញ្ញាអន្តរជាតិដែលពាក់ព័ន្ធ។

ឃ.ប្រភេទការងារទាំងឡាយណាដែលជាប្រភេទ ឬដំណើរការនៃប្រតិបត្តិការការងាររបស់វាបង្កឱ្យមានគ្រោះថ្នាក់ បំពាន និងកេងប្រវ័ញ្ចញើសកម្លាំងឈាមរបស់កុមារ ហើយធ្វើឱ្យកុមារឃ្លាតឆ្ងាយពីការអប់រំ។

[៤] ការស្ទង់មតិ អំពីពលកម្មកុមារនៅប្រទេសកម្ពុជានៅឆ្នាំ ២០០១ ដោយវិទ្យាស្ថានជាតិស្ថិតិ

លក្ខខណ្ឌការងារមិនសមស្រប ដែលការងារទាំងអស់នោះបណ្តាលឱ្យមានភាពរាំងស្ទះដល់លទ្ធភាពក្នុងការអភិវឌ្ឍន៍រូបរាងកាយ និងស្មារតីពួកគេឱ្យបានពេញលេញនាពេលអនាគត។ និយោជកនិងសមាគមនិយោជកគឺជាអ្នកដើរតួនាទីយ៉ាងសំខាន់ដំបូងគេនៅក្នុងការប្រឆាំងពលកម្មកុមារទាំងថ្នាក់ជាតិ និងសកល។ និយោជកអាចចាត់វិធានការទទួលខុសត្រូវក្នុងការដកហូតកុមារចេញពីកន្លែងធ្វើការរបស់ពួកគេ ឬពួកគេអាចកាត់បន្ថយគ្រោះថ្នាក់ការងារសម្រាប់កុមារដែលមានវ័យជំទង់ ហើយពួកគេក៏អាចបដិសេធក្នុងការជួលកុមារផងដែរ។ លើសពីនេះទៅទៀត និយោជក និងសមាគមនិយោជក ក៏អាចបញ្ចុះបញ្ចូលឱ្យមានការចូលរៀននៅតាមសាលា និងវគ្គបំពាក់បំប៉ននានាប្រកបដោយប្រសិទ្ធភាព ហើយពួកគេក៏អាចជួយក្នុងលើកកំពស់ការយល់ដឹង និងផ្លាស់ប្តូរឥរិយាបថរបស់សាធារណជនផងដែរ។

នាថ្ងៃទី ១០ និង ១១ ខែឧសភា ឆ្នាំ ២០១០នៅក្នុង *"សន្និសិទស្តីពីពលកម្មកុមារសកលក្នុងឆ្នាំ ២០១០"* មានអ្នកចូលរួមដែលជាតំណាងមកពី រដ្ឋាភិបាល សមាគមនិយោជក សហជីព អង្គការក្រៅរដ្ឋាភិបាល អង្គការសង្គមស៊ីវិលផ្សេងៗទៀត អង្គការថ្នាក់តំបន់ និងថ្នាក់អន្តរជាតិ បានមកជួបជុំគ្នានៅទីក្រុង ឡាអេ (Hague) ប្រទេសណែដឺឡែន (Netherlands) ដើម្បីពិនិត្យមើលលើភាពរីកចម្រើនចាប់តាំងពីការអនុម័តអនុសញ្ញាអង្គការពលកម្មអន្តរជាតិ ស្តីពីទម្រង់ធ្ងន់ធ្ងរបំផុតនៃពលកម្មកុមារ ឆ្នាំ ១៩៩៩ (លេខ ១៨២) ដើម្បីដោះស្រាយលើឧបសគ្គដែលនៅសេសសល់ និងអនុម័តយល់ព្រមលើវិធានការក្នុងការពន្លឿនដំណើរការឆ្ពោះទៅកាន់ការលុបបំបាត់ទម្រង់ធ្ងន់ធ្ងរបំផុតនៃពលកម្មកុមារ នៅឆ្នាំ ២០១៦ ស្របគ្នាជាមួយគ្នានឹងកិច្ចធ្វើការយល់ព្រមលើគោលដៅនៃការលុបបំបាត់ពលកម្មកុមារដែលប្រកបដោយប្រសិទ្ធភាព ដែលឆ្លុះបញ្ចាំងពីការប្រកាសរបស់អង្គការពលកម្មអន្តរជាតិស្តីពីគោលការណ៍ និងសិទ្ធិជាមូលដ្ឋាននៅកន្លែងធ្វើការ (១៩៩៨) និងអនុសញ្ញាILO ឆ្នាំ ១៩៧៣ (លេខ ១៣៨) អនុសញ្ញាលេខ ១៨២ នៅឆ្នាំ ១៩៩៩ ជាអនុសញ្ញាបំពេញបន្ថែម។ សន្និសីទនេះត្រូវបានប្រកាសថាជាដំណើរ *ឆ្ពោះទៅកាន់ពិភពលោកដែលគ្មានពលកម្មកុមារ និងការបង្កើតផែនទីបង្ហាញផ្លូវសំដៅឆ្ពោះទៅកាន់ឆ្នាំ ២០១៦*។

នៅថ្នាក់តំបន់ ថ្នាក់ដឹកនាំសមាគមប្រជាជាតិអាស៊ីអាគ្នេយ៍ (ASEAN) រដ្ឋមន្ត្រី និង/ឬមន្ត្រីជាន់ខ្ពស់បានប្តេជ្ញាចិត្តក្នុងការចាត់វិធានការដ៏មានប្រសិទ្ធភាព ក្នុងការលុបបំបាត់ទម្រង់ធ្ងន់ធ្ងរបំផុតនៃពលកម្មកុមារនៅ ASEANនៅឆ្នាំ ២០១៦។ ថ្នាក់ដឹកនាំ ASEANបានប្តេជ្ញាក្នុងការធ្វើឱ្យសម្រេចបាននូវការលុបបំបាត់ពលកម្មកុមារនៅក្នុងទម្រង់ធ្ងន់ធ្ងរបំផុតនាឆ្នាំ ២០១៦។ ASEAN អាចដើរ តាមផែនការសកម្មភាពជាសកលរបស់អង្គការពលកម្មអន្តរជាតិ ដែលផែនការនេះត្រូវបានកែសម្រួលពីគោលដៅអភិវឌ្ឍន៍សហស្សវត្ស គោលដៅទសវត្សសម្រាប់ការងារសមរម្យនៅអាស៊ី ក៏ដូចជាគោលដៅថ្នាក់ជាតិ ដែលបានកំនត់យកដោយប្រទេសដែលជាសមាជិក ASEAN[5]។

ពលកម្មកុមារជាពិសេសទម្រង់ធ្ងន់ធ្ងរបំផុតរបស់វា ត្រូវបានលើកយកមកពិភាក្សាក្នុងចំណោមសមាជិក ASEAN នៅក្នុងកិច្ចប្រជុំមន្ត្រីការងារជាន់ខ្ពស់ (SLOM) ដើម្បីគាំទ្រសម្រេចបានគោលដៅនៃការលុបបំបាត់ទម្រង់ធ្ងន់ធ្ងរបំផុតនៃពលកម្មកុមារប្រកបដោយប្រសិទ្ធភាព។ កិច្ចប្រជុំនេះត្រូវបានចូលរួមដោយតំណាង ពីក្រសួងនានាដែលទទួលខុសត្រូវលើការងារ សុខុមាលភាពសង្គម ការអប់រំ ផែនការ សិទ្ធិមនុស្ស សិទ្ធិការងារ យុត្តិធមិ

[5] ឧទាហរណ៍ដូចជា កម្ពុជា ថៃឡង់ និង ភីលីពីន បានបង្កើតនូវ គោលដៅថ្នាក់ជាតិនៅឆ្នាំ ២០១៦ សម្រាប់ការលុបបំបាត់ទម្រង់ធ្ងន់ធ្ងរបំផុតនៃពលកម្មកុមារ។ ប្រទេសវៀតណាមកំពុងបង្កើតផែនការសកម្មភាពជាតិស្របតាមគោលដៅឆ្នាំ ២០១៦។

សន្តិសុខសង្គម ប្រឆាំងភាពក្រីក្រ និងសិទ្ធិកុមារ។ កិច្ចប្រជុំនេះក៏ត្រូវបានចូលរួមដោយអង្គការ រដ្ឋាភិបាលអន្តរជាតិ (IGOs) ដែលពាក់ព័ន្ធដូចជា ILO-IPEC, UNICEF, UNESCO, UNDP, ធនាគារពិភពលោក, ADB, IMF និង IFI ផ្សេងៗទៀត ជាអ្នកចូលរួម និងឧបត្ថម្ភ។ ដៃគូសង្គម និងអង្គការសង្គមស៊ីវិលពាក់ព័ន្ធក៏បានចូលរួមផងដែរ។

ដំណើរការនេះអាចត្រូវបានដឹកនាំយ៉ាងរលូនដោយSLOM លេខាធិការដ្ឋានASEAN គណៈកម្មការASEAN ស្តីពីការលើកកម្ពស់ និងការការពារសិទ្ធិរបស់ស្ត្រី និងកុមារ កិច្ចប្រជុំមន្ត្រីជាន់ខ្ពស់ស្តីពីសុខុមាលភាព និងការអភិវឌ្ឍន៍សង្គម និងភាគីពាក់ព័ន្ធរបស់ ASEAN ផ្សេងៗទៀត។ លេខាធិការដ្ឋានASEAN ដើរតួយ៉ាងសំខាន់ក្នុងការលុបបំបាត់ពលកម្មកុមារ និងទម្រង់ធ្ងន់ធ្ងរបំផុតរបស់វា។

***សហព័ន្ធនិយោជក និងសមាគមពាណិជ្ជកម្មកម្ពុជា(CAMFEBA)*** ចាត់ទុកការលុបបំបាត់ពលកម្មកុមារ គឺជាបញ្ហាមួយក្នុងចំណោមបញ្ហាសំខាន់ៗ នៅក្នុងរបៀបវារៈរបស់និយោជកនៅក្នុងព្រះរាជាណាចក្រកម្ពុជា ពីព្រោះពលកម្មកុមារ បណ្តាលឱ្យផលិតភាពរបស់ពួកគេថយចុះ ជះឥទ្ធិពលដល់ផលប្រយោជន៍ពាណិជ្ជកម្ម ផ្ទុយទៅនឹងទំនួលខុសត្រូវរបស់ក្រុមហ៊ុនចំពោះសង្គម ហើយប្រឆាំងនឹងឧបករណ៍ច្បាប់ទាំងថ្នាក់ជាតិ និងអន្តរជាតិ ដូចជាច្បាប់ការងារ អនុសញ្ញាអង្គការសហប្រជាជាតិស្តីពីសិទ្ធិកុមារ (UNCRC) អនុសញ្ញា ILO លេខ ១៣៨[៦] និង ១៨២[៧] ។ល។

ឆ្លើយតបនឹងការលុបបំបាត់ពលកម្មកុមារ CAMFEBA បានខិតខំប្រឹងប្រែងយ៉ាងខ្លាំងក្លា តាមរយៈការសហការយ៉ាងជិតស្និទ្ធជាមួយរាជរដ្ឋាភិបាលកម្ពុជា (RGC) សហជីព ភ្នាក់ងារ UNL/INGOsនិងCSOs GMAC និងវិស័យឯកជន ក្នុងការគាំទ្រកិច្ចខិតខំប្រឹងប្រែងរបស់កម្ពុជាចំពោះការផ្តល់សច្ចាប័ន និងការអនុវត្តអនុសញ្ញា ILO លេខ ១៣៨ និង ១៨២ និង ការអនុម័តប្រកាសស្តីពីពលកម្មកុមារ ការអនុម័ត NPA-WFCL(2008-2012) និងឧបករណ៍ច្បាប់ថ្នាក់ជាតិ និងថ្នាក់អន្តរជាតិនានា ក្នុងការលើកទឹកចិត្តរដ្ឋសភា និងព្រឹទ្ធសភា ដើម្បីផ្តល់សច្ចាប័នលើអនុសញ្ញា ILO លេខ ១៣៨ និង ១៨២ នៅប្រទេសកម្ពុជា។

ក្រៅពីដើរតួជាសមាជិកមួយនៃសមាជិកត្រីភាគីរបស់ ILO ដែលក្នុងនោះរួមមានអង្គការតំណាងកម្មករ ក៏ដូចជាដៃគូសង្គមរបស់ ILO CAMFEBA/និយោជក និងសហជីព បានដើរតួយ៉ាងសំខាន់ក្នុងការកៀងគរមតិសាធារណៈ ដើម្បីប្រឆាំងនឹងពលកម្មកុមារ ហើយនិងលើកយកបញ្ហាពលកម្មកុមារ និងការលុបបំបាត់ពលកម្មកុមារដាក់ក្នុងរបៀបវារៈរបស់CAMFEBA/សមាគមនិយោជក។

CAMFEBA បានខិតខំប្រឹងប្រែងក្នុងការការពារ និងលើកកម្ពស់សិទ្ធិទាំងអស់របស់កុមារតាមរយៈការគាំទ្រការបង្កើតឡើងនូវគោលនយោបាយថ្នាក់ជាតិ និងកំនត់គោលដៅក្នុងការលុបបំបាត់ពលកម្មកុមារនៅក្នុងប្រទេស។ ពលកម្មកុមារបានធ្វើសមាហកម្មយ៉ាងល្អិតល្អន់ចូលទៅក្នុងយុទ្ធសាស្ត្រថ្នាក់ជាតិក្នុងការលុបបំបាត់ភាពក្រីក្រ (NPRS – in 2006) និងគោលដៅអភិវឌ្ឍន៍សហស្សវត្សរកម្ពុជា (CMDGs) ដែលរួមបញ្ចូលផែនការសកម្មភាពជាតិ ស្តីពីការលុបបំបាត់ទម្រង់ធ្ងន់ធ្ងរបំផុតនៃពលកម្មកុមារ (NPA-WFCL)។ គោលនយោបាយទាំងនេះបានបញ្ជាក់យ៉ាងច្បាស់នូវគោលដៅរបស់ប្រទេសក្នុងការកាត់បន្ថយនូវទម្រង់ធ្ងន់ធ្ងរបំផុតនៃពលកម្មកុមារ ចំពោះកុមារដែលមានអាយុពី ៥ ទៅ ១៧ ឆ្នាំ ពី ១៦.៥% នៅក្នុងឆ្នាំ ១៩៩៩ មកនៅត្រឹម ១៣% នៅក្នុងឆ្នាំ ២០០៥ ហើយនឹងមកត្រឹម ៨% នៅក្នុងឆ្នាំ ២០១៥។

---

[៦] អាយុអប្បបរមាក្នុងការបម្រើការងារ

[៧] សកម្មភាពបន្ទាន់ក្នុងការលុបបំបាត់ទម្រង់ធ្ងន់ធ្ងរបំផុតនៃពលកម្មកុមារ

***សហព័ន្ធនិយោជក និងសមាគមពាណិជ្ជកម្មកម្ពុជា(CAMFEBA)*** ត្រូវបានបង្កើតឡើងនៅក្នុងខែកក្កដា ឆ្នាំ ២០០០ ក្រោមច្បាប់ការងារកម្ពុជា និងជាអង្គការនិយោជកដែលប្រកបដោយវិជ្ជាជីវៈតែមួយនៅក្នុងប្រទេសកម្ពុជា។ ***CAMFEBA*** ត្រូវបានទទួលស្គាល់ដោយរាជរដ្ឋាភិបាលកម្ពុជា ILO និង ភ្នាក់ងារជាតិ និងអន្តរជាតិ ថាជាសមាជិកដំបូងគេបង្អស់ដែលតំណាងអោយការលើកកម្ពស់ និងការពារសិទ្ធិ និងផលប្រយោជន៏របស់និយោជកនៅក្នុងប្រទេស។ សព្វថ្ងៃនេះ CAMFEBA តំណាងឱ្យជាង ១០០០ និយោជកនៅក្នុងប្រទេសកម្ពុជា។ CAMFEBA ក៏ជាសមាជិករបស់ សមាគមនិយោជកអន្តរជាតិ(IoE) សហព័ន្ធនិយោជកASEAN(ACE) និងសហព័ន្ធនិយោជកអាស៊ីប៉ាស៊ីហ្វិក (CAPE)។ នាពេលបច្ចុប្បន្ន CAMFEBA គឺជាដៃគូសង្គមយ៉ាងសំខាន់នៃអង្គការពលកម្មអន្តរជាតិ អនុវត្តលើកម្មវិធីអន្តរជាតិសម្រាប់ការលុបបំបាត់ពលកម្មកុមារ (ILO IPEC) នៅកម្ពុជាក្នុងការចូលរួមចំណែកក្បៀងគរមតិសាធារណៈ ជាពិសេសនិយោជក ឱ្យលុបបំបាត់ពលកម្មកុមារនៅក្នុងប្រទេសកម្ពុជា។ CAMFEBA បានរៀបចំខ្លួនជាស្រេចក្នុងការចូលរួមចំណែកលុបបំបាត់ពលកម្មកុមារនៅកម្ពុជា ដើម្បីសម្រេចគោលដៅភ្លោះរបស់រាជរដ្ឋាភិបាលកម្ពុជា CAMFEBA នៅឆ្នាំ ២០១៥ និង ២០១៦: ***សម្រាប់ការលុបបំបាត់ពលកម្មកុមារពី ១៦.៥ % នៅឆ្នាំ ១៩៩៩ មកត្រឹម ៨ % នៅឆ្នាំ ២០១៥ និងការបញ្ចប់ទម្រង់ធ្ងន់ធ្ងរបំផុតនៃពលកម្មកុមារនៅឆ្នាំ ២០១៦ នៅក្នុងប្រទេស។***

## ១.២. និយមន័យនៃពលកម្មកុមារ

*…មាត្រាទី ២ នៃអនុសញ្ញា ILO ស្តីពីទម្រង់ធ្ងន់ធ្ងរបំផុតនៃពលកម្មកុមារ បានឱ្យនិយមន័យលើ"កុមារ" គឺជាបុគ្គលដែលមានអាយុក្រោម ១៨ឆ្នាំ។ ពលកម្មកុមារ គឺជាការងារដែលធ្វើឱ្យមានផលប៉ះពាល់ដល់សុខុមាលភាពរបស់កុមារ ការអប់រំ ការអភិវឌ្ឍន៍ និងការរស់រាននៅថ្ងៃអនាគតរបស់ពួកគេ។ ពលកម្មកុមារ គឺជាការងារទាំងឡាយណាដែល ប្រភេទ ឬដំណើរការនៃប្រតិបត្តិការការងាររបស់វាបង្កឱ្យមានគ្រោះថ្នាក់ បំពាន និងកេងប្រវ័ញ្ចញើសឈាមរបស់កុមារ ហើយធ្វើឱ្យកុមារឃ្លាតឆ្ងាយពីការអប់រំ។*

### ***និយមន័យផ្សេងទៀតនៃកុមារបម្រើការងារ***

*ក្រៅពីពាក្យ "ពលកម្មកុមារ" អង្គការពលកម្មអន្តរជាតិ (ILO) បានប្រើប្រាស់ពាក្យ "កុមារបម្រើការងារ" និង"កុមារបម្រើសកម្មភាពសេដ្ឋកិច្ច" ក្នុងបំណងបង្កើតពាក្យងាយយល់សម្រាប់ពេលធ្វើស្ថិតិ។ ពាក្យទាំងពីរនេះ សំដៅទៅលើការងារដែលធ្វើឡើងដោយកុមារលើសពីមួយម៉ោងក្នុងមួយសប្តាហ៍។ ការងារនេះអាចជាការងារដែលត្រូវទទួលបានប្រាក់កម្រៃ ឬគ្មានប្រាក់កំរៃសម្រាប់ការងារក្នុងទីផ្សារ ឬគ្មានទីផ្សារ មានលក្ខណៈទៀងទាត់ ឬយូរៗម្តង ស្របច្បាប់ ឬមិនស្របច្បាប់។ នៅក្នុងករណីភាគច្រើន ការងារទាំងនោះស្ថិតនៅក្រោមច្បាប់ ហេតុដូច្នេះ វាមិនត្រូវបានចាត់ទុកថាជាពលកម្មកុមារនោះទេ។ ហេតុដូចនេះហើយវាមានសារៈសំខាន់សម្រាប់ពេលអានស្ថិតិដើម្បីបែងចែកឱ្យច្បាស់រវាង "ពលកម្មកុមារ" ដែលមានលក្ខណៈ ខុសច្បាប់ និងសកម្មភាពផ្សេងៗដែលត្រូវបានធ្វើដោយកុមារតែជាការងារស្របច្បាប់។ ILO ប្រើប្រាស់នូវពាក្យបច្ចេកទេសទាំងនេះ ពីព្រោះវាមានភាពងាយស្រួលក្នុងការប្រមូលទិន្នន័យដោយផ្អែកលើពាក្យខុសគ្នាទាំងនេះជាជាងផ្អែកលើពាក្យពលកម្មកុមារតែមួយ។ និយមន័យនឹងកាន់តែទូលំទូលាយជាងនេះសម្រាប់ការប្រើប្រាស់លើទិន្នន័យប្រៀបធៀបពីប្រទេសមួយទៅប្រទេសមួយទៀតដែលត្រូវផ្តល់ដោយ ILO។*

***និយមន័យនៃពលកម្មកុមារ យោងតាមរាជរដ្ឋាភិបាលកម្ពុជា***[៨]

*...ឆ្លងតាមកិច្ចពិភាក្សាស្តីពីការលុបបំបាត់ទម្រង់ធ្ងន់ធ្ងរបំផុតនៃពលកម្មកុមារ (WFCL) ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ (MLVT) បានឱ្យនិយមន័យនៃពលកម្មកុមារ ថាជាការងារដែលធ្វើដោយកុមារក្រោមអាយុ ១៨ ឆ្នាំ រួមបញ្ចូលការងារបានប្រាក់កម្រៃ ឬគ្មានប្រាក់កម្រៃដែលប៉ះពាល់ដល់ការលូតលាស់ផ្នែកបញ្ញាស្មារតី ផ្នែករូបរាងកាយ ផ្នែកសង្គម ឬសីលធម៌របស់កុមារ និងរារាំងកុមារក្នុងការទទួលបានការអប់រំ។ ការងារណាដែលជួយដល់អប់រំ ឬបណ្តុះបណ្តាលកុមារសម្រាប់ការងារនៅពេលអនាគត និងជាផ្នែកមួយនៃដំនើរការរបស់សង្គម និងគ្រួសារ វាត្រូវបានកំនត់ថាជាការងារកុមារ និងមិនត្រូវបានចាត់ទុកថាជាពលកម្មកុមារ ឬពលកម្មកុមារ នៅក្នុងទម្រង់ធ្ងន់ធ្ងរបំផុតនោះទេ។*

*ខាងក្រោមនេះគឺជាការដកស្រង់ចេញពីអនុសញ្ញា ILO ១៨២ បកស្រាយបន្ថែមពីអត្ថន័យពលកម្មកុមារ។*

- *ទម្រង់ធ្ងន់ធ្ងរបំផុតនៃពលកម្មប្រឆាំងនឹងសិទ្ធិមូលដ្ឋានរបស់មនុស្ស ដូចជាទាសភាពលើកុមារ ឬការអនុវត្តន៍ ប្រហាក់ប្រហែលទៅនឹងទាសភាពដូចជាការលក់ និងការជួញដូរកុមារ ការងារដោះបំណុល និងការងារជាខ្ញុំកញ្ជះ ការងារដោយបង្ខំ ឬការងារដោយកាតព្វកិច្ច រួមទាំងការជ្រើសរើសកុមារដោយបង្ខំ ឬដោយកាតព្វកិច្ច ដើម្បីអោយបម្រើក្នុងជំលោះប្រដាប់អាវុធ ការប្រើប្រាស់កុមារក្នុងការងារប្រើកំលាំងអូសទាញ ឬពេស្យាកម្ម ការផលិតរូបភាពអាសគ្រាម ឬការសំដែងអាសគ្រាម និងការប្រើប្រាស់កុមារឱ្យបម្រើក្នុងសកម្មភាពខុសច្បាប់/ឧក្រិដ្ឋកម្ម។ សកម្មភាពទាំងអស់នេះ គឺខុសនឹងច្បាប់របស់រាជរដ្ឋាភិបាលកម្ពុជា។*
- *ពលកម្មកុមារនៅក្នុងប្រភេទការងារប្រកបដោយគ្រោះថ្នាក់ ឬនៅក្នុងបរិយាកាសការងារគ្រោះថ្នាក់ អាចប៉ះពាល់ដល់សុខភាព សុវត្ថិភាព និងសីលធម៌របស់កុមារបម្រើការងារ។ ការងារទាំងនេះគឺមិនអនុញ្ញាតឱ្យធ្វើសម្រាប់អាយុដែលឋិតនៅក្រោម ១៨ ឆ្នាំ។*

គួរកត់សំគាល់ថា ច្បាប់ការងារបច្ចុប្បន្នរបស់រាជរដ្ឋាភិបាលកម្ពុជាអនុញ្ញាតឱ្យកុមារដែលមានអាយុពី ១២ ដល់ ១៤ ឆ្នាំ ធ្វើការងារស្រាលៗ ប្រសិនបើការងារនេះមិនប្រកបដោយគ្រោះថ្នាក់ និងមិនប៉ះពាល់ដល់ការចូលសាលារៀនរបស់កុមារ ឬការចូលរួមវគ្គបណ្តុះបណ្តាលវិជ្ជាជីវៈ។

## ១.៣. ការប្តេជ្ញាចិត្តរបស់រាជរដ្ឋាភិបាលកម្ពុជា ក្នុងការលុបបំបាត់ពលកម្មកុមារ និងទម្រង់ធ្ងន់ធ្ងរបំផុត

នៅក្នុងច្បាប់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា មាត្រាទី ៤៨ បានទទួលស្គាល់សិទ្ធិកុមារ ដូចដែលបានចែងនៅក្នុងអនុសញ្ញាអង្គការសហប្រជាជាតិស្តីពីសិទ្ធិកុមារ ជាពិសេសសិទ្ធិរស់រានមានជីវិត សិទ្ធិទទួលការអប់រំរៀនសូត្រ សិទ្ធិទទួលការគាំពារក្នុងស្ថានការណ៍មានសង្គ្រាម និងការការពារប្រឆាំងអាជីវកម្មជួញដូរ ឬកាមគុណលើកុមារ។ ច្បាប់ស្តីអំពីការងាររបស់កម្ពុជា ជំពូកទី៨ ស្តីពីស្ត្រី និងពលកម្មកុមារ ក៏បានចែងផងដែរពីក្របខ័ណ្ឌផ្នែកច្បាប់ក្នុងការការពារពលករកុមារ។ ផ្ទុយទៅវិញ បទបញ្ជា និងបទបញ្ញត្តិនានារបស់ក្រសួងត្រូវតែរឹតបន្តឹងបន្ថែមជាពិសេសស្តីពីប្រភេទការងារផ្សេងៗគ្នាដែលប្រកបដោយគ្រោះថ្នាក់ និងមិនអនុញ្ញាតឱ្យ

[៨] ផ្អែកលើ NPA-WFCL២០០៩-២០១២

កុមារធ្វើការងារប្រកបដោយគ្រោះថ្នាក់ និងហាមឃាត់សម្រាប់កុមារ លក្ខខណ្ឌពិសេសៗសម្រាប់ការហ្វឹកហ្វឺនកូនជាង ការបែងចែកការងារ និងការងារស្រាលៗដែលកុមារអាចធ្វើបាន។ រហូតមកដល់បច្ចុប្បន្ននេះ នាយកដ្ឋានការងារកុមារ/ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ បានចេញនូវបទបញ្ជា (ប្រកាស) ចំនួន ១២ ស្តីពីលក្ខខណ្ឌការងារសម្រាប់កុមារនៅក្នុងវិស័យឡឥដ្ឋ នេសាទ កាត់ដេរសម្លៀកបំពាក់ និងស្បែកជើង ដំណាំកៅស៊ូ ផលិតអំបិល ការងារស្រាលៗ (សម្រាប់អាយុពី ១២ ដល់ ១៥ ឆ្នាំ) ការលើកដាក់ទម្ងន់ដោយកម្លាំងកុមារ និងសារាចរលេខ ០១២ សម្រាប់កម្មករ ឬនិយោជិតដែលមានអាយុពី១៥ ដល់ ១៨ឆ្នាំ ដែលរួមមានប្រកាស ស្តីពីកុមារធ្វើការនៅក្នុងមុខរបរកសិកម្មចិញ្ចឹមជីវិតដូចជាថ្នាំជក់ ការនេសាទឆ្ងាយពីមាត់សមុទ្រ មុខរបរផលិតកម្មជំឡូងមី និងការងារចំការ។

ផែនការសកម្មភាពរបស់ CAMFEBA ស្តីពីការលុបបំបាត់ពលកម្មកុមារ (CAMFEBA -PAECL) ត្រូវបានបង្កើតឡើងដោយផ្អែកលើគោលនយោបាយរាជរដ្ឋាភិបាលកម្ពុជាដែលមានស្រាប់ និងច្បាប់នៃប្រទេសកម្ពុជាក្នុងការពង្រឹង និងចូលរួមចំណែកក្នុងគោលដៅរបស់រាជរដ្ឋាភិបាលកម្ពុជាក្នុងការកាត់បន្ថយ និងលុបបំបាត់ពលកម្មកុមារនៅក្នុងប្រទេស ដែលបានកំនត់នូវគោលដៅយ៉ាងច្បាស់ក្នុងការលុបបំបាត់ពលកម្មកុមារ ដើម្បីលើកកម្ពស់សេដ្ឋកិច្ច និងជីវភាពរស់នៅរបស់ប្រជាជនក្នុងប្រទេសកម្ពុជា។ CAMFEBA ដែលជាសហគមន៍តំណាងនិយោជកនៅក្នុងប្រទេសកម្ពុជា បានតស៊ូមតិ និងចរចាជាមួយរដ្ឋាភិបាល សហជីព និង សង្គមស៊ីវិល ដើម្បីធ្វើការស្របទៅតាមរាល់គោលនយោបាយគន្លឹះ និងធានាថាប្រទេសកម្ពុជានឹងមិនមានពលកម្មកុមារនៅឆ្នាំ ២០១៦។

### ១.៣.១. ក្របខ័ណ្ឌគោលនយោបាយ ក្នុងការលុបបំបាត់ពលកម្មកុមារ

រាជរដ្ឋាភិបាលកម្ពុជាបានចាត់វិធានការនានាក្នុងការកាត់បន្ថយ និងលុបបំបាត់ពលកម្មកុមារនៅក្នុងប្រទេស។ រាជរដ្ឋាភិបាលកម្ពុជាបានបង្កើត និងអនុវត្តនូវក្របខ័ណ្ឌគោលនយោបាយថ្នាក់ជាតិ ដែលកំណត់ពលកម្មកុមារជាសូចនាករសំខាន់សម្រាប់សេដ្ឋកិច្ច ការលុបបំបាត់ភាពក្រីក្រ និងការលើកកម្ពស់សិទ្ធិកុមារ។ យុទ្ធសាស្ត្រចតុកោណរបស់រាជរដ្ឋាភិបាលកម្ពុជាបានផ្តោតសំខាន់ទៅលើកំណើនការងារ សមធម៌ និងប្រសិទ្ធភាព ហើយបានចាត់ទុកកុមារ គឺជាឆ្អឹងខ្នងនៃសេដ្ឋកិច្ចជាតិ និងមូលធនមនុស្សនៅក្នុងប្រទេស។ លើសពីនេះទៅទៀត ផែនការអភិវឌ្ឍន៍យុទ្ធសាស្ត្រជាតិ (NSDP) ឆ្នាំ ២០០៩-២០១៣ បានកំនត់យ៉ាងច្បាស់ក្នុងការលើកកម្ពស់សុវត្ថិភាពនៅកន្លែងការងារសម្រាប់កុមារអាយុពី ១៥ ដល់ ១៨ឆ្នាំ (អាយុអប្បបរមាក្នុងការបម្រើការងារ) និងក្នុងការលុបបំបាត់ទម្រង់ធ្ងន់ធ្ងរបំផុតនៃពលកម្មកុមារឱ្យអស់នៅក្នុងឆ្នាំ ២០១៦ (ទំព័រទី ១៥៩) និងគោលដៅអភិវឌ្ឍន៍សហស្សវត្សរបស់ប្រទេសកម្ពុជា (CMDG) ក្នុងការកាត់បន្ថយពលកម្មកុមារពី ១៦.៥% នៅឆ្នាំ ១៩៩៩ មកត្រឹម ៨% នៅឆ្នាំ ២០១៥។ ទាំងNSDP និង CMDG បានផ្តល់ការងារ បង្កើនការផ្គត់ផ្គង់ពលកម្មជំនាញ និងការលុបបំបាត់ទម្រង់ធ្ងន់ធ្ងរបំផុតនៃពលកម្មកុមារ។ ការធានាបាននូវលក្ខខណ្ឌការងារសមរម្យ និងការអនុវត្តច្បាប់ការងារ និងលក្ខខណ្ឌអន្តរជាតិ នឹងផ្តល់ឱ្យនូវការបន្តចូលរួមចំណែកនិងពង្រឹងកិច្ចខិតខំប្រឹងប្រែងក្នុងការកាត់បន្ថយកុមារបម្រើការងារ (ពលកម្មកុមារ)។ លើសពីនេះទៅទៀត សំណាញ់សន្តិសុខសង្គម ត្រូវបានផ្តល់ឱ្យដល់ជនរងគ្រោះពីការជួញដូរដែលជាអនីតិជន កុមារជាប់ទោស ជនរស់នៅតាមចិញ្ចើមថ្នល់ ក្មេងកំព្រា និងកុមារដែលងាយរងគ្រោះដទៃទៀត។ ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈបានកំណត់បញ្ហាពលកម្មកុមារ ជាបញ្ហាអាទិភាពនៅក្នុងផែនការយុទ្ធសាស្ត្រប្រាំឆ្នាំរបស់ក្រសួង ២០០៦-២០១០។

ផែនការសកម្មភាពជាតិស្តីពីការលុបបំបាត់ទម្រង់ធ្ងន់ធ្ងរបំផុតនៃពលកម្មកុមារ ត្រូវបានអនុម័តដោយរាជរដ្ឋាភិបាលកម្ពុជានៅថ្ងៃទី ១៦ ខែ មិថុនា ឆ្នាំ ២០០៨។ ផែនការនេះ ត្រូវបានអនុវត្តដោយក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ដោយទទួលបានការគាំទ្រផ្នែកហិរញ្ញវត្ថុ និងបច្ចេកទេសពីអង្គការ ILO IPEC អង្គការវីនរ៉ក់អន្តរជាតិ និងអង្គការក្រៅរដ្ឋាភិបាលជាតិ និងអន្តរជាតិនៅក្នុងប្រទេស ហើយផែនការនេះ កំពុងស្ថិតនៅក្នុងដំណើរនៃការបង្កើតនូវផែនការថ្នាក់ជាតិវគ្គទី២ (២០១៣-២០១៧)។ ផែនការថ្នាក់ជាតិវគ្គទី២ បានដកស្រង់នូវការអនុវត្ត និងបទពិសោធន៏ល្អៗ ពីការអនុវត្តនូវផែនការថ្នាក់ជាតិវគ្គទី១ ដើម្បីពង្រឹងការលុបបំបាត់ទម្រង់ធ្ងន់ធ្ងរបំផុតនៃពលកម្មកុមារ ដែលត្រូវបានកំនត់ដោយគោលដៅភ្លោះរបស់រាជរដ្ឋាភិបាលកម្ពុជានៅឆ្នាំ ២០១៦។

នៅថ្ងៃទី ១០-១១ ខែឧសភា ឆ្នាំ ២០១១ អង្គការ ILO IPEC បានអនុម័តលើផែនទីបង្ហាញផ្លូវជាសកលមួយក្នុងការបញ្ចប់នូវទម្រង់ធ្ងន់ធ្ងរបំផុតនៃពលកម្មកុមារនៅឆ្នាំ ២០១៦។ កម្ពុជា គឺជាប្រទេសមួយក្នុងចំនោមប្រទេសតិចតួចបំផុត ដែលបានទទួលយកផែនទីបង្ហាញផ្លូវជាសកលនេះ ហើយនិងបានបង្កើតផែនទីបង្ហាញផ្លូវថ្នាក់ជាតិ ដែលរួមបញ្ចូលនូវជំហានទាំង ១២ ដើម្បីឆ្ពោះទៅកាន់ការលុបបំបាត់ទម្រង់ធ្ងន់ធ្ងរបំផុតនៃពលកម្មកុមារនៅក្នុងប្រទេសកម្ពុជា។

**គោលនយោបាយភូមិ ឃុំមានសុវត្ថិភាព** បានអនុម័ត និងដាក់ចូលជាធរមាន នៅថ្ងៃទី ១៧ ខែឧសភា ឆ្នាំ ២០១០។ ភូមិ និងឃុំ/សង្កាត់នីមួយៗ ត្រូវធានាឱ្យបាននូវសុវត្ថិភាពនៅក្នុងតំបន់របស់ខ្លួន (មានន័យថា នឹងមិនមាន អំពើចោរកម្ម សកម្មភាពលួច ឆក់ ប្លន់ គ្រប់ប្រភេទ គ្មានការផលិត ការចែកចាយ និងការប្រើប្រាស់គ្រឿងញៀនខុសច្បាប់ គ្មានអំពើអនាចារ្យ ការជួញដូរ ស្ត្រី និងកុមារ និងអំពើហិង្សាក្នុងគ្រួសារ គ្មានក្មេងទំនើង គ្មានការលេងល្បែងស៊ីសងខុសច្បាប់គ្រប់ប្រភេទ ការប្រើប្រាស់អាវុធខុសច្បាប់ និងបទល្មើសគ្រប់ប្រភេទ)។ គោលនយោបាយនេះ បំពេញបន្ថែមលើគោលនយោបាយថ្នាក់ជាតិក្នុងការលុបបំបាត់ទម្រង់ធ្ងន់ធ្ងរបំផុតនៃពលកម្មកុមារ ដែលផ្តោតសំខាន់លើការជួញដូរ កេងប្រវ័ញ្ចផ្លូវភេទមកលើកុមារ (CSEC)។

យុទ្ធសាស្ត្រគាំពារសង្គមថ្នាក់ជាតិ(NSPS)ដែលត្រូវបានបង្កើតឡើងនាពេលថ្មីៗនេះ និងត្រូវបានអនុម័តដោយរាជរដ្ឋាភិបាលកម្ពុជាគឺជាគោលនយោបាយមួយយ៉ាងសំខាន់សម្រាប់ជនក្រីក្រ និងជនងាយរងគ្រោះ ។ គោលនយោបាយនេះបានបញ្ជាក់យ៉ាងច្បាស់នូវតួនាទីរបស់ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ ដើម្បីបង្កើតឱកាស**ការងារសមរម្យ**សម្រាប់ក្រុមងាយរងគ្រោះ និងអនុវត្តជំហានសំខាន់ៗ ដើម្បីឆ្ពោះទៅកាន់ការសម្រេចបាននូវ**គោលដៅភ្លោះស្តីពីពលកម្មកុមារៈ** ក្នុងការកាត់បន្ថយគ្រប់ទម្រង់ទាំងអស់នៃពលកម្មកុមារមកត្រឹម ៨% នៅឆ្នាំ ២០១៥ និងលុបបំបាត់ទម្រង់ធ្ងន់ធ្ងរបំផុតនៃពលកម្មកុមារនៅឆ្នាំ ២០១៦ តាមរយៈការអប់រំ។ កិច្ចការទាំងនេះនឹងផ្តល់នូវឱកាសដ៏ប្រសើរសម្រាប់តួអង្គសង្គម រួមមានសមាគមនិយោជក វិស័យឯកជន ក្នុងការដើរតួយ៉ាងសំខាន់ក្នុងការកាត់បន្ថយ និងលុបបំបាត់ទម្រង់ធ្ងន់ធ្ងរបំផុតនៃពលកម្មកុមារនៅឆ្នាំ ២០១៦។

ច្បាប់ស្តីអំពីការងារដែលត្រូវបានអនុម័តនៅក្នុងឆ្នាំ ១៩៩៧ នាពេលបច្ចុប្បន្ន កំពុងត្រូវបានស្ថិតនៅក្នុងដំណើរនៃការត្រួតពិនិត្យមើលឡើងវិញ និងត្រូវរួមបញ្ចូលនូវភាសា/លក្ខខណ្ឌចាំបាច់ខ្លះស្តីពីការលុបបំបាត់ពលកម្មកុមារ និងទម្រង់ធ្ងន់ធ្ងរបំផុតរបស់វា និងការងារដែលកុមារបម្រើការតាមផ្ទះ ស្របពេលដែលថ្នាក់គ្រប់គ្រងរបស់អង្គការពលកម្មអន្តរជាតិនាពេលថ្មីៗនេះបានអនុម័តលើអនុសញ្ញាលេខ ១៨៩ ស្តីពីការងារសមរម្យសម្រាប់អ្នកបម្រើការតាមផ្ទះ។

ផែនការសកម្មភាពថ្នាក់ជាតិស្ដីពីការបង្ក្រាបអំពើជួញដូរមនុស្ស ការកេងប្រវ័ញ្ចលើកម្លាំងពលកម្ម និងការធ្វើអាជីវកម្មផ្លូវភេទលើមនុស្ស (NPA-STSLS -2011-2013)ដែលត្រូវបានអនុម័តនៅថ្ងៃ ០៧ ខែវិច្ឆិកា ឆ្នាំ ២០១១ ដោយ **ឯកឧត្ដមឧបនាយករដ្ឋមន្ត្រី និងរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ស ខេង** ផែនការនេះ ផ្ដល់ឱកាសឱ្យនិយោជក និងវិស័យឯកជន ក្នុងការធ្វើសមាហរណកម្ម និងអនុវត្ត NPA-STSLS ស្របជាមួយនឹងផែនការ CAMFEBA-PAECL ជាពិសេសក្រុមសកម្មភាពក្នុងការលុបបំបាត់ពលកម្មកុមារ និងទម្រង់ធ្ងន់ធ្ងរបំផុតរបស់វា (ក្រុមសកម្មភាពលេខ ២.៤) និងការលើកកម្ពស់សុវត្ថិភាពកុមារក្នុងវិស័យទេសចរណ៍ (ក្រុមសកម្មភាពលេខ ២.៦) ដែលនឹងត្រូវផ្ដោតនៅក្នុងផែនការសកម្មភាពរបស់និយោជកនេះ។ ក្នុងការសម្របសម្រួល និងអនុវត្ត NPA-STSLS រាជរដ្ឋាភិបាលកម្ពុជាបានបង្កើតឡើងនូវគណៈកម្មការជាតិស្ដីពីការបង្ក្រាបអំពើជួញដូរមនុស្ស ការកេងប្រវ័ញ្ចកម្លាំងពលកម្ម និងការធ្វើអាជីវកម្មផ្លូវភេទលើមនុស្ស (NC) ដើម្បីសម្របសម្រួល អនុសារណៈយោគយល់កិច្ចព្រមព្រៀងពហុភាគី និងទ្វេភាគី ក៏ដូចជាលើកកម្ពស់យុទ្ធសាស្ត្រសម្របសម្រួលកិច្ចផ្ដួចផ្ដើម ដើម្បីបង្ក្រាបអំពើជួញដូរក្នុងប្រទេសកម្ពុជា។ គណៈកម្មការជាតិ (NC) នេះជាសញ្ញាមួយទៀត ដែលសបញ្ជាក់ពីការប្ដេជ្ញាចិត្តរបស់រាជរដ្ឋាភិបាលកម្ពុជាក្នុងការប្រឆាំងនឹងអំពើជួញដូរមនុស្ស ដែលរួមបញ្ចូលការជួញដូរកេងប្រវ័ញ្ចផ្លូវភេទមកលើកុមារ។

ស្របពេលជាមួយគ្នានេះវាគួរបញ្ជាក់ផងដែរថាគោលដៅនៃការអប់រំដើម្បីទាំងអស់គ្នា (EFA) ក៏ត្រូវបានកំណត់នៅក្នុងឆ្នាំ ២០១៥ ហើយគោលដៅនេះនឹងអនុវត្តយ៉ាងប្រសើររួមគ្នាជាមួយនឹងគោលដៅក្នុងការលុបបំបាត់ពលកម្មកុមារ ដែលមានចែងនៅក្នុង CMDG និងគោលដៅសកលដែលអនុម័តដោយ ILO។ ផ្ទុយទៅវិញវាទាមទារឱ្យមាននូវគោលដៅដែលមានរយៈពេលកំណត់មួយ ដើម្បីបង្កើតជាវិធីសាស្ត្រសម្រាប់វាស់វែងពីភាពរីកចម្រើនការសម្រេចគោលដៅទាំងនេះ។ ដោយយល់ឃើញថាមានដៃគូអភិវឌ្ឍន៍ និងភ្នាក់ងារអនុវត្តជាច្រើនធ្វើការក្នុងបញ្ហាពលកម្មកុមារ ដូចនេះវាពិតជាចាំបាច់ត្រូវជម្រុញឱ្យដៃគូរអភិវឌ្ឍន៍ និងភ្នាក់ងារអនុវត្តទាំងនោះសហការគ្នាជាដៃគូរសង្គម ក្នុងការអនុវត្តយុទ្ធសាស្ត្រផែនការសកម្មភាពរបស់ CAMFEBA ដើម្បីធានាថាការគាំទ្រទាំងនេះមានការប្រាស្រ័យទាក់ទងល្អ និងស្របទៅតាមផែនការសកម្មភាពថ្នាក់ជាតិ និងគោលដៅ គោលនយោបាយយុទ្ធសាស្ត្រផ្សេងៗទៀត។

តាមរយៈការផ្ដល់សច្ចាប័នលើអនុសញ្ញាលេខ ១៣៨ និង ១៨២ រាជរដ្ឋាភិបាលកម្ពុជាបានកំនត់នូវជំហានជាបន្តបន្ទាប់ ដើម្បីធានាឱ្យបាននូវការអនុវត្តទូទាំងប្រទេស។ ក្រៅពីការទទួលបានជំនួយគាំទ្រផ្នែកបច្ចេកទេស ពីអង្គការ ILO ក្នុងការកំណត់វិធីសាស្ត្រវាស់វែងដែលមានរយៈពេលកំណត់ សម្រាប់លុបបំបាត់ជាបន្ទាន់នូវទម្រង់ធ្ងន់ធ្ងរបំផុតនៃពលកម្មកុមារ និងការកាត់បន្ថយគ្រប់ទម្រង់ទាំងអស់នៃពលកម្មកុមារ រាជរដ្ឋាភិបាលក៏បានអនុវត្តនូវផែនការជាតិក្នុងការលុបបំបាត់ទម្រង់ធ្ងន់ធ្ងរនៃពលកម្មកុមារ (NPA WFCL) ក្នុងរយៈពេលប្រាំឆ្នាំ ចាប់ពី ឆ្នាំ ២០០៨ ដល់ ២០១២ ហើយនាពេលបច្ចុប្បន្ន ផែនការនេះកំពុងស្ថិតនៅក្នុងដំណើរការនៃការត្រួតពិនិត្យមើលឡើងវិញ និងបង្កើតឡើងដើម្បីដាក់ឱ្យអនុវត្តបន្ត ដើម្បីសម្រេចបានគោលដៅឆ្នាំ ២០១៦។ ម្យ៉ាងវិញទៀតបញ្ហាពលកម្មកុមារក៏ត្រូវបានដាក់បញ្ចូលទៅក្នុង ផែនការអាទិភាពមួយក្នុងផែនការយុទ្ធសាស្ត្ររបស់ក្រសួងការងារ និងបណ្ដុះបណ្ដាលវិជ្ជាជីវៈ ២០០៦-២០១០។ លើសពីនេះទៅទៀត ក្រសួងការងារ និងបណ្ដុះបណ្ដាលវិជ្ជាជីវៈបានចេញប្រកាស ឬបទបញ្ញត្តិរបស់រដ្ឋាភិបាលដើម្បីដោះស្រាយបញ្ហាពលកម្មកុមារនៅក្នុងទម្រង់ប្រកបដោយគ្រោះថ្នាក់ផងដែរ។

ក្រសួងក៏បានរៀបចំអនុគណៈកម្មាធិការថ្នាក់ជាតិស្តីពីពលកម្មកុមារឡើងវិញ និងបង្កើតឡើងនូវគណៈកម្មការពលកម្មកុមារខេត្ត ចំនួន ៧។ ក្រសួងបានពង្រឹងនូវសមត្ថភាព នាយកដ្ឋានការងារកុមារ និងមន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈខេត្ត ដើម្បីឆ្លើយតបនឹងបញ្ហាពលកម្មកុមារ។

### ១.៣.២. ការប្តេជ្ញាថ្នាក់ជាតិ និងថ្នាក់អន្តរជាតិ ក្នុងការលុបបំបាត់ពលកម្មកុមារ

រាជរដ្ឋាភិបាលកម្ពុជាបានផ្តល់សច្ចាប័ន និងអនុម័ត អនុសញ្ញាអង្គការសហប្រជាជាតិ និងអន្តរជាតិ និងបទបញ្ញត្តិជាតិសំខាន់ៗជាច្រើន ដែលឆ្លុះបញ្ចាំងពីការប្តេជ្ញាចិត្តផ្នែកច្បាប់ ក្នុងការប្រយុទ្ធប្រឆាំងពលកម្មកុមារ ដែលរួមបញ្ចូលការផ្តល់សច្ចាប័នលើ**អនុសញ្ញាអង្គការសហប្រជាជាតិស្តីពីសិទ្ធិកុមារ** នៅឆ្នាំ ១៩៩២ ការផ្តល់សច្ចាប័នលើ**អនុសញ្ញារបស់អង្គការ ILO លេខ ១៣៨** (ស្តីពីអាយុអប្បបរមាក្នុងការបម្រើការងារ) នៅក្នុងឆ្នាំ ១៩៩៩ និង**អនុសញ្ញាលេខ ១៨២** (ស្តីពីទម្រង់ធ្ងន់ធ្ងរបំផុតនៃពលកម្មកុមារ) នៅឆ្នាំ ២០០៥ ដែលរួមបញ្ចូលបទបញ្ញត្តិ ទាមទារឱ្យមានការការពារសិទ្ធិកុមារនៅក្នុង **រដ្ឋធម្មនុញ្ញ** ឆ្នាំ ១៩៩៣ បានកំណត់អាយុអប្បបរមា ១៥ឆ្នាំ សម្រាប់ការបម្រើការងារនៅក្នុង**ច្បាប់ការងាររបស់ប្រទេសកម្ពុជា**ការដាក់ចេញនូវប្រកាស ឬបទបញ្ញត្តិរបស់ក្រសួងចំនួន១១ ដែលកំណត់ពីលក្ខខណ្ឌការងារនៅក្នុងវិស័យផ្សេងៗដែលទាក់ទងពីការជួល បុគ្គលិក និងបានចងនូវលក្ខខណ្ឌជាក់លាក់នានាស្តីពីការជួលកុមារឱ្យធ្វើការ។ ក្នុងចំណោមប្រកាសចំនួន ១១ ប្រកាសនេះ មានប្រកាសចំនួន ៤ ដែលផ្តោតសំខាន់ទៅលើពលកម្មកុមារក្នុងវិស័យកសិកម្មលក្ខណៈគ្រួសារ ដែលមានការគាំទ្រពីអង្គការវីនរ៉ក់អន្តរជាតិ ការលើកកម្ពស់កុមារតាមរយៈគម្រោងសេវាអប់រំ។ រាជរដ្ឋាភិបាលកម្ពុជាក៏បានអនុម័ត និងដាក់ឱ្យអនុវត្តតាម**ការសម្រេចរបស់អង្គការអន្តរសភាASEAN** ដើម្បីបង្ការ និងលុបបំបាត់ទម្រង់ធ្ងន់ធ្ងរបំផុតនៃពលកម្មកុមារនៅឆ្នាំ ២០០៤ និងបង្កើត **នាយកដ្ឋានការងារកុមារ** ដែលផ្តោតសំខាន់លើការលុបបំបាត់ពលកម្មកុមារ។ កំណត់តួនាទីរបស់មន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈខេត្ត/ក្រុងទាំងអស់ ដើម្បីជំរុញការយកចិត្តទុកដាក់ ជាពិសេសលើការលុបបំបាត់ពលកម្មកុមារ ដោយមានការសហការពីភ្នាក់ងារពាក់ព័ន្ធទាំងអស់។

## ១.៤. ការប្តេជ្ញាចិត្តរបស់ CAMFEBA - និយោជក

CAMFEBA/សមាគមនិយោជក បានដើរតួយ៉ាងសំខាន់ក្នុងនាមជាសមាជិកត្រីភាគី ក្នុងការចូលរួមចំណែកកាត់បន្ថយពលកម្មកុមារនៅឆ្នាំ ២០១៦។ យុទ្ធសាស្ត្រដ៏សំខាន់របស់ CAMFEBA/សមាគមនិយោជក គឺការសហការជាមួយសមាជិករបស់ខ្លួន និងសហគមន៍និយោជកដ៏ទៃទៀត ដើម្បីសម្រេចឱ្យបាននូវភាពគ្មានពលកម្មកុមារនៅកន្លែងការងារ/ស្ថាប័ននានា។ CAMFEBA និងសមាគមនិយោជក គាំទ្រកិច្ចខិតខំប្រឹងប្រែងរបស់ប្រទេសកម្ពុជាក្នុងការផ្តល់សច្ចាប័ន និងការអនុវត្តអនុសញ្ញា ILO ១៨២ និងក្នុងការអនុម័តប្រកាសមួយចំនួនស្តីពីពលកម្មកុមារ ហើយនិងការអនុម័តលើ NPA-WFCL, 2008-2012 និងឧបករណ៍ច្បាប់ថ្នាក់ជាតិ និងអន្តរជាតិជាច្រើនផ្សេងទៀតក្នុងការប្រយុទ្ធប្រឆាំងពលកម្មកុមារ។ នេះគឺជាផ្នែកមួយនៃតួនាទីនិងការប្តេជ្ញាដ៏សកម្ម ដែលធ្វើឡើងដោយ CAMFEBA/សមាគមពាណិជ្ជកម្ម ក្នុងការលើកទឹកចិត្តឱ្យរដ្ឋសភា និងព្រឹទ្ធសភាចុះត្រួតពិនិត្យនៅតាមតំបន់គម្រោងពលកម្មកុមារដើម្បីឱ្យយល់កាន់តែច្បាស់ និងឱ្យតម្លៃក្នុងការយល់ព្រមទទួលនូវអនុសញ្ញា ILO លេខ ១៨២។

CAMFEBA/សមាគមរបស់សមាគមនិយោជក គឺជាភាគីយ៉ាងសំខាន់សម្រាប់ការអនុវត្តការងារទាំងអស់របស់ ILO ជាពិសេសការលុបបំបាត់ពលកម្មកុមារ ។ ក្រៅពីភាពជាសមាជិកដែលបង្កើតបានជារចនាសម្ព័ន្ធត្រីភាគី

របស់ ILO សហជីពក៏ជាដៃគូសង្គមរបស់ ILO ផងដែរ។ ដោយមានការសហការពី ILO IPEC CAMFEBA/សមាគមនិយោជក បានដើរតួយ៉ាងសំខាន់ក្នុងការកៀងគរមតិសាធារណៈប្រឆាំងនឹងពលកម្មកុមារ ហើយជាពិសេសនាំយកសារស្តីអំពីបញ្ហាពលកម្មកុមារដល់កន្លែងការងារ និងយកបញ្ហានៃការលុបបំបាត់ពលកម្មកុមារដាក់ជាបញ្ហាមួយដ៏សំខាន់នៅក្នុងរបៀបវារៈរបស់ CAMFEBA/អង្គការនិយោជកផងដែរ។

សិទ្ធិអំណាចរបស់CAMFEBA /សមាគមនិយោជកនៅក្នុងប្រទេសកម្ពុជា គឺការឈរជាអ្នកតំណាងឱ្យសម្លេង ការប្តេជ្ញាចិត្ត និងការអនុវត្តគោលនយោបាយរបស់និយោជកនៅថ្នាក់ជាតិ តំបន់ និងអន្តរជាតិ ដើម្បីចែករំលែកស្វែងរកជំនួយ និងការគាំទ្រលើការអនុវត្តគម្រោងជាក់លាក់សម្រាប់កាត់បន្ថយ និងលុបបំបាត់ពលកម្មកុមារ ឬការផ្តល់ផលប្រយោជន៍ដល់កុមារ តាមរយៈការតស៊ូមតិ និងចរចាជាមួយរដ្ឋាភិបាល សមាគមនិយោជក និងសង្គមស៊ីវិល ឱ្យមានការផ្លាស់ប្តូរគោលនយោបាយ និងឥរិយាបថ ដើម្បីចូលរួមចំណែកក្នុងការលុបបំបាត់ពលកម្មកុមារនៅក្នុងប្រទេសកម្ពុជា និងគាំទ្រការបង្កើតវេទិកាក្នុងការលុបបំបាត់ពលកម្មកុមារ និងការលុបបំបាត់ទម្រង់ធ្ងន់ធ្ងរបំផុតនៃពលកម្មកុមារជាបន្ទាន់ ដោយការកៀងគរ ពង្រឹង និងបង្កើនសមត្ថភាព CAMFEBA/សមាគមរបស់សមាគមនិយោជកនៅក្នុងប្រទេស ដើម្បីប្រយុទ្ធប្រឆាំងនឹងពលកម្មកុមារ។ CAMFEBA/សមាគមនិយោជកមួយចំនួនបានទទួលយកខស្តីពីការទប់ស្កាត់ពលកម្មកុមារ ហើយដាក់ចូលទៅក្នុងយុទ្ធសាស្ត្រនៃការចរចាអនុសញ្ញារួម ទំនួលខុសត្រូវសង្គម (CSR) របស់CAMFEBA/សមាគមនិយោជក។ ពួកគេធ្វើការតស៊ូមតិប្រឆាំងពលកម្មកុមារ តាមរយៈការរៀបចំទិវាអន្តរជាតិប្រឆាំងនឹងពលកម្មកុមារ ទិវាកុមារអន្តរជាតិ ការត្រួតពិនិត្យមើលពលកម្មកុមារ ការផ្តល់នូវជម្រើសសមរម្យក្នុងការបង្កើននូវការអប់រំកុមារ និងជីវភាពរបស់ក្រុមគ្រួសាររបស់ពួកគេ ការចែកចាយសំភារៈដូចជា ផ្ទាំងបដា បន្ទះស្អិត ខិត្តប័ណ្ណ និងកូនសៀវភៅតូចៗ ដោយផ្តោតសំខាន់លើការប្តេជ្ញាចិត្តរបស់ CAMFEBA/សមាជិកនិយោជក ប្រយុទ្ធប្រឆាំងនឹងពលកម្មកុមារ និងចែកចាយសំភារៈជូនអ្នកតំណាងសំខាន់ៗ និង CAMFEBA/សមាគមនិយោជកនៅក្នុងប្រទេសកម្ពុជា។

រចនាសម្ព័ន្ធរបស់ CAMFEBA ត្រូវបានភ្ជាប់នៅក្នុងឧបសម្ព័ន្ធ "ក" ។

## ១.៥. ការប្តេជ្ញាចិត្តរបស់សហជីព

សហជីពដើរតួយ៉ាងសំខាន់ ដូចគ្នាផងដែរទៅនឹង CAMFEBA ក្នុងការចូលរួមការលុបបំបាត់ពលកម្មកុមារនៅឆ្នាំ ២០១៦។ យុទ្ធសាស្ត្រដ៏សំខាន់របស់សហជីព គឺការសហការជាមួយសមាជិករបស់ពួកគេ និយោជក រដ្ឋាភិបាល និងអង្គការសង្គមស៊ីវិល ដើម្បីសម្រេចឱ្យបានថា គ្មានកុមារនៅកន្លែងការងារ/ស្ថាប័ន។ ចាប់តាំងពី ២០០៤ សហជីព និងសមាគមដែលជាសមាជិករបស់ពួកគេ បានចាត់វិធានការផ្សេងៗក្នុងការលុបបំបាត់ពលកម្មកុមារ ជាពិសេសទម្រង់ធ្ងន់ធ្ងរបំផុតរបស់វា។ គណៈកម្មាធិការអន្តរសហជីព ស្តីពីពលកម្មកុមារត្រូវបានបង្កើត ហើយបន្ទាប់មកត្រូវបានស្គាល់ថាជា **គណៈកម្មាធិការប្រឹក្សាគម្រោងសហជីពប្រឆាំងនឹងពលកម្មកុមារ**។

សិទ្ធអំណាចរបស់សហជីពនៅក្នុងប្រទេសកម្ពុជា គឺជាអ្នកតំណាងឱ្យសហជីពនៅថ្នាក់ជាតិ ថ្នាក់តំបន់ និងថ្នាក់អន្តរជាតិ ក្នុងការចែករំលែក និងស្វែងរកការគាំទ្រផ្នែកបច្ចេកទេស និងហិរញ្ញវត្ថុក្នុងការលុបបំបាត់ពលកម្មកុមារ ឬផ្តល់ផលប្រយោជន៍ឱ្យកុមារ និងកម្មករ។ សហជីពជាច្រើន បានបញ្ចូល ខស្តីពីការទប់ស្កាត់ពលកម្មកុមារនៅក្នុងការចរចាអនុសញ្ញារួមជាមួយនិយោជក។ **អង្គការសហជីពប្រយុទ្ធប្រឆាំងនឹងបញ្ហាពលកម្មកុមាររួមបញ្ចូល**ការចូលរួមរបស់មេដឹកនាំសហជីពក្នុងយុទ្ធនាការលើកកម្ពស់ការយល់ដឹងដល់សមាជិករបស់ខ្លួន ការបង្កើត

ផែនការសកម្មភាពរបស់សហជីពស្តីពីពលកម្មកុមារ ការបង្កើតវគ្គបណ្តុះបណ្តាល និងសំភារៈបណ្តុះបណ្តាល ដែលទាក់ទងនឹងពលកម្មកុមារ ការបង្កើតក្រមសីលធម៌របស់សហជីពស្តីពីពលកម្មកុមារ ការចូលរួមរបស់តំណាងសហជីពនៅក្នុងបណ្តាញសង្គមស៊ីវិលប្រឆាំងនឹងពលកម្មកុមារ ការបោះឆ្នោតជ្រើសរើសតំណាងរបស់ PACT ក៏ដូចជាប្រធានរបស់ CSNACL ការទប់ស្កាត់ ឬដកហូតកុមារលើសពី ៦០០ នាក់ពីទម្រង់ធ្ងន់ធ្ងរបំផុត តាមរយៈការអនុវត្តសកម្មភាពផ្ទាល់របស់ PACT ។ លើសពីនេះទៅទៀត សហជីព/ PACT ប្រឆាំងនឹងពលកម្មកុមារ ធ្វើការប្តេជ្ញាចិត្តយ៉ាងខ្លាំងក្នុងការគាំទ្រកិច្ចប្រឹងប្រែងរបស់ប្រទេសកម្ពុជាឆ្ពោះទៅកាន់ការផ្តល់សច្ចាប័ន និងការអនុវត្តអនុសញ្ញា ១៨២ និងការផ្តល់សច្ចាប័នដល់ប្រកាសស្តីពីពលកម្មកុមារ និងការអនុម័តក្របខ័ណ្ឌគោលនយោបាយជាតិ និងអន្តរជាតិ ក្របខ័ណ្ឌច្បាប់ និងអនុសញ្ញាអន្តរជាតិដែលទាក់ទងនឹងការលុបបំបាត់ពលកម្មកុមារ ។ល ។

## ១.៦. ការប្តេជ្ញាចិត្តរបស់បណ្តាញសង្គមស៊ីវិលប្រឆាំងនឹងពលកម្មកុមារ (SCNACL)

បណ្តាញសង្គមស៊ីវិលប្រឆាំងនឹងពលកម្មកុមារ (SCNACL) គឺជាសម្ព័ន្ធនៃអង្គការសង្គមស៊ីវិល (CSO) I/LNGOs គ្រូបង្រៀន វេជ្ជបណ្ឌិត សមាគមសាសនា បុគ្គលម្នាក់ៗ ។ល ។ ដែលប្តេជ្ញាចិត្តក្នុងការចូលរួមក្នុងការលុបបំបាត់ពលកម្មកុមារនៅក្នុងប្រទេសកម្ពុជា ។ ការបង្កើតបណ្តាញសង្គមស៊ីវិលប្រឆាំងនឹងពលកម្មកុមារ គឺជាវិធីសាស្ត្រក្នុងការដោះស្រាយចន្លោះប្រហោង និងផ្តល់ឱកាសសម្រាប់សមាគម និងអង្គការសង្គមស៊ីវិលមកជួបគ្នាក្នុងការសហការបង្កើតនូវវេទិកាដ៏ធំទូទាំងប្រទេសមួយ ដោយផ្តោតលើការលុបបំបាត់ពលកម្មកុមារនៅក្នុងប្រទេសកម្ពុជា ។ គោលដៅរបស់ SCNACL គឺចង់ឱ្យបណ្តាញនេះនឹងបន្តអនុវត្តជំហានបន្ថែមទៀត និងខិតខំបន្ថែម ដូចជាការពង្រីកសមាជិកភាពរបស់ខ្លួន ពិនិត្យមើលឡើងវិញ និងពង្រឹងរចនាសម្ព័ន្ធដឹកនាំសមត្ថភាពរបស់និយោជកក្នុងការតស៊ូមតិប្រឆាំងពលកម្មកុមារ និងលើកកម្ពស់ការយល់ដឹងអំពីពលកម្មកុមារ និងលើកកម្ពស់ការយល់ដឹងនិងចំណេះដឹងដល់សមាជិកសង្គមស៊ីវិលជាទូទៅស្តីពីពលកម្មកុមារនៅក្នុងអនុសញ្ញា ILO ទី ១៣៨ និង ១៨២ និងចូលរួមគាំទ្រដល់គោលដៅភ្លោះរបស់ RGC ក្នុងការបញ្ចប់ WFCL នៅឆ្នាំ២០១៦ ។

## ១.៧. យន្តការ

តាមរយៈការសហការក្នុងនាមជាដៃគូជាមួយរាជរដ្ឋាភិបាល និងដៃគូដទៃទៀត ដែលរួមមាន សហជីព អង្គការសង្គមស៊ីវិល និងដៃគូអភិវឌ្ឍន៍ CAMFEBA នឹងកំណត់យកបញ្ហាពលកម្មកុមារដាក់ជាបញ្ហាអាទិភាពក្នុងការដោះស្រាយ ។ យន្តការប្រឆាំងនឹងពលកម្មកុមារត្រូវបានបង្កើត ឡើងនៅគ្រប់កម្រិតនៅក្នុងជួររដ្ឋាភិបាល ។ CAMFEBA នឹងត្រូវបានណែនាំទៅកាន់គ្រប់កម្រិតទាំងអស់ និងធ្វើការស្នើសុំកិច្ចសហការដើម្បីគាំទ្រ និងធ្វើសមាហរណកម្មបញ្ហានានាហើយបង្ហាញពីការប្តេជ្ញាចិត្តរបស់ CAMFEBA/និយោជកនៅគ្រប់វេទិកា និងរបៀបវារៈរបស់ខ្លួន ។ CAMFEBA នឹងបន្តចូលរួមក្នុងយន្តការដែលមានស្រាប់នេះ ដែលត្រូវបានបង្កើតឡើងដោយ RGC ដែលមានដូចខាងក្រោម:

១. សភាពាណិជ្ជកម្មនៅថ្នាក់ជាតិ និងថ្នាក់ខេត្ត ជាបណ្តាញសមាគមវិស័យឯកជនៈ រាជរដ្ឋាភិបាលបានបង្កើតសភាពាណិជ្ជកម្ម (CC) នៅថ្នាក់ជាតិ និងថ្នាក់ខេត្ត ដើម្បីសម្របសម្រួលទៅដល់វិនិយោគិនដែលចង់មកវិនិយោគនៅក្នុងប្រទេសកម្ពុជា ។ CC បានត្រូវបានផ្តល់សិទ្ធិក្នុងការបង្កើតច្បាប់ពាណិជ្ជកម្ម ដែលវាជំនួយយ៉ាងសំខាន់នៅក្នុងការគាំទ្រលើការលុបបំបាត់ពលកម្មកុមារ ប្រសិនបើ CC បានយល់អំពីឥទ្ធិពលនៃការ

ជួលកុមារដែលឋិតនៅក្រោមអាយុបម្រើការងារ និងគុណវិបត្តិរបស់វាមកលើនិយោជិន និងសហគ្រិន។ លើសពីនេះទៅទៀតCC អាចក្លាយបណ្តាញមួយក្នុងការជួយគាំទ្រ ជាពិសេសការជួយជំរុញការលុបបំបាត់ពលកម្មកុមារនៅក្នុងប្រទេសកម្ពុជា។

២. គណៈកម្មាធិការថ្នាក់ជាតិស្តីពីការបង្ក្រាបអំពើជួញដូរ ការរត់ពន្ធ ការធ្វើអាជីវកម្ម ពលកម្មលើមនុស្ស និងការធ្វើអាជីវកម្មផ្លូវភេទ (STSLS): យន្តការនេះត្រូវបានបង្កើតនៅឆ្នាំ ២០១០ នៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ នៅ ២៤ ខេត្តក្នុងប្រទេសកម្ពុជា។ នៅថ្នាក់ជាតិ គណៈកម្មាធិការថ្នាក់ជាតិនេះត្រូវបានដឹកនាំដោយ ឧបនាយករដ្ឋមន្ត្រី និងរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ហើយលេខាធិការរបស់ NS ដឹកនាំដោយ រដ្ឋលេខាធិការក្រសួងមហាផ្ទៃ។ ដូចនៅថ្នាក់ជាតិផងដែរ គណៈកម្មាធិការថ្នាក់ខេត្តស្តីពីការបង្ក្រាបអំពើជួញដូរ ការរត់ពន្ធ ការធ្វើអាជីវកម្ម ពលកម្មលើមនុស្ស និងការធ្វើអាជីវកម្មផ្លូវភេទត្រូវបានដឹកនាំដោយអភិបាលខេត្ត ហើយនិងលេខាធិការគណៈកម្មាធិការខេត្ត (PCS) ដែលត្រូវបានដឹកនាំដោយ អភិបាលរងខេត្ត នៅក្នុងខេត្តនីមួយៗ។ NC និង PC មានបណ្តាញដ៏ធំ និងប្តេជ្ញាចិត្តក្នុងការប្រយុទ្ធប្រឆាំង នឹងអំពើជួញដូរ ការរត់ពន្ធ ការធ្វើអាជីវកម្ម ពលកម្មលើមនុស្ស និងការធ្វើអាជីវកម្មផ្លូវភេទ និង WFCL ដែលត្រូវបានចាត់ទុកថាផ្នែកមួយសំខាន់ៗ ផងដែរ។ យន្តការនេះត្រូវបានចូលរួមដោយមន្ត្រីរដ្ឋាភិបាល ជាន់ខ្ពស់ ភ្នាក់ងារUN I/LNGOs និង SCOs នៅគណៈកម្មាធិការថ្នាក់ជាតិ និងគណៈកម្មាធិការថ្នាក់ខេត្ត។ ដូច្នេះ វត្តមានរបស់វិស័យឯកជន ជាពិសេសសមាជិករបស់ខ្លួនក្នុងនាមជាសមាជិករបស់គណៈកម្មាធិការនេះ វាអាចក្លាយជាអ្នកដែលមានសក្តានុពលក្នុងការផ្តត់ផ្គង់ថវិកាឱ្យ CAMFEBA និងការចែករំលែកព័តិមានទាក់ទងនឹងបញ្ហាលុបបំបាត់ពលកម្មកុមារ។ បច្ចុប្បន្ននេះ *សមាគមភ្នាក់ងារជ្រើសរើសពលករកម្ពុជា (ACRA)* ក៏មានវត្តមាននៅក្នុងគណៈកម្មាធិការថ្នាក់ជាតិ ហើយបញ្ហាក្នុងការជ្រើសរើសបុគ្គលដែលរួមមាន កុមារក្រោមអាយុបម្រើការងារ (ពលកម្មកុមារ) ក៏នៅតែជាបញ្ហាចោទនៅក្នុងប្រទេសកម្ពុជា។

៣. ក្រុមប្រឹក្សាថ្នាក់ជាតិកម្ពុជាដើម្បីកុមារ (CNCC) និងក្រុមប្រឹក្សាខេត្ត/ក្រុងដើម្បីកុមារ (P/MCC): ក្រុមប្រឹក្សាថ្នាក់ជាតិកម្ពុជាដើម្បីកុមារ គឺជាភាគីរដ្ឋាភិបាលដែលមានទំនួលខុសត្រូវក្នុងការធានាឱ្យបាននូវការសម្របសម្រួលក្នុងការអនុវត្ត ការត្រួតពិនិត្យ និងការវាយតម្លៃគោលនយោបាយ និងកម្មវិធីដែលទាក់ទងនឹងការរស់រាន ការអភិវឌ្ឍន៍ ការការពារ និងការចូលរួមរបស់កុមារ ដើម្បីសុខុមាលភាពរបស់ពួកគេ។ **សម្តេចនាយករដ្ឋមន្ត្រី**ជាប្រធានកិត្តិយសនៃក្រុមប្រឹក្សានេះ។ **រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា** ជាប្រធាន *CNCC* ។ ក្រុមប្រឹក្សានេះត្រូវបានចូលរួមពីគ្រប់ក្រសួងនៅថ្នាក់ខេត្ត និងក្រុង។ នៅថ្នាក់ខេត្ត អភិបាលខេត្តជាប្រធាន និងនាយកដ្ឋានសង្គមកិច្ច អតីតយុទ្ធជន និងយុវនិតិសម្បទា គឺជាលេខាធិការរបស់ក្រុមប្រឹក្សា។ CNCC ផ្តល់យោបល់ទាក់ទងនឹងការបង្កើតគោលនយោបាយ និងការបង្កើតផែនការសកម្មភាពជាតិ និងដើរតួនាទីយ៉ាងសំខាន់ក្នុងការតស៊ូមតិស្តីពីសិទ្ធិកុមារ នៅថ្នាក់ជាតិ និងថ្នាក់អន្តរជាតិ និងរាយការណ៍ជាអចិន្ត្រៃយ៍ទៅរដ្ឋាភិបាល និងរាយការណ៍ស្តីពីភាពរីកចម្រើនស្ថានភាព សិទ្ធិកុមារនៅក្នុងប្រទេសកម្ពុជាជូនទៅអង្គការសហប្រជាជាតិ។

៤. អនុកម្មាធិការថ្នាក់ជាតិស្តីពីពលកម្មកុមារ និងទម្រង់ផ្សេងៗនៃការជួញដូរកេងប្រវ័ញ្ចកុមារ (NSC-CL) : (NSC-CL) ត្រូវដឹកនាំដោយក្រសួងការងារ និងបណ្តុះបណ្តាល។ NSC-CL គឺជាអង្គសម្របសម្រួលដ៏សំខាន់

សម្រាប់រាជរដ្ឋាភិបាលកម្ពុជា និយោជក កម្មករ និងសង្គមស៊ីវិល ស្តីពីការពិនិត្យមើលឡើងវិញលើច្បាប់ និងយុទ្ធសាស្ត្រ និងការអនុម័តកម្មវិធីនិងការចែករំលែកព័ត៌មាន ក្នុងការលុបបំបាត់ពលកម្មកុមារនៅក្នុងប្រទេសកម្ពុជា។ អនុកម្មាធិការនេះគឺជាតួអង្គដ៏សំខាន់នៅក្នុងប្រទេសកម្ពុជា។ ផ្ទុយទៅវិញNCS-CL ក៏ត្រូវពង្រឹងតួនាទីរបស់ខ្លួន និងគាំទ្រការពង្រីកសមត្ថភាពរបស់ខ្លួននៅខេត្តទាំង២៤ នៅប្រទេសកម្ពុជា។

៥. គណៈកម្មាធិការខេត្ត/ក្រុង ស្តីពីពលកម្មកុមារ និងទម្រង់ផ្សេងៗនៃការកេងប្រវ័ញ្ចកុមារៈ នៅថ្នាក់ខេត្ត MoLV / NSC-CL បានរៀបចំគណៈកម្មាធិការស្តីពីពលកម្មកុមារ និងទម្រង់ផ្សេងៗនៃការកេងប្រវ័ញ្ចកុមារ ដែលមានពាក្យកាត់ថា PCCL មានសមាជិកពីគ្រប់មន្ទីរតាមខេត្តទាំងអស់ សមាគមនិយោជក សហជីព ដៃគូអភិវឌ្ឍន៍ NGOs និង CSOs ។ល។ PCCL ត្រូវបានដឹកនាំដោយអភិបាលខេត្ត ហើយនាយកដ្ឋានការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈខេត្ត គឺជាលេខាធិការរបស់គណៈកម្មការស្តីពីពលកម្មកុមារនេះ។ PCCL គឺជាយន្តការដែលបានលើកឡើង ដើម្បីផ្សារភ្ជាប់ការងារជាមួយនឹងគណៈកម្មាធិការខេត្តស្តីពីពលកម្មកុមារដែលមានស្រាប់/គ្រោងនឹងបង្កើត ដែលរួមមានសភាពាណិជ្ជកម្មខេត្តចូលរួមជាមួយ។

ក្រុមប្រឹក្សាគណកម្មាធិការខេត្ត/ក្រុង (P/MCC) និងគណៈកម្មាធិការពលកម្មកុមារខេត្ត/ក្រុង និង (P/MCCL) ត្រូវបានពិនិត្យមើលឡើងវិញ ហើយP/MCCL គួរតែយកតាមមានរចនាសម្ព័ន្ធនៅថ្នាក់ខេត្ត ដែល NCS-CL ឋិតនៅក្រោម CNCC ដូចនេះ PCCL គួរតែឋិតនៅក្រោម P/MCC ។

៦. យន្តការតាមតំបន់ផ្សេងៗ ដូចជាក្រុមប្រឹក្សាខេត្តស្តីពីការការពារសិទ្ធិកុមារ ដែលមានភាពស្រដៀងគ្នានឹងក្រុមប្រឹក្សាស្រុក ដែលក្រុមប្រឹក្សាស្រុកដែលមានស្រាប់ស្តីពីការការពារសិទ្ធិកុមារ នឹងត្រូវបញ្ចូលគ្នាជាមួយគណៈកម្មាធិការពលកម្មកុមារស្រុក (DCCL) ហើយនៅថ្នាក់ឃុំ ក្រុមប្រឹក្សាឃុំបានចូលរួមចំណែកយ៉ាងសកម្ម និងផ្តោតសំខាន់លើបញ្ហាកុមារ និងស្ត្រី ដែលរួមមាន ការអប់រំ ការប្រឆាំងនឹងអំពើហិង្សាក្នុងគ្រួសារ និងសមភាពយេនឌ័រ។ នៅក្នុងឃុំចំនួន ១៦២៤ ឃុំនីមួយៗមាន មន្ត្រីបង្គោលមួយរូបពីក្រុមប្រឹក្សាឃុំ ដែលមានទំនួលខុសត្រូវលើកុមារ និងស្ត្រី CAMFEBA – PAECLនឹងត្រូវសហការជាមួយក្រសួងមហាផ្ទៃ ដែលដឹកនាំ និងគ្រប់គ្រងការងាររបស់ក្រុមប្រឹក្សាសហគមន៍ និងធ្វើការយ៉ាងជិតស្និទ្ធជាមួយដៃគូសង្គម ដូចជា MoLVT សហជីព និង NGO ក្នុងស្រុក ទាក់ទងនឹងការងារក្នុងវិស័យអប់រំ សុខភាព ការអភិវឌ្ឍសហគមន៍ សកម្មភាពស្វែងរកប្រាក់ចំណូល ការបណ្តុះបណ្តាលជំនាញ ការអភិវឌ្ឍជនបទ ទេសចរណ៍ បដិសណ្ឋារកិច្ច ។ល។ ក្នុងការចូលរួមចំណែកលុបបំបាត់ទម្រង់ធ្ងន់ធ្ងរបំផុតនៃពលកម្មកុមារដោយកំណត់គោលដៅនៅឆ្នាំ ២០១៥ និង ២០១៦។

# ២. ការវិភាគពលកម្មកុមារ និងទម្រង់ធ្ងន់ធ្ងររបស់វា និង ការឆ្លើយតបនៅក្នុងប្រទេសកម្ពុជា

## ២.១. ស្ថានភាពពលកម្មកុមារនៅក្នុងប្រទេសកម្ពុជា

ដោយទទួលបានប្រាក់កំរៃតិចតួចពីផលិតកម្មដើម្បីចិញ្ចឹមជីវិត ក្រុមគ្រួសារនីមួយៗបានខិតខំស្វែងរកមធ្យោបាយក្នុងការដោះស្រាយនឹងកង្វះម្ហូបអាហារ និងប្រាក់ចំណូល។ មធ្យោបាយមួយដែលក្រុមគ្រួសារទាំងនោះប្រើប្រាស់ជាញឹកញាប់ គឺការប្រើប្រាស់ពលកម្មកុមារ។ ការធ្វើចំណាកស្រុកតាមរដូវរបស់គ្រួសារកើតឡើង

នៅកំឡុងរដូវប្រាំង និងតាមរយៈការកើនឡើងនូវតម្រូវការពលកម្មនៅក្នុងផលិតកម្មដទៃទៀត ដូចជាការដាំដំណាំសម្រាប់នាំចេញ នៅក្នុងឧស្សាហកម្មធុនស្រាលដូចជា ឡឥដ្ឋ កសិដ្ឋានផលិតអំបិល ការនេសាទ និងការកែច្នៃត្រី ការងាររើសែង ការងារនៅតាមកំពង់ផែ និងព្រំដែន ការវាយថ្ម និងកាប់ឈើ ដែលកុមារធ្វើការ។ ការងារទាំងនេះ ធ្វើឡើងដោយ ការប្រមែប្រមូលកំលាំងពលកម្មដែលមាននៅក្នុងគ្រួសារ ជាការងារតាមរដូវកាល ដែលទទួល បានផ្តល់ប្រាក់ខែជាប្រយោល មានរយៈពេលខ្លី ហើយជាការងារដែលពោរពេញដោយគ្រោះថ្នាក់។

កុមារក៏ធ្វើការងារបម្រើការតាមផ្ទះ និងនៅក្នុងវិស័យសេវាកម្មក្នុងទីក្រុងដូចជា ភោជនីយដ្ឋាន ទេសចរណ៍ អាជីវកម្ម និងការងារសំណង់។ តំបន់ទីក្រុងដែលផ្តល់នូវឱកាសការងារមួយចំនួនទៀតក្នុងការស្វែងរកប្រាក់ចំណូលដូចជា ការងាររើសែង ការរើស ឬការទិញ និងការលក់ផលិតផលសំណល់ ដែលអាចយកមកកែច្នៃ និងការងារតាមដងវិថីផ្លូវដូចជា ជូតស្បែកជើង លក់កាសែត និងលក់ទំនិញតាមផ្លូវ។ កុមារត្រូវបានគេឃើញថាបានធ្វើចំណាកស្រុកឆ្លងប្រទេស ដើម្បីទៅធ្វើការនៅក្នុងវិស័យនេសាទ ការដាំដុះ និងការងារនៅតាមតំបន់ទីក្រុងនៃប្រទេសថៃ និងវៀតណាមជាដើម។ កុមារ និងស្ត្រីវ័យក្មេង កំពុងប្រឈមមុខយ៉ាងខ្លាំងទៅនឹងការជួញដូរកេងប្រវ័ញ្ចផ្លូវភេទ និងពលកម្ម ជាពិសេសនៅពេលធ្វើការចំណាកស្រុក ដោយខ្វះព័ត៌មាន និងការត្រៀមខ្លួនជាមុន។

ការអង្កេតពលកម្មកុមារនៅកម្ពុជា (CCLS) នៅឆ្នាំ ២០០១ គឺជា ឯកសារយោងដ៏ជាក់លាក់ស្តីពីពលកម្មកុមារនៅកម្ពុជា។ ការអង្កេតនេះបានរកឃើញថា មានកុមារបម្រើសកម្មភាពសេដ្ឋកិច្ចជាង ៥០% ដែលមានអាយុ ១០ឆ្នាំ។ នេះបង្ហាញថា កុមារស្ទើរតែ ១.៥ លាននាក់ បម្រើសកម្មភាពសេដ្ឋកិច្ច។ កុមារបម្រើសកម្មភាពសេដ្ឋកិច្ចប្រហែល ៧៥% ត្រូវបានរកឃើញថា ពួកគេបានធ្វើការងារតាមផ្ទះ និងការងារប្រហែល ៩០% គឺជាការងារមិនផ្តល់កម្រៃ។ការងារទាំងនេះត្រូវចំណាយពេលច្រើនប្រហែល ២២ ម៉ោងក្នុងមួយសប្តាហ៍ ហើយភាគច្រើននៃកុមារបម្រើការងារជួបប្រទះនឹងគ្រោះថ្នាក់ ដែលអាចធ្វើឱ្យពួកគេពិការ ឬមានជម្ងឺ។

គម្រោង ILO-IPEC ស្តីពីពលកម្មកុមារបានធ្វើការសិក្សាលើវិស័យចំនួន ៧ ក្នុងចំណោម ១៦ វិស័យនៃ WFCL ចាប់តាំងពីឆ្នាំ ២០០១ ដោយរួមបញ្ចូលពលកម្មកុមារនៅកសិដ្ឋានស្រែអំបិល ការដាំកៅស៊ូ ការផលិតឥដ្ឋ ការរើសែង ការបម្រើការងារតាមផ្ទះ និងការរើសអេតចាយ ឬសំរាម ដែលនេះ សបញ្ជាក់ពីគ្រោះថ្នាក់ដែលកុមារជួបប្រទះ។ លើសពីនេះទៅទៀត ការសិក្សាផ្សេងៗទៀតត្រូវបានធ្វើឡើងដោយ អង្គការអន្តរជាតិ ដូចជាបញ្ហាស្តីពីការធ្វើចំណាកស្រុក (IOM) ការសិក្សាពីការងារបម្រើការតាមផ្ទះ ដែលមានអង្គការមិត្តសំឡាញ់សិក្សាពីលើកុមាររស់នៅចិញ្ចើមផ្លូវ អង្គការវីនរ៉ក់អន្តរជាតិសិក្សាពីលើពលកម្មកុមារក្នុងវិស័យកសិកម្មបែបគ្រួសារ[៩] ហើយអង្គការទស្សនៈពិភពលោកកម្ពុជាសិក្សាពីពលកម្មកុមារនៅទីក្រុង ដែលទាំងនេះបង្ហាញពីទម្រង់ CCLS នៃកុមារបម្រើការងារ។

គម្រោងនៃការសិក្សាស្រាវជ្រាវលើការយល់ដឹងអំពីពលកម្មកុមារ បានស្រង់យកទិន្នន័យចំនួនកុមារនៅគ្រប់វិស័យនៃ WFCL ដោយប្រើប្រាស់ទិន្នន័យការអង្កេតសង្គម-សេដ្ឋកិច្ចកម្ពុជា (CSES)។ ចំនួននៃកុមារបម្រើការងារនៅក្នុងបញ្ជីជាតិស្តីអំពីការងារ បានប៉ាន់ប្រមាណថាមានកុមារប្រហែល ៣១៣ ២៦៤ ដែលមានអាយុពី ១០ ដល់ ១៧ កំពុងធ្វើការក្នុងទម្រង់ធ្ងន់ធ្ងរបំផុត។ ភាគច្រើននៃចំនួនកុមារទាំងនេះ ធ្វើការនៅក្នុងវិស័យនេសាទក្រៅប្រព័ន្ធ ការដាំដុះពាក់កណ្តាលឧស្សាហកម្ម និងការងារនៅក្នុងភោជនីយដ្ឋាន។ វិស័យសំខាន់ផ្សេងៗ

---

[៩] គម្រោងនេះត្រូវបានបញ្ចប់នៅឆ្នាំ ២០១១។

ទៀតមានដូចជា ការផលិតអំបិល ការលីសែង ការកែច្នៃផលិតសមុទ្រ ការរើសសំរាម ការងារបម្រើការតាមផ្ទះ ការផលិតឥដ្ឋ ការផលិតសំភារៈសិប្បកម្ម និងការលក់សំភារៈអនុស្សាវរីយ៍ និងសហគ្រាសពាក់ព័ន្ធនានា ការសុំទាន ការងារសំណង់ និងការធ្វើចំណាកស្រុក។ តំបន់គោលដៅ ដែលកុមារទៅធ្វើការគឺ នៅក្នុងទីប្រជុំជននៅតាមក្រុង តំបន់ពាណិជ្ជកម្មនៅជិតព្រំដែន និងខេត្តដែលផ្គត់ផ្គង់ទំនិញ និងសេវាកម្មដល់ទីក្រុង។ គ្រោះថ្នាក់ចំបងៗ ដែលកើតឡើងនៅកន្លែងការងារអាស្រ័យលើប្រភេទនៃទម្រង់ពលកម្មកុមារ ប៉ុន្តែ វាក៏ទាក់ទងនឹងការងារ ប្រើប្រាស់ពលកម្មខ្លាំង ភាពរងនូវកំដៅថ្ងៃ ស៊ីតុណ្ហភាពក្តៅខ្លាំង និងសារធាតុគីមីដែលប៉ះពាល់ដល់សុខភាពខ្លាំង ការកំណត់ម៉ោងសម្រាកច្បាស់លាស់ ការទទួលប្រាក់កំរៃ និងភាពងាយរងគ្រោះនូវការបំពានផ្នែកពាក្យសំដី និងរូបរាងកាយ ដោយនិយោជក និងភាពងាយរងគ្រោះនូវការកេងប្រវ័ញ្ចផ្លូវភេទ និងការជួញដូរ។

ILO-IPEC TBP គាំទ្រការអនុវត្ត NPA-WFCL របស់ RGC បញ្ចេក់ពីការសាយភាយនៃស្ថានភាពWFCL នៅក្នុងវិស័យទាំង ១៦ និងតំបន់ភូមិសាស្ត្រសំខាន់ចំនួន ៥ តាមរយៈការអង្កេតមើលនៅក្នុងខែឧសភា ឆ្នាំ ២០០៨ (ខេត្តសៀមរាប កែប កំពត ឃុំប៉ោយប៉ែតនៅក្នុងខេត្តបន្ទាយមានជ័យ ខេត្តកោះកុង)។ ការអង្កេតមើលនេះ រួមមានដៃគូពាក់ព័ន្ធសំខាន់ៗ តំណាងពីថ្នាក់ខេត្ត ស្រុក ឃុំ និងភូមិ ដើម្បីទទួលបានការប៉ាន់ស្មាននូវពលកម្ម កុមារនេះ។ នៅក្នុងការស្រាវជ្រាវនេះ ចម្លើយរបស់ឪពុកម្តាយ និងកុមារ ត្រូវបានយកមកវិភាគក្នុងការវាស់វែង ស្ថានភាពពលកម្មកុមារ និងលទ្ធផលបានប៉ាន់ស្មាន ថាមានកុមារចំនួន **២៧ ៨២៦ កំពុងធ្វើការនៅក្នុង WFCL** ។ ចំនួនទាំងនេះគឺជាគោលដៅដែលត្រូវដកហូតកុមារពី WFCL ។

លក្ខខណ្ឌដែលជះឥទ្ធិពលអាក្រក់ចំពោះកុមារកាន់តែធ្ងន់ធ្ងរនោះ គឺនៅពេលដែលមេគ្រួសារ ឬសមាជិក គ្រួសារពិការ ឬមានជម្ងឺ។ នៅឆ្នាំ១៩៩៩ មានការប៉ាន់ប្រមាណថាមាន ១.៥% នៃចំនួនប្រជាជនសរុបដែល ជាជនពិការ[១០] ។ បន្ទុះគ្រាប់មីន គឺជាមូលហេតុនៃពិការភាពនៅក្នុងចំណោមជនពិការចំនួន ១១%[11] ។ កត្តាមួយ ទៀត គឺមនុស្សភាគច្រើនដែលមានអាយុពី ១៥ ដល់ ៤៩ ឆ្នាំ កំពុងរស់នៅដោយមានផ្ទុកមេរោគ HIV/AIDS ដែលមាន ចំនួន១.៩% នៃចំនួនប្រជាជនសរុបនៅឆ្នាំ ២០០៣[១២] ទោះបីជាតួលេខនេះបានធ្លាក់ចុះមកដល់ 0.៩% នៅឆ្នាំ ២០០៧[១៣] យ៉ាងណាក្តី។ តម្រូវការរបស់ក្រុមគ្រួសារធំចំពោះកុមារ កើតឡើងជាក់ស្តែងនៅក្នុងគ្រួសារ ដែលស្ត្រីគឺជាមេគ្រួសារដែលមានភាគរយ ១៤% ដល់ ១៩% នៅតាមតំបន់ជនបទ[១៤] ។ លក្ខខណ្ឌដទៃទៀត ដែលនាំឱ្យកុមារធ្វើការ គឺការបំពាននៅក្នុងគ្រួសារ ការបំបោះបង់ចោល តម្រូវការក្នុងការសងបំណុលជំនួសគ្រួសារ ឬការរត់ចេញ ពីផ្ទះដើម្បីគេចចេញពីបញ្ហានៅក្នុងផ្ទះ។

## ២.២. បរិបទ និងមូលហេតុនៃពលកម្មកុមារ

មូលហេតុដែលកុមារធ្វើក្នុងប្រទេសកម្ពុជា គឺជាតម្រូវការបន្ទាន់ក្នុងការបន្ថែមលើប្រាក់ចំណូលគ្រួសារ។ លក្ខខណ្ឌការងារ ភាគច្រើនមិនបានផ្តល់នូវប្រាក់ចំណូលគ្រប់គ្រាន់ និងបង្កើតនូវឱកាសការងារសម្រាប់កម្លាំង ពលកម្មដែលកំពុងតែកើនឡើង។ កម្លាំងពលកម្មទាំងនេះកំពុងតែធ្វើដំណើរទៅតំបន់ដែលមានការរីកចំរើន ដូចជា មជ្ឈមណ្ឌលតាមក្រុង នៅតំបន់ដែលមានពាណិជ្ជកម្មឆ្លងប្រទេសខ្ពស់ នៅក្នុងសហគ្រាសដែលបម្រើឱ្យតម្រូវការ

---

[១០] វិទ្យាស្ថានជាតិស្ថិតិ/ក្រសួងផែនការ (NIS/MoP ), ២០០៤

[១១] ក្រុមប្រឹក្សាអភិវឌ្ឍសង្គម (CSD), ២០០២. គោលនយោបាយលុបបំបាត់ភាពក្រីក្រ ២០០៣-២០០៥. ភ្នំពេញ: CSD.ខែធ្នូ ឆ្នាំ ២០០២

[១២] មជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជម្ងឺអេដស៍ សើស្បែក និងកាមរោគ និង , ២០០៣.*HIV Sentinel Surveillance 2003: Result, Trend and Estimates* (ការត្រួតពិនិត្យមើលជម្ងឺអេដស៍លទ្ធផល និន្នាការ និង ការប៉ាន់ស្មាន). ភ្នំពេញ:MOH/CDC/FHI/USAID

[១៣] Lodish Emily.២០០៧. "ការបង្ហាញស្ថិតិខុសរបស់ NGO ស្តីពី HIV/AIDS "*Cambodia Daily*, ឆ្នាំទី ៣៧, លេខទី ៩១. ថ្ងៃទី ២០ ខែកញ្ញា ឆ្នាំ ២០០៧

[១៤] ការធ្វើជំរឿនប្រជាជនទូទាំងប្រទេសកម្ពុជា, ១៩៩៨ (វិទ្យាស្ថានជាតិស្ថិតិ/ក្រសួងផែនការ, ១៩៩៩), ធ្វើបច្ចុប្បន្នកម្មនៅក្នុង CDHS ឆ្នាំ ២០០៥

ទីក្រុង និងនៅតាមព្រំដែន។ ពលកម្មកុមារត្រូវបានរកឃើញនៅក្នុងវិស័យដែលផលិតផលទាក់ទងនឹងតម្រូវការរបស់មជ្ឈមណ្ឌលមានការរីកចំរើន ដូចជា វិស័យឡឥដ្ឋ ការផលិតអំបិល ការកែច្នៃត្រី ឬនៅការនាំចេញ និងការដាំដំណាំកៅស៊ូ និងដំនាំសម្រាប់នាំចេញ ការងារអូសរទេះ និងការនេសាទនៅជិតព្រំដែន។ កំលាំងពលកម្មដែលស្ថិតក្នុងភាពវ័យក្មេងមិនមានជំនាញ ខ្វះការអប់រំ និងខ្វះទំនាក់ទំនងបណ្តាញការងារ ហើយចុងបញ្ចប់នឹងធ្វើការក្នុងវិស័យដែលមិនគួរជាទីពេញចិត្តដូចជាការរើសអេតចាយ ការលីសែងតាមផ្សារ ការដើរលក់ឥវ៉ាន់តាមផ្លូវ ឬការដើរសុំទាន។ កុមារធ្វើការដែលមិនទទួលបានព័ត៌មានគ្រប់គ្រាន់ អស់សង្ឃឹម និងត្រូវបានគេបោកប្រាស់ ជាពិសេសកុមារី ចុងបញ្ចប់ត្រូវបានគេជួញដូរ និងកេងប្រវ័ញ្ចផ្លូវភេទ។

អាត្រាកំណើនប្រជាជនចំនួន ២% នឹងត្រូវបានរំពឹងទុកថាជាហានិភ័យយ៉ាងខ្លាំងសម្រាប់ការជ្រើសរើសការងារ។ យុវវ័យ និងមនុស្សពេញវ័យក្មេងនៅក្នុងទីផ្សារការងារ ត្រូវបានប៉ាន់ប្រមាណថាមានចំនួន ៣.១៥ លាននាក់។ លំនាំនៃចំនួនប្រជាជននេះ ជះឥទ្ធិពលទៅលើតំរូវការសាលារៀន ការងារ ដីធ្លី និងការស្នាក់នៅ។ ចំនួនប្រជាជនកើនឡើងយ៉ាងរហ័សនៅអត្រា ៣.៥ ភាគរយ (២០០១-២០០៥)។ គ្រួសារក្រីក្រដែលគ្មានមូលធន គ្មានជំនាញ និងគ្មានការអប់រំ នឹងត្រូវចូលបម្រើការងារប្រចាំថ្ងៃដែលប្រើកំលាំងជាមួយនឹងប្រាក់ចំនួលទាប ហើយបញ្ជូនកូនរបស់ពួកគេទៅបម្រើការងារនៅតំបន់ទីក្រុង។ កង្វះការទទួលបានការថែទាំសុខភាព កង្វះចំណីអាហារដែលមានជីវជាតិ និងគ្រោះថ្នាក់ដែលកើតចេញពីការងារប្រើកំលាំងខ្លាំង ហើយជម្ងឺធ្វើឱ្យប៉ះពាល់យ៉ាងខ្លាំងដល់គ្រួសារក្រីក្រ។ ការចំណាយសម្រាប់ការថែរក្សាសុខភាព គឺជាមូលហេតុយ៉ាងសំខាន់មួយក្នុងចំណោមមូលហេតុសំខាន់ៗដទៃទៀតដែលនាំឱ្យមានការលក់នូវទ្រព្យសម្បត្តិ ហើយបណ្តាលឱ្យបាត់បង់ដីធ្លី[១៥]។ តម្រូវក្នុងការសងបំណុល គឺជាកត្តាមួយដ៏សំខាន់ដែលត្រូវបានធ្លាក់ទៅលើកុមារីដែលត្រូវទៅបម្រើការងារនៅតាមផ្ទះ និងត្រូវបានកេងប្រវញ្ច័ផ្លូវភេទ[១៦]។

ស្រដៀងទៅនឹងប្រទេសភាគច្រើននៅក្នុងប្រទេសកម្ពុជា តួនាទីយេនឌ័រ និងការបែងចែកពលកម្មរវាងភេទទាំងពីរ ឆ្លុះបញ្ចាំងពីវប្បធម៌។ កុមារីត្រូវបានគិតថា ពួកគេឈានដល់ពេញវ័យនៅអាយុក្មេងជាងកុមារា។ លើសពីនេះទៅទៀត នេះត្រូវឆ្លុះបញ្ចាំងពីចំនួនកុមារបានចូលសាលារៀន។ នៅពេលដែលមានតុល្យភាពរវាងការចុះឈ្មោះចូលរៀនរវាងកុមារា និងកុមារីនៅក្នុងថ្នាក់កំរិតទាប កុមារីភាគច្រើននៅអាយុ ១១ បានបោះបង់ការសិក្សា។ នេះកើតឡើងពីព្រោះ សាលាបឋមសិក្សា ត្រូវបញ្ចប់នៅថ្នាក់ទី ៦ ហើយអនុវិទ្យាល័យចាប់ផ្តើមនៅថ្នាក់ទី ៧។ កុមារដែលមានអាយុ ១១ ឬ ១២ឆ្នាំ បញ្ចប់កំរិតបឋមសិក្សាហើយចាប់ផ្តើមចូលរៀននៅអនុវិទ្យាល័យ។

នៅពេលសាលាអនុវិទ្យាល័យ ស្ថិតនៅឆ្ងាយពីផ្ទះតាមភូមិ ពេលនោះសុវត្ថិភាពនៃការធ្វើដំណើរពីសាលាអនុវិទ្យាល័យមកភូមិ ឬទីប្រជុំជនគឺជាបញ្ហា ដែលបង្ខំឱ្យកុមារីជាទូទៅបោះបង់ចោលការសិក្សា បន្ទាប់ពីបញ្ចប់បឋមសិក្សា។ លើសពីនេះទៅទៀត ការរើសអើងភេទគឺជាមូលហេតុដែលនាំឱ្យមានអត្រាបោះបង់ការសិក្សាមាន

[១៥] ករណីសិក្សា របស់អង្គការសហប្រជាជាតិ ហាប៊ីថាត *(Munankami R. and Mann Chhoeurn (2004.)UN-Habitat Case Studies)* ស្តីពីៈ ការធ្វើការងារដើម្បីបណ្តាញកាន់តែប្រសើរក្នុងការភ្ជាប់រវាង ទីក្រុង និងជនបទ នៅក្នុងប្រទេសកម្ពុជា). ឆ្នាំទី ១០.លេខទី ៣. ខែកញ្ញា ឆ្នាំ ២០០៤ ទាញយកព័តិមានអំពីប្រជាជននៅក្នុងក្រុងភ្នំពេញ ដែលត្រូវប៉ាន់ស្មានថាចំនួន ១.២ លាននាក់ កំពុងកើនឡើង នៅអត្រា ៤-៥ភាគរយ ក្នុងមួយឆ្នាំ និង ៣៥ភាគរយ ចំពោះប្រជាជនដែលរស់នៅក្នុងតំបន់អាណាធិបតេយ្យ

[១៦] ការវាយតម្លៃភាពក្រីក្ររបស់កម្ពុជា ២០០៦ បាឱ្យដឹងថា ការចំណាយជាមធ្យម ២៤ដូល្លារ ក្នុងមួយឆ្នាំ និងចំណាយរបស់រដ្ឋាភិបាលលើ សុខភាពរបស់មនុស្សម្នាក់ តិចបំផុតមានចំនួន ៤.០៩ ដូល្លារ (ក្រសួងសុខាភិបាល ២០០៦)។

កម្រិតខ្ពស់នៅអាយុស្របពេលដែលកុមារបញ្ចប់ពីថ្នាក់បឋមសិក្សា ហើយបន្តទៅថ្នាក់មធ្យមសិក្សា។ គ្រួសារភាគច្រើននៅក្នុងប្រទេសកម្ពុជាតែងតែគិតថា ការអប់រំត្រឹមកំរិតបឋមសិក្សា លើសពីភាពគ្រប់គ្រាន់សម្រាប់កុមារី នៅពេលកុមារាត្រូវបានលើកទឹកចិត្តឱ្យបន្តការរៀនសូត្រ។

កម្ពុជា គឺជាប្រទេសមួយដែលមានអាត្រានៃការចូលរួមបម្រើការងាររបស់ស្ត្រីមានកំរិតខ្ពស់នៅក្នុងតំបន់ដែលមានចំនួន ៧៣.៦ ភាគរយ ក្នុងចំនោមមនុស្សដែលមានអាយុលើសពី ១៥ឆ្នាំ ។ ផ្ទុយទៅវិញ ស្ត្រីទទួលបានប្រាក់កម្រៃទាប បានតំណែងដែលគ្មានជំនាញ និងងាយរងគ្រោះនៅក្នុងទម្រង់ផ្សេងៗនៃការកេងប្រវ័ញ្ចនៅកន្លែងការងារ។ ប្រទេសកម្ពុជាបានក្លាយជាមជ្ឈមណ្ឌលសម្រាប់ផ្តល់ធនធាន ជាកន្លែងឆ្លងកាត់ និងគោលដៅនៃការជួញដូរស្ត្រី និងកុមារ។ តំបន់ដែលស្ត្រី និងកុមារចាញ់ប្រៀបគេ រួមមាន ប្រភេទ និងកម្រិតនៃការចូលរួមនៅក្នុងទីផ្សារការងារ ការបែងចែកធនធាននៅក្នុងគ្រួសារ ការអប់រំ និងសម្លេងឬអំណាចនៅក្នុងសហគមន៍ និងសង្គម[១៧] ។

ប្រទេសកម្ពុជាមានកម្រិតទាបជាងគេបំផុតនៃសមធមិយេនឌ័រនៅក្នុងអាស៊ី ដែលត្រូវបានវាស់ដោយសន្ទស្សន៍ការអភិវឌ្ឍយេនឌ័រ (0.៥៥៧) និងសន្ទស្សន៍ការលើកកម្ពស់យេនឌ័រ (0.៣៦៤)[១៨] ។ ឥរិយាបថ និងទំនៀមទម្លាប់សង្គមចាត់ទុកស្ត្រីមានឋានៈទាបជាងបុរស ដែលនាំឱ្យមានអសមធមិយេនឌ័រ ក្នុងការទទួលបានការអប់រំនិងកម្រិតក្នុងអនក្ខរកម្មរបស់ស្ត្រី កម្រិតយ៉ាងខ្ពស់នៃពលកម្មកុមារី អសមធមិយេនឌ័រក្នុងការទទួលបានសេវាកម្មសាធារណៈ និងភាពជាតំណាងរបស់ស្ត្រីទាប នៅក្នុងមុខតំណែងធ្វើការសម្រេចចិត្ត។ វប្បធម៌ដែលរារាំងស្ត្រីទៅសាលារៀន រារាំងកំណែទម្រង់។ នៅក្នុងស្ថានការណ៍ភាគច្រើន វាមិនមានសុវត្ថិភាពសម្រាប់កុមារីទៅសាលារៀនដែលមានចម្ងាយឆ្ងាយដោយគ្មានអ្នកទៅជាមួយ។

ភាពទន់ខ្សោយនៃប្រព័ន្ធអប់រំកម្ពុជា ត្រូវបានគេមើលឃើញយ៉ាងច្បាស់នៅក្នុងការសម្រេចបាននូវការអប់រំចំពោះកម្លាំងពលកម្មរបស់ប្រទេស។ មានត្រឹមតែមួយភាគបី នៃកម្លាំងពលកម្មបានបញ្ចប់ថ្នាក់បឋមសិក្សា (ថ្នាក់ទី៦) ឬខ្ពស់ជាងនេះ។ នេះបណ្តាលឱ្យឪពុកម្តាយមិនឱ្យតម្លៃលើការអប់រំ ជាពិសេសអ្នកក្រនៅតាមជនបទ។ លើសពីនេះទៅទៀត មានកង្វះខាតសាលារៀននៅគ្រប់កម្រិត ពីថ្នាក់ទី ១-៦។ សាលារៀនដែលមានគ្រប់កម្រិតនៅឆ្ងាយពីភូមិ ហើយគ្រួសារក្រីក្រភាគច្រើន មិនអាចមានលទ្ធភាពក្នុងការបញ្ជូនកូនទៅសាលារៀន[១៩] ។ នេះបណ្តាលឱ្យមានអត្រាបោះបង់ការសិក្សាខ្ពស់ ពី ១២-១៦% នៅខេត្តដែលក្រីក្របំផុត ហើយកុមារដែលបោះបង់ការសិក្សាត្រូវបានធ្លាក់លើពលកម្មកុមារ។

ការប៉ាន់ស្មានបឋម នៃទម្រង់ធ្ងន់ធ្ងរបំផុតនៃពលកម្មកុមារ ដែលបានបញ្ចូលក្នុងបញ្ជីថ្នាក់ជាតិ ត្រូវបានយកមកបង្ហាញនៅខាងក្រោម ដើម្បីបង្ហាញពីការបែងចែកទម្រង់ធ្ងន់ធ្ងរបំផុតនៃពលកម្មកុមារនៅតាមខេត្ត កុមារអាយុពី ១០-១៧ ឆ្នាំ នៅក្នុងកំឡុងឆ្នាំ ២០០៤-០៤។ សរុបបញ្ចូលគ្នា មានកុមារចំនួន ៣១៣ ២៦៣[២០] ដែលមានអាយុពី ១០-១៧ឆ្នាំ ធ្វើការនៅក្នុងទម្រង់ធ្ងន់ធ្ងរបំផុត។

---

[១៧] ILO IPEC ខែកក្កដា ២០០១: បញ្ជ្រាបយេនឌ័រចូលទៅក្នុងកម្មវិធីដែលផ្តោតសំខាន់លើពលកម្មកុមារ

[១៨] របាយការណ៍អភិវឌ្ឍធនធានមនុស្សរបស់ UNDP(២០០៣) ដែលត្រូវបានយកទិន្នន័យដោយ ចំណែកស្មើភាពសម្រាប់ស្ត្រី: ការវាយតម្លៃលើយេនឌ័រក្នុងប្រទេសកម្ពុជា) ADB, DFID, UNIFEM, UNDP និងធនាគារពិភពលោក ២០០៤

[១៩] បានដកស្រង់ទិន្នន័យ ការប៉ាន់ស្មានស្តីពី ការចំណាយរបស់ក្រុមគ្រួសារលើសាលាមត្តេយ្យ និងបឋមសិក្សា តិចជាង ១០ ដូល្លារ តិចជាង ១០០ដូល្លារ សម្រាប់ថ្នាក់ មធ្យមសិក្សា តិចជាង ២៥០ដូល្លារ សម្រាប់កម្រិតបច្ចេកទេស/បណ្តុះបណ្តាលជំនាញ និងតិចជាង ៥០០ ដូល្លារសម្រាប់ថ្នាក់មហាវិទ្យាល័យ។

[២០] របាយការណ៍របស់UCW ២០១០

**ការបែងចែកទម្រង់ធ្ងន់ធ្ងរបំផុតនៃពលកម្មកុមារតាមខេត្ត កុមារអាយុពី ១០-១៧ ឆ្នាំ នៅក្នុងកំឡុងឆ្នាំ ២០០៤-០៤**

| ខេត្ត | ចំនួនកុមារក្នុងទម្រង់ធ្ងន់ធ្ងរបំផុត | ភាគរយនៃកុមារស្ថិតនៅក្នុងទម្រង់ធ្ងន់ធ្ងរបំផុត ប្រៀបធៀបនឹងកុមារបម្រើសកម្មភាពសេដ្ឋកិច្ច | ចំនួនកុមារក្នុងទម្រង់ធ្ងន់ធ្ងរបំផុត គិតជាភាគរយក្នុងចំណោមកុមារទាំងអស់ |
|---|---|---|---|
| បន្ទាយមានជ័យ | ១៣ ៨២៧ | ១៩.៩ | ៩.១ |
| បាត់ដំបង | ៣០ ១៩៨ | ២៧.១ | ១៤.៨ |
| កំពង់ចាម | ៥៩ ៤៨០ | ២៥.០ | ១៤.៩ |
| កំពង់ឆ្នាំង | ២០ ២៩៧ | ៣២.៣ | ២០.៥ |
| កំពង់ស្ពឺ | ១៣ ១៩០ | ១២.៩ | ៨.៧ |
| កំពង់ធំ | ១៨ ៩៦០ | ២៣.៣ | ១២.៥ |
| កំពត | ១០ ២៤៣ | ២១.០ | ៨.០ |
| កណ្តាល | ៣៨ ៣៦៧ | ២៣.៣ | ១២.៨ |
| កោះកុង | ៨ ០១៨ | ៣៧.៩ | ២៤.៨ |
| ក្រចេះ | ២ ១៩៨ | ៩.៦ | ៣.៩ |
| ភ្នំពេញ | ១៧ ២៥១ | ៣២.៣ | ៧.៣ |
| ព្រះវិហារ | ២ ២៨៣ | ១០.៧ | ៨.១ |
| ព្រៃវែង | ២០ ៤៣៧ | ១១.៧ | ៨.៥ |
| ពោធិ៍សត្វ | ៦ ៥៥២ | ១១.២ | ៦.៩ |
| រតនគិរី | ៣១៧ | ២.៦ | ១.៣ |
| សៀមរាប | ១៥ ៣៥៤ | ១៤.១ | ៨.៦ |
| ក្រុងព្រះសីហនុ | ៣ ១០១ | ១៧.៣ | ៨.១ |
| ស្ទឹងត្រែង | ១ ៤១៧ | ១៣.២ | ៨.២ |
| ស្វាយរៀង | ៨ ៧៨៩ | ៩.២ | ៧.៣ |
| តាកែវ | ១៩ ០២០ | ១៤.៧ | ៩.៧ |
| ឧត្តរមានជ័យ | ១ ៣៣៣ | ១២.៨ | ៨.៤ |
| ក្រុងកែប | ១ ១៨០ | ១៧.៤ | ១៥.៣ |
| ក្រុងប៉ៃលិន | ១ ៤៩១ | ៧០.២ | ១២.៧ |
| **សរុប** | **៣១៣ ២៦៤** | **១៩.២** | **១០.៨** |

ធនធានៈ ការគណនារបស់ UCW ផ្អែកលើទិន្នន័យរបស់ CSES ២០០៣-០៤

# ៣. បញ្ហាជាអាទិភាពសម្រាប់ដោះស្រាយ

ការលុបបំបាត់ទម្រង់ធ្ងន់ធ្ងរបំផុតនៃពលកម្មកុមារ ទាមទារឱ្យមានវិធីសាស្ត្រនៃការការពារសង្គម ដើម្បីគាំទ្រទៅដល់វិស័យដែលក្រីក្រ និងងាយរងគ្រោះជាងគេ ហើយនិងជួយកុមារ និងក្រុមគ្រួសារ ក៏ដូចជាសហគមន៍របស់ពួកគេឱ្យចេះគ្រប់គ្រងហានិភ័យនានា។ យុទ្ធសាស្ត្រទូទៅគឺមិនមានការកំណត់លើវិស័យ ឬតំបន់ឡើយ

ប៉ុន្តែនឹងផ្តោតលើកញ្ចប់នៃការអភិវឌ្ឍន៍ទាំងមូល ដើម្បីដោះស្រាយឬសគល់នៃបញ្ហាពលកម្មកុមារ ហើយទន្ទឹមគ្នានេះដែរ ក៏គួរតែកត់សម្គាល់នូវតម្រូវការចាំបាច់នូវសកម្មភាពបន្ទាន់នានាលើវិស័យទាំងឡាយ ដែលបញ្ហាពលកម្មកុមារកើតមានទាំងវិស័យសេដ្ឋកិច្ចរៀបរយ និងមិនរៀបរយ ។

កិច្ចការអាទិភាពនៅក្នុងផែនការ CAMFEBA-PAECL គឺការចូលរួមចំណែកជួយគាំទ្រផែនការ NPA-WFCL របស់រាជរដ្ឋាភិបាលកម្ពុជា និងផែនទីបង្ហាញផ្លូវទាំង១២របស់កម្ពុជា ក៏ដូចជាយុទ្ធសាស្ត្រថ្នាក់ជាតិ ផ្សេងៗទៀតនៃក្របខ័ណ្ឌគោលនយោបាយដូចជា CMDGs EFA និង NSPS និងកម្មវិធីការងារសមរម្យរបស់អង្គការពលកម្មអន្តរជាតិ NPA-STSLS ។ល។

១. **ការគាំទ្រការបង្កើនសមត្ថភាពស្ថាប័នរបស់ *CAMFEBA* :** ដើម្បីដឹកនាំ សម្របសម្រួលលើប្រព័ន្ធតាមដាន និង ត្រួតពិនិត្យពលកម្មកុមារ និងរាយការណ៍អំពីការលុបបំបាត់ពលកម្មកុមារដើម្បីគាំទ្រគោលដៅភ្លោះនាឆ្នាំ ២០១៦ ។

២. **ការសិក្សា និងស្រាវជ្រាវ:** ការបន្តបង្កើតនូវវិធីសាស្ត្រ និងសមត្ថភាពដើម្បីធ្វើការស្រាវជ្រាវទាំងក្នុងវិស័យក្នុងប្រព័ន្ធ និងក្រៅប្រព័ន្ធស្តីអំពីបញ្ហាពលកម្មកុមារ ដោយផ្តោតលើទម្រង់ធ្ងន់ធ្ងរបំផុតរបស់វា និងធ្វើការគ្រប់គ្រងលើប្រព័ន្ធវិភាគលើផលវិបាក និងការវាយតម្លៃលើការធ្វើអន្តរាគមន៍ពលកម្មកុមារដោយរួមបញ្ចូលទាំងលទ្ធផលនៃភាពខុសគ្នារវាងក្មេងស្រី និងប្រុស និងភាពខុសគ្នានៃអាយុ និងការបង្កើនការរៀបចំឯកសារ និងការចែករំលែកនូវចំណេះដឹង ។

៣. **គោលនយោបាយ និងការអភិវឌ្ឍន៍ស្ថាប័ន:** បញ្ជ្រាបការព្រួយបារម្ភលើបញ្ហាពលកម្មកុមារទៅក្នុងគោលនយោបាយរបស់រដ្ឋ តាមរយៈក្រសួងពាក់ព័ន្ធទាំងអស់ ជាពិសេសសភាពាណិជ្ជកម្មកម្ពុជានៅកំរិតថ្នាក់ជាតិ និងក្រោមជាតិទូទាំងប្រទេសកម្ពុជា ។

៤. **ច្បាប់ និងការអនុវត្ត:** ការអនុវត្តច្បាប់ដែលមានស្រាប់ទាក់ទងនឹងពលកម្មកុមារ គឺនៅមានកំរិត និងមិនទាន់មានប្រសិទ្ធភាពនៅឡើយ ។ ក្រមការងារបានចែងថាកុមារត្រូវតែមានអាយុចាប់ពី ១៥ ឆ្នាំឡើងទៅ ទើបអាចអនុញ្ញាតឱ្យចូលធ្វើការបាន ។ ប៉ុន្តែកុមារជាច្រើនអាចទទួលបានការងារធ្វើនៅក្នុងអាយុ ១៥ ឆ្នាំ ដោយមិនមានភស្តុតាងណាមួយដើម្បីគាំទ្រទង្វើទាំងនេះ ។ ការដាក់ឱ្យអនុវត្តការណែនាំសម្រាប់ការងារស្រាល និងសកម្មភាពដែលមានលក្ខណៈគ្រោះថ្នាក់ក៏នៅមានភាពទន់ខ្សោយ ។ ភ្នាក់ងារមួយចំនួនធ្វើការជាមួយនិយោជកដើម្បីបង្កើនលក្ខខណ្ឌការងារឱ្យកាន់តែប្រសើរ ដើម្បីកាត់បន្ថយហានិភ័យ ប៉ុន្តែសកម្មភាពទាំងនេះនៅតែស្ថិតនៅក្នុងស្ថានភាពនៃការចរចា ។ មិនមានភស្តុតាងណាមួយ ឬវិធីសាស្ត្រនៃការដាក់ទោសទណ្ឌទៅលើនិយោជកដែលមិនគោរពតាមការណែនាំ និងបង្រៀនពីភ្នាក់ងារពាក់ព័ន្ធនានា ។

៥. **ជម្រុញឱ្យមានកម្មវិធី សុខភាពនិង សុវត្ថិភាពនៅកន្លែងការងារ *(OSH)* និង ប្រព័ន្ធត្រួតពិនិត្យពលកម្មកុមារ *(CLMS)*:** តាមរយៈការសហការជាមួយរាជរដ្ឋាភិបាលកម្ពុជា ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ បានបង្កើតប្រព័ន្ធដែលមានប្រសិទ្ធភាពមួយស្តីពី សុខភាពនិង សុវត្ថិភាពនៅកន្លែងការងារសម្រាប់កម្មករ ដោយរួមបញ្ចូលទាំងកុមារបម្រើការងារ (អាយុស្របច្បាប់សម្រាប់បម្រើ

ការងារ) ដែលទទួលបាននូវការគាំពារ និងទប់ស្កាត់ពីការគ្រោះថ្នាក់ដល់សុខភាពដូចជា រាងកាយ សារធាតុគីមី ជីវសាស្ត្រ និងបរិក្ខារសម្រាប់កុមារបម្រើការងារ ។ល។ ដែលមានអាយុពី ១៥ ទៅ ១៨ ឆ្នាំ។

៦. **ផ្លាស់ប្តូរ/ទប់ស្កាត់ និងការពារកុមារ និងបង្កើតជីវភាពរស់នៅរបស់កុមារ និងក្រុមគ្រួសាររបស់ពួកគេ:** CAMFEBA/សហគមនិយោជក នឹងធានាក្នុងការផ្លាស់ប្តូរ ដកហូតកុមារពីលក្ខខណ្ឌការងារប្រកបដោយគ្រោះថ្នាក់ ដោយផ្តល់ឱ្យពួកគេនូវជម្រើសដ៏សមស្របនានា ដូចជាផ្តល់នូវការបណ្តុះបណ្តាលជំនាញ លើកទឹកចិត្ត និងគាំទ្រឱ្យពួកគេបានចូលរៀននៅក្នុងសាលាអប់រំក្នុង និងក្រៅប្រព័ន្ធ ដោយផ្អែកលើចំណេះដឹងរបស់កុមារ។

៧. **ជម្រុញលើគោលការណ៍យុវជននិងការងារដើម្បីទទួលបានការងារសមរម្យ:** សហការជាមួយវិស័យមិនរៀបរយ ដែលជាកន្លែងកើតមានពលកម្មកុមារ និងបង្កើតយុទ្ធសាស្ត្រសមរម្យមួយសម្រាប់ផ្លាស់ប្តូរ ទប់ស្កាត់ ការពារ និងស្តារនីតិសម្បទា តាមរយៈជម្រើសសេវាកម្មល្អៗ (យន្តការ) - ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ សង្គមស៊ីវិល អង្គការក្រៅរដ្ឋាភិបាល CSNACL ។

៨. **កៀរគរថវិការ:** កៀរគរ និងប្រមូលធនធាននានាសម្រាប់សកម្មភាពក្នុងការលុបបំបាត់ទម្រង់ធ្ងន់ធ្ងរបំផុតនៃពលកម្មកុមារនៅក្នុងប្រទេសកម្ពុជានៅឆ្នាំ ២០១៦ និងចូលរួមការប្រឆាំងនឹងសកម្មភាពពលកម្មកុមារ (រួមបញ្ចូលការរាយការណ៍ និងការត្រួតពិនិត្យតាមដាន) បន្ទាប់ពីឆ្នាំ ២០១៦។

៩. **តស៊ូមតិ និងបញ្ជ្រាបទៅនិយោជកទាំងក្នុងវិស័យរៀបរយ និងមិនរៀបរយ:** កសាងសមត្ថភាព និងការបង្កើតបណ្តាញតស៊ូមតិ និងការកៀរគរការចូលរួមពីសង្គម និងយុទ្ធសាស្ត្របញ្ជ្រាបការយល់ដឹង ដើម្បីទប់ស្កាត់ ការពារ និងអប់រំលើផលវិបាកអវិជ្ជមាននៃពលកម្មកុមារទៅដល់សាធារណជន ជាពិសេសជំរុញលើកទឹកចិត្តនិយោជក និងសមាជិករបស់ពួកគេចូលរួមគាំទ្រក្នុងការលុបបំបាត់ពលកម្មកុមារក្នុងទម្រង់ធ្ងន់ធ្ងរបំផុត ដើម្បីជួយគាំទ្រគោលដៅភ្លោះរបស់រាជរដ្ឋាភិបាលកម្ពុជានៅឆ្នាំ ២០១៦។

វិស័យអាទិភាពក្នុងការទប់ស្កាត់ត្រូវបានកំណត់ដោយផ្អែកលើវិស័យ ឬតំបន់ និងការរៀបចំការចុះធ្វើអន្តរាគមន៍។ ស្របជាមួយនឹងការប្តេជ្ញាចិត្តថ្នាក់ជាតិ និងការខិតខំជាសកលក្នុងការចាត់វិធានការលុបបំបាត់ទម្រង់ធ្ងន់ធ្ងរបំផុតនៃពលកម្មកុមារ ដែលវាមិនអាចអត់ឱ្យបានសម្រាប់សិទ្ធិបឋមរបស់មនុស្ស: អំពើជួញដូរ និងអំពើពេស្យាចារលើកុមារ និងពលកម្មកុមារប្រកបដោយភាពគ្រោះថ្នាក់។ ទម្រង់ធ្ងន់ធ្ងរបំផុតនៃពលកម្មកុមារត្រូវបានដាក់ជាអាទិភាពនៅក្នុងផែនការសកម្មភាពជាតិស្តីអំពីការគាបសង្កត់ ការជួញដូរ ការកេងប្រវ័ញ្ចលើកម្លាំង និងផ្លូវភេទ (២០១១-២០១៣)។ វាត្រូវបានវិភាគយ៉ាងល្អិតល្អន់ក្នុងការដាក់បញ្ចូលពលកម្មកុមារ និងអំពើជួញដូរកេងប្រវ័ញ្ចផ្លូវភេទលើកុមារជាលទ្ធផលរំពឹងទុកជាអាទិភាពទៅក្នុងផែនការសកម្មភាព។ វាកំពុងត្រូវបានអនុវត្តតាមរយៈ NPA-STSLS (2011-2013)របស់រាជរដ្ឋាភិបាលកម្ពុជា។ តាមរយៈការផ្តោតលើវិស័យខាងលើ CAMFEBA - PAECL នឹងលើកយកវិស័យណាដែលពលកម្មកុមារកើតមាន ដោយរួមបញ្ចូល CSES ក៏ដូចជានៅគ្រប់ខេត្ត និងវិស័យ។

វិភាគលើការកំណត់លើផ្អែកដែលត្រូវការការធ្វើអន្តរាគមន៍បន្ថែមរបស់ CAMFEBA - PAECL នឹងការផ្តោតជាបឋមលើទម្រង់ធ្ងន់ធ្ងរបំផុតនៃពលកម្មកុមារ និងការរត់ពន្ធ និងការជួញដូរផ្លូវភេទទៅលើកុមារ ការ

ឆ្លងដែនអសុវត្ថិភាព និងការជំរុញយុវជនឱ្យទទួលបានការងារសមរម្យ។ CAMFEBA - PAECL នឹងអនុវត្ត សកម្មភាពស្របគ្នាជាមួយនឹងគោលនយោបាយនានារបស់រាជរដ្ឋាភិបាល និងយុទ្ធសាស្ត្រសម្រាប់លុបបំបាត់ទម្រង់ធ្ងន់ធ្ងរបំផុតនៃពលកម្មកុមារ ជាពិសេស NPA-WFCL-II, NSPS, ESP, EFA និង CMDGs ។

ហេតុដូចនេះ CAMFEBA - PAECL នឹងអនុវត្តលើតំបន់គោលដៅទាំង ២៤ខេត្តនៃព្រះរាជាណាចក្រកម្ពុជា និងតំបន់ដែលស្ថិតនៅ ក្រោមការធ្វើអន្តរាគមផ្ទាល់របស់ខ្លួនដែលបានកំណត់នូវចំនួនទម្រង់ធ្ងន់ធ្ងរបំផុតនៃពលកម្មកុមារ និងអាទិភាព និងថវិកាដែលមាន និងការគាំទ្រពីថ្នាក់ខេត្ត និងតំបន់។

# ៤. ផែនការសកម្មភាពរបស់ CAMFEBA ស្តីពីការលុបបំបាត់ពលកម្មកុមារក្នុងទម្រង់ធ្ងន់ធ្ងរបំផុតនៅក្នុងប្រទេសកម្ពុជា CAMFEBA - PAECL

## ៤.១. ទស្សនវិស័យ បេសកកម្ម និងគោលដៅ

### ៤.១.១. ទស្សនវិស័យ

កម្ពុជាជាប្រទេសដែលគ្មានពលកម្មកុមារ ជាកន្លែងដែលកុមាររស់នៅជាមួយភាពរីកចម្រើន និងការអភិវឌ្ឍន៍លូតលាស់ពេញលេញប្រកបដោយភាពសុខដុម ។

### ៤.១.២. បេសកកម្ម

CAMFEBA ប្តេជ្ញាចិត្តក្នុងការសម្រេចបាននូវទស្សនវិស័យរបស់ខ្លួនតាមរយៈការសហការ និងសម្របសម្រួលយ៉ាងជិតស្និទ្ធ ការកៀងគរធនធានពីសមាជិករបស់ខ្លួន រាជរដ្ឋាភិបាលកម្ពុជា សហជីព ភ្នាក់ងារសហប្រជាជាតិ ដៃគូអភិវឌ្ឍន៍ អង្គការសង្គមស៊ីវិល ។ល។ ដើម្បីធានាថា កម្ពុជាជាប្រទេសដែលគ្មានពលកម្មកុមារ។

### ៤.១.៣. គោលដៅ

CAMFEBA មានគោលបំណងក្នុងការពង្រឹងយន្តការ បង្កើនសមត្ថភាព ជំរុញការចូលរួមពីវិស័យរៀបរយ និងវិស័យមិនរៀបរយ និងការអភិវឌ្ឍន៍ដើម្បីចូលរួមគាំទ្រគោលដៅភ្លោះរបស់រាជរដ្ឋាភិបាលកម្ពុជា ក៏ដូចជាគោលដៅជាតិក្នុងការកាត់បន្ថយពលកម្មកុមារនៅឆ្នាំ ២០១៥ និងគោលដៅសកលរបស់អង្គការពលកម្មអន្តរជាតិ (ILO) ក្នុងការបញ្ចប់ទម្រង់ធ្ងន់ធ្ងរបំផុតនៃពលកម្មកុមារឱ្យអស់នៅក្នុងប្រទេសកម្ពុជានៅឆ្នាំ ២០១៦។

## ៤.២. គោលបំណង/គោលដៅ:

១. ដើម្បីដោះស្រាយនូវចន្លោះខ្វះខាតនៃសមត្ថភាពរបស់និយោជក ក្នុងការអនុវត្តយុទ្ធសាស្ត្រដើម្បីបញ្ចប់ទម្រង់ធ្ងន់ធ្ងរបំផុតនៃពលកម្មកុមារនាឆ្នាំ ២០១៦ ដោយរួមបញ្ចូលទាំងសុវត្ថិភាពរបស់កុមារក្នុងវិស័យទេសចរណ៍ និងការធ្វើអន្តោប្រវេសន៍ប្រកបដោយសុវត្ថិភាព។

២. ដើម្បីជំរុញកិច្ចសហការប្រកបដោយប្រសិទ្ធភាពរបស់សមាគមនិយោជក និងដៃគូរបស់ពួកគេ ជាពិសេសសហជីព និងវិស័យឯកជនដើម្បីជំរុញការគោរព/អនុវត្តតាមនូវក្របខណ្ឌបទបញ្ញត្តិគោលនយោបាយជាតិ និងអនុសញ្ញាអន្តរជាតិ ដូចជា ច្បាប់ការងារ ប្រកាស អនុសញ្ញាលេខ ១៣៨ ១៨២ UNCRC ។ល។ ប្រកបដោយប្រសិទ្ធភាព ដើម្បីចូលរួមគាំទ្រគោលដៅភ្លោះរបស់រាជរដ្ឋាភិបាលកម្ពុជាក្នុងការបញ្ចប់ទម្រង់ធ្ងន់ធ្ងរបំផុតនៃពលកម្មកុមារឱ្យអស់នៅក្នុងប្រទេសកម្ពុជានៅឆ្នាំ ២០១៦។

៣. ដើម្បីបង្កើតយុទ្ធសាស្ត្រនៃការចុះធ្វើអន្តរាគមន៍ដោយផ្ទាល់ទៅលើការ ដកហូត ទប់ស្កាត់ ការពារ និង ស្តារនីតិសម្បទា និងជំរុញឱ្យមានការងារសម្រាប់យុវជនដើម្បីទទួលបានការងារសមរម្យ សម្រាប់ជាវិធានការប្រកបដោយប្រសិទ្ធភាពក្នុងការលុបបំបាត់ទម្រង់ធ្ងន់ធ្ងរបំផុតនៃពលកម្មកុមារ ដើម្បីចូលរួមគាំទ្រគោលដៅភ្លោះរបស់រាជរដ្ឋាភិបាលកម្ពុជានៅឆ្នាំ ២០១៦។

៤. ដើម្បីបង្កើតយុទ្ធនាការតស៊ូមតិ និងការយល់ដឹងស្តីពីការលុបបំបាត់ពលកម្មកុមារ ជាពិសេសនៅក្នុងការលុបបំបាត់ទម្រង់ធ្ងន់ធ្ងរបំផុតនៃពលកម្មកុមារ ទៅដល់សាធារណជន និយោជក កម្មករ ភ្នាក់ងារម្ចាស់ជំនួយ ។ល។ ដើម្បីបង្ហាញពីផលវិបាកជាអវិជ្ជមានលើធនធានមនុស្ស សេដ្ឋកិច្ច និងបរិយាកាសអភិវឌ្ឍសង្គម។

៥. ដើម្បីកៀរគរ និងបញ្ចូលធនធាននានាសម្រាប់សកម្មភាពនានាក្នុងការលុបបំបាត់ទម្រង់ធ្ងន់ធ្ងរបំផុតនៃពលកម្មកុមារនៅក្នុងប្រទេសកម្ពុជានាឆ្នាំ ២០១៦ និងធានានូវសកម្មភាពប្រឆាំងនូវពលកម្មកុមារ (រួមបញ្ចូលនូវការរាយការណ៍ និងការតាមដានត្រួតពិនិត្យ) បន្ទាប់ពីឆ្នាំ ២០១៦។

## ៤.៣. លទ្ធផលរំពឹងទុកចំបងៗ

១. CAMFEBA នឹងអាចមានសម្ថភាពក្នុងការដោះស្រាយនូវចន្លោះខ្វះខាតនៃសមត្ថភាពរបស់និយោជកក្នុងការអនុវត្តយុទ្ធសាស្ត្រដើម្បីបញ្ចប់ទម្រង់ធ្ងន់ធ្ងរបំផុតនៃពលកម្មកុមារនាឆ្នាំ ២០១៦ ដោយរួមបញ្ចូលទាំងសុវត្ថិភាពរបស់កុមារក្នុងវិស័យ ទេសចរណ៍ និងការធ្វើអន្តោប្រវេសន៍ប្រកបដោយសុវត្ថិភាព។

២. CAMFEBA នឹងអាចមានសមត្ថភាពក្នុងការជំរុញកិច្ចសហការប្រកបដោយប្រសិទ្ធភាពរបស់សមាគមនិយោជក និងដៃគូរបស់ពួកគេ ជាពិសេសសហជីព និងវិស័យឯកជនដើម្បីជំរុញការគោរព/អនុវត្តតាមនូវក្របខណ្ឌបទបញ្ញត្តិគោលនយោបាយជាតិ និងអនុសញ្ញាអន្តរជាតិ ដូចជា ច្បាប់ការងារ ប្រកាស អនុសញ្ញាលេខ ១៣៨ ១៨២ UNCRC ។ល។ ប្រកបដោយប្រសិទ្ធភាព ដើម្បីចូលរួមគាំទ្រគោលដៅភ្លោះរបស់រាជរដ្ឋាភិបាលកម្ពុជាក្នុងការបញ្ចប់ ទម្រង់ធ្ងន់ធ្ងរបំផុតនៃពលកម្មកុមារឱ្យអស់នៅក្នុងប្រទេសកម្ពុជានៅឆ្នាំ ២០១៦។

៣. CAMFEBA នឹងអាចមានសម្ថភាពក្នុងការបង្កើតយុទ្ធសាស្ត្រនៃការចុះធ្វើអន្តរាគមដោយផ្ទាល់ទៅលើការដកហូត ទប់ស្កាត់ ការពារ និងស្តារ នីតិសម្បទា និងជំរុញឱ្យមានការងារសម្រាប់យុវជនដើម្បីទទួលបានការងារសមរម្យ សម្រាប់ជាវិធានការប្រកបដោយប្រសិទ្ធភាពក្នុងការលុបបំបាត់ទម្រង់ធ្ងន់ធ្ងរបំផុតនៃពលកម្មកុមារ ដើម្បីចូលរួមគាំទ្រគោលដៅភ្លោះរបស់រាជរដ្ឋាភិបាលកម្ពុជានៅឆ្នាំ ២០១៦។

៤. CAMFEBA នឹងអាចមានសម្ថភាពក្នុងការបង្កើតយុទ្ធនាការតស៊ូមតិ និងការយល់ដឹងស្តីពីការលុបបំបាត់ពលកម្មកុមារ ជាពិសេសនៅក្នុងការលុបបំបាត់ទម្រង់ធ្ងន់ធ្ងរបំផុតនៃពលកម្មកុមារ ទៅដល់សាធារណជន និយោជក កម្មករ ភ្នាក់ងារម្ចាស់ ជំនួយ ។ល។ ដើម្បីបង្ហាញពីផលវិបាកជាអវិជ្ជមានលើធនធានមនុស្ស សេដ្ឋកិច្ច និងបរិយាកាសអភិវឌ្ឍសង្គម។

៥. CAMFEBA និងសមាគមនិយោជករបស់ខ្លួន នឹងអាចត្រួតពិនិត្យបង្កើតផែនការសកម្មភាពរបស់ខ្លួនដើម្បីដោះស្រាយបញ្ហាពលកម្មកុមារ និងទម្រង់ធ្ងន់ធ្ងរបំផុតរបស់វានៅកន្លែងការងារ/គ្រឹះស្ថាន។

៦. CAMFEBA នឹងអាចមានសម្ថភាពក្នុងការកៀងគរ និងបញ្ចូលធនធាននានាសម្រាប់សកម្មភាពនានាក្នុងការលុបបំបាត់ទម្រង់ធ្ងន់ធ្ងរបំផុតនៃពលកម្មកុមារនៅក្នុងប្រទេសកម្ពុជានាឆ្នាំ ២០១៦ និងធានានូវសកម្មភាពប្រឆាំងនូវពលកម្មកុមារ (រួមបញ្ចូលនូវការរាយការណ៍ និងការតាមដានត្រួតពិនិត្យ) បន្ទាប់ពីឆ្នាំ ២០១៦។

៧. CAMFEA នឹងអាចគាំទ្រការអនុវត្តPAECL ដើម្បីឆ្ពោះទៅសម្រេចឱ្យបាននូវគោលដៅភ្លោះរបស់រដ្ឋាភិបាលកម្ពុជានាឆ្នាំ ២០១៥ និង២០១៦ និងមាននិរន្តរភាពសម្រាប់ដំណើរការក្នុងរយៈពេលវែង។

## ៤.៤. យុទ្ធសាស្ត្ររបស់ CAMFEBA-PAECL (2012-2016)

ផែនការសកម្មភាពស្តីពីការលុបបំបាត់ទម្រង់ធ្ងន់ធ្ងរបំផុតនៃពលកម្មកុមារ គឺពឹងផ្អែកទៅលើការយល់ដឹងអំពីផលប្រយោជន៍ និងគោលដៅអាជីវកម្មនៅក្នុងបរិបទប្រទេសកម្ពុជា និងផ្អែកទៅលើ វិធីដែលសហព័ន្ធនិយោជក និងសមាគមពាណិជ្ជកម្មកម្ពុជា (CAMFEBA) និង សហគមន៍/សមាគមនិយោជកអាចចូលរួមចំណែកក្នុងការលុបបំបាត់ទម្រង់ធ្ងន់ធ្ងរបំផុតនៃពលកម្មកុមារនៅក្នុងប្រទេសកម្ពុជា ជាពិសេសរួមចំណែកក្នុងការសម្រេចឱ្យបាននូវគោលដៅភ្លោះរបស់ប្រទេសកម្ពុជាស្តីពីពលកម្មកុមារ ដែលវាជាផ្នែកមួយនៃការប្តេជ្ញាចិត្តរបស់ពួកគេទៅលើទំនួលខុសត្រូវសង្គម។

CAMFEBA បានពង្រឹងសមត្ថភាពរបស់ខ្លួនយ៉ាងខ្លាំង តាមរយៈការសហការជាមួយ ILO IPEC រាជរដ្ឋាភិបាលកម្ពុជា និងសហជីព ដៃគូអភិវឌ្ឍន៍ផ្សេងៗទៀត ជាពិសេសវិស័យឯកជន ដែលរួមបញ្ចូលសមាគមសណ្ឋាគារនៅក្នុងប្រទេស ក្នុងការប្រយុទ្ធប្រឆាំងទម្រង់ធ្ងន់ធ្ងរបំផុតនៃពលកម្មកុមារ ដែលរួមបញ្ចូលបញ្ហានៃការធ្វើអន្តោប្រវេសន៍ប្រកបដោយមានសុវត្ថិភាពរបស់យុវវ័យសម្រាប់ការងារសមរម្យ សុវត្ថិភាពកុមារក្នុងវិស័យទេសចរណ៍ និងការបង្ការពីការជួញដូរកេងប្រវ័ញ្ចផ្លូវភេទមកលើកុមារ (CSEC) នៅក្នុងប្រទេស។

ដូច្នេះ មូលហេតុក្នុងការបង្កើតនូវផែនការសកម្មភាពរបស់ CAMFEBA ក្នុងការលុបបំបាត់ទម្រង់ធ្ងន់ធ្ងរបំផុតនៃពលកម្មកុមារ គឺដើម្បីយកវាធ្វើជាផែនទីបង្ហាញផ្លូវសម្រាប់ CAMFEBA និងដើម្បីបង្កើតជាលទ្ធផល និងបទពិសោធន៍ ពីការសហការជាដៃគូជាមួយ រដ្ឋាភិបាល ភ្នាក់ងារអង្គការសហប្រជាជាតិ សហជីព អង្គការសង្គមស៊ីវិលក្នុង និងក្រៅប្រទេស និងសមាគមនិយោជក ដើម្បីចូលរួមគាំទ្រសម្រេចឱ្យបាននូវគោលដៅភ្លោះរបស់ប្រទេសកម្ពុជា ក្នុងការបញ្ចប់នូវទម្រង់ធ្ងន់ធ្ងរបំផុតនៃពលកម្មកុមារនៅក្នុងប្រទេសកម្ពុជានៅក្នុងឆ្នាំ ២០១៦។ ទាំងនេះនឹងរួមបញ្ចូលសកម្មភាពប្រយុទ្ធប្រឆាំងពលកម្មកុមារ តាមរយៈការធានាឱ្យបាននូវការសហការគាំទ្រជាដៃគូក្នុងការលុបបំបាត់ពលកម្មកុមារ ការកៀងគរនិយោជក និងអង្គភាពអាជីវកម្មរបស់ពួកគេ ដើម្បីឆ្ពោះទៅកាន់ការលុបបំបាត់ពលកម្មកុមារនៅក្នុងប្រទេស ដោយផ្តោតសំខាន់ទៅលើការសហការយ៉ាងជិតស្និទ្ធ ក្នុងការលុបបំបាត់ជាបន្ទាន់នូវទម្រង់ធ្ងន់ធ្ងរបំផុតនៃពលកម្មកុមារ តាមរយៈការលើកទឹកចិត្តនិយោជកឱ្យឈប់ជួលកុមារដែលមិនទាន់គ្រប់អាយុបម្រើការងារ និងអ្នកធ្វើការទាក់ទងនឹងពលកម្មកុមារ ការសហការជាមួយភ្នាក់ងារដៃគូអភិវឌ្ឍន៍ និងអ្នកទិញ។ល។ និងផ្សព្វផ្សាយដល់កម្មករនៅតាមវិស័យកាត់ដេរ ដើម្បីឱ្យពួកគេបានផ្សព្វផ្សាយបន្តដល់សហគមន៍កាន់តែច្រើនទៀតនៅក្នុងប្រទេសកម្ពុជា ជាពិសេសនៅក្នុងតំបន់ជនបទ។

ផែនការសកម្មភាពនេះ នឹងកសាងសមត្ថភាពរបស់ CAMFEBA និងម្ចាស់រោងចក្រកាត់ដេរ និងកម្មកររបស់ពួកគេ ដើម្បីផ្សព្វផ្សាយឱ្យកាន់តែទូលំទូលាយនូវសារ និងគំនិតស្តីពីការលុបបំបាត់ពលកម្មកុមារ ផលវិបាកនៃទម្រង់ធ្ងន់ធ្ងរបំផុតនៃពលកម្មកុមារមកលើកុមារ និងអនាគតរបស់ពួកគេ ការធ្វើអន្តោប្រវេសន៍ដោយមាន

សុវត្ថិភាពសម្រាប់ការងារសមរម្យរបស់យុវជន។ ផែនការនេះនឹងផ្តោតសំខាន់ទៅលើការលើកកម្ពស់ការយល់ដឹង ការបញ្ច្រាប ការតស៊ូមតិ និងការកៀងគរកម្មករនិងម្ចាស់រោងចក្រប្រឆាំងនឹងពលកម្មកុមារ ដោយធានាថា ការអប់រំកុមារ ត្រូវបានចាត់ទុកថាជាធាតុមួយដ៏សំខាន់ ក្នុងការអភិវឌ្ឍន៍សេដ្ឋកិច្ចរយៈពេលវែងរបស់ប្រទេសកម្ពុជា និងក្នុងការលុបបំបាត់ពលកម្មកុមារ ដែលចូលរួមចំណែកសម្រេចបាននូវគោលដៅភ្លោះរបស់រាជរដ្ឋាភិបាលកម្ពុជានៅឆ្នាំ ២០១៦។

ផែនការសកម្មភាពរបស់ CAMFEBA ស្តីពីការលុបបំបាត់ទម្រង់ធ្ងន់ធ្ងរបំផុតនៃពលកម្មកុមារក្នុងប្រទេសកម្ពុជា ផ្តោតសំខាន់ទៅលើយុទ្ធសាស្ត្រជាក់លាក់ ដែលត្រូវបានបញ្ជាក់ដូចខាងក្រោមក្នុងការពន្លឿននូវការចូលរួមរបស់ CAMFEBA និងសមាជិកក្នុងការសម្រេចឱ្យបាននូវគោលដៅថ្នាក់ជាតិ នៅឆ្នាំ ២០១៥ និងគោលដៅសកលរបស់ ILO ក្នុងការបញ្ចប់ទម្រង់ធ្ងន់ធ្ងរបំផុតនៃពលកម្មកុមារឱ្យអស់នៅឆ្នាំ ១០១៦។

- **យុទ្ធសាស្ត្រទី ១:** បង្កើន និងពង្រឹងសមត្ថភាពស្ថាប័នរបស់ *CAMFEBA* ក្នុងការដឹកនាំ សម្របសម្រួលក្នុងការត្រួតពិនិត្យ និងរាយការណ៍ ដើម្បីចូលរួមសម្រេចឱ្យបាននូវគោលដៅភ្លោះរបស់រាជរដ្ឋាភិបាលកម្ពុជានៅឆ្នាំ ២០១៦ ដោយបញ្ចប់ឱ្យអស់នូវទម្រង់ធ្ងន់ធ្ងរបំផុត។

- **យុទ្ធសាស្ត្រទី ២:** ពង្រឹងសមត្ថភាពដៃគូពាក់ព័ន្ធទាំងអស់ *CAMFEBA* និងសមាជិករបស់ពួកគេ រួមមានសមាជិករបស់ *GMAC* ក្នុងការលើកកម្ពស់ និងអនុវត្ត *CAMFEBA – PAECL* និងយុទ្ធសាស្ត្រផ្សេងៗទៀត និងក្របខ័ណ្ឌគោលនយោបាយ និងច្បាប់នានាដែលរួមបញ្ចូលក្រមសីលធម៌ ទំនួលខុសត្រូវសង្គម ។ល។ ដើម្បីបង្កើនល្បឿនក្នុងការលុបបំបាត់ពលកម្មកុមារនៅកម្ពុជានាឆ្នាំ ២០១៦។

- **យុទ្ធសាស្ត្រទី ៣:** លើកកម្ពស់ការចូលរួមរបស់ *CAMFEBA* និងសមាគមនិយោជកទាំងនៅវិស័យរៀបរយ និងវិស័យមិនរៀបរយឱ្យដកហូត ទប់ស្កាត់ ការពារ សុវត្ថិភាពនិងសុខភាពនៅកន្លែងការងារ និងប្រព័ន្ធត្រួតពិនិត្យតាមដានពលកម្មកុមារ *(CLMS)* និងផ្តល់ការគាំទ្រសមរម្យដល់កុមារ/យុវវ័យ ដូចជាការអប់រំ និងជំនាញចាំបាច់សម្រាប់កុមារ និងយុវវ័យ ដើម្បីមានការងារធ្វើ និងទទួលបានការងារសមរម្យ និងប្រយុទ្ធប្រឆាំងនឹង ការជួញដូរកេងប្រវ័ញ្ចផ្លូវភេទមកលើកុមារ និងពលកម្មកុមារ ដើម្បីសម្រេចបាននូវគោលដៅភ្លោះរបស់រដ្ឋាភិបាលនៅឆ្នាំ ២០១៦។

- **យុទ្ធសាស្ត្រទី ៤:**កៀងគរធនធាន ដើម្បីធានា CAMFEBA និងសមាគមនិយោជកដែលជាសមាជិករបស់ពួកគេ និងដៃគូសង្គមដែលរួមមានសហជីព និងភាគីរដ្ឋាភិបាល នឹងមានធនធានគ្រប់គ្រាន់ក្នុងការ ប្រយុទ្ធប្រឆាំងនឹងពលកម្មកុមារឆ្ពោះទៅកាន់គោលដៅភ្លោះកម្ពុជានៅឆ្នាំ ២០១៦។

- **យុទ្ធសាស្ត្រទី ៥:** បង្កើតយុទ្ធសាស្ត្រក្នុងការតស៊ូមតិ និងលើកកម្ពស់ការយល់ដឹង ស្តីពីផលវិបាកជាអវិជ្ជមាននៃពលកម្មកុមារមកលើសង្គម ជាពិសេសធានាថា CAMFEBA និងសមាគមនិយោជកដែលជាសមាជិករបស់ពួកគេ នឹងបន្តចូលរួមចំណែកគាំទ្រសម្រេចគោលដៅភ្លោះរបស់រដ្ឋាភិបាលនៅឆ្នាំ ២០១៦ និង និរន្តរ៍ភាពនៃសកម្មភាពទាំងនេះនៅក្នុងប្រទេសកម្ពុជាបន្ទាប់ពីឆ្នាំ ២០១៦។

## ៤.៥. លទ្ធផលរំពឹងទុក និងសកម្មភាពសំខាន់ៗ

**យុទ្ធសាស្ត្រទី ១** មាន**លទ្ធផលរំពឹងទុកចំនួន៣** ដែលរួមបញ្ចូលនូវ**សកម្មភាពសំខាន់ៗចំនួន១៤** ដែលមានការសង្ខេបដូចខាងក្រោម:

**លទ្ធផលរំពឹងទុក ១.១: ពិនិត្យមើលឡើងវិញ និងបង្កើតយន្តការរបស់ CAMFEBA សម្រាប់អនុវត្តPAECL ដើម្បីឆ្ពោះទៅសម្រេចបានគោលដៅភ្លោះរបស់រាជរដ្ឋាភិបាលកម្ពុជា។** លទ្ធផលរំពឹងទុកនេះ ធ្វើឡើងដើម្បីធានាថា យន្តការរបស់CAMFEBAត្រូវបានអនុវត្តយ៉ាងរលូននៅតាម ២៤ ខេត្ត នៅក្នុងប្រទេសកម្ពុជា ដើម្បីចូលរួមចំណែកដល់គោលដៅភ្លោះរបស់រាជរដ្ឋាភិបាលកម្ពុជា ក្នុងការបញ្ចប់ទម្រង់ធ្ងន់ធ្ងរបំផុតនៃពលកម្មកុមារ នៅឆ្នាំ ២០១៦។ លទ្ធផលរំពឹងទុកនេះមាន **សកម្មភាពសំខាន់ៗចំនួន ៤** ដោយផ្តោតសំខាន់ទៅលើ ការពង្រឹង និងពង្រីករចនាសម្ព័ន្ធរបស់ CAMFEBA និងយន្តការក្នុងប្រយុទ្ធប្រឆាំងនឹងទម្រង់ធ្ងន់ធ្ងរបំផុតនៃពលកម្មកុមារនៅ ២៤ ខេត្ត តាមរយៈការសហការជាមួយសភាពាណិជ្ជកម្ម។ កំនត់តួនាទី និងទំនួលខុសត្រូវរបស់និយោជក ក្រុមហ៊ុន និងវិស័យឯកជនក្នុងការប្រយុទ្ធប្រឆាំងទម្រង់ធ្ងន់ធ្ងរបំផុតនៃពលកម្មកុមារ។ ចូលរួមកិច្ចប្រជុំ សន្និសីទ សិក្ខាសិលា ការលើកកម្ពស់ការយល់ដឹង និងយុទ្ធនាការផ្សព្វផ្សាយដែលតំណាងឱ្យ CAMFEBA/សហព័ន្ធនិយោជក ក្នុងការលុបបំបាត់ទម្រង់ធ្ងន់ធ្ងរបំផុតនៃពលកម្មកុមារ និងជួយគាំទ្រដើម្បីឱ្យសម្រេចគោលដៅភ្លោះរបស់រាជរដ្ឋាភិបាលកម្ពុជា នៅឆ្នាំ ២០១៦។

**លទ្ធផលរំពឹងទុក ១.២: ការសហការ និងអនុវត្តនូវ CAMFEBA - PAECL ស្របតាមគោលនយោបាយជាតិផ្សេងៗទៀត ក្នុងការប្រយុទ្ធប្រឆាំងទម្រង់ធ្ងន់ធ្ងរបំផុតនៃពលកម្មកុមារនៅក្នុងប្រទេសកម្ពុជា។** លទ្ធផលរំពឹងទុកនេះធានាថា សមាគមរោងចក្រកាត់ដេរកម្ពុជា សភាពាណិជ្ជកម្ម និងវិស័យឯកជន ទទួលខុសត្រូវក្នុងការអនុវត្ត CAMFEBA's PAECL ដើម្បីគាំទ្រគោលដៅភ្លោះរបស់រាជរដ្ឋាភិបាលកម្ពុជានៅឆ្នាំ ២០១៦។ លទ្ធផលរំពឹងទុកនេះមាន**សកម្មភាពសំខាន់ៗចំនួន ៥** ដែលរួមបញ្ចូលការពង្រឹង និងការពង្រីករចនាសម្ព័ន្ធរបស់ CAMFEBA និងយន្តការក្នុងការប្រយុទ្ធប្រឆាំងទម្រង់ធ្ងន់ធ្ងរបំផុតនៃពលកម្មកុមារនៅគ្រប់ ២៤ ខេត្ត តាមរយៈកិច្ចសហការជាមួយសភាពាណិជ្ជកម្ម និងស្របទៅតាមយន្តការដែលមានស្រាប់ផ្សេងៗទៀត ដូចជាក្រុមប្រឹក្សាពលកម្មកុមារខេត្ត ឃុំ និងភូមិ និងក្រុមប្រឹក្សាសហគមន៍។ វាជួយផ្សព្វផ្សាយអំពី CAMFEBA – PAECL នៅឆ្នាំ ២០១៦ ទៅកាន់សមាជិក និងអ្នកជាប់ពាក់ព័ន្ធទាំងអស់ ដែលរួមបញ្ចូលអ្នកបញ្ជាទិញសម្រាប់ការរួមចំណែក និងការប្តេជ្ញាចិត្តរបស់ពួកគេ ដើម្បីចូលរួមចំណែកសម្រេចគោលដៅភ្លោះរបស់រាជរដ្ឋាភិបាលនៅឆ្នាំ ២០១៦។ វាក៏ជួយផ្សព្វផ្សាយ និងចែកចាយ CAMFEBA–PAECL ទៅកាន់សមាជិកនិយោជកទាំងអស់ ក្រសួងរបស់រដ្ឋ និងកម្មករ និងអង្គការក្រៅរដ្ឋាភិបាលទាំងក្នុងស្រុក និងអន្តរជាតិ ក្នុងការបញ្ជ្រាបនិងបញ្ចូល CAMFEBA–PAECL ទៅក្នុងកិច្ចអន្តរាគមន៍ និងផែនការសកម្មភាពរបស់ពួកគេ។

**លទ្ធផលរំពឹងទុក ១.៣: បង្កើនសមត្ថភាព និងបញ្ជ្រាប GMAC និយោជក និងសមាជិករបស់ពួកគេ និង វិស័យឯកជនទាំងអស់ ឱ្យរួមកំលាំងគ្នាក្នុងការលុបបំបាត់ពលកម្មកុមារឆ្ពោះទៅកាន់គោលដៅភ្លោះរបស់រាជរដ្ឋាភិបាលកម្ពុជា។** លទ្ធផលរំពឹងទុកនេះ រួមបញ្ចូល**សកម្មភាពសំខាន់ៗចំនួន ៥** ដោយផ្តោតលើការងារជាមួយ សហជីព ស្ថាប័នរដ្ឋាភិបាលកម្ពុជា GMAC ក្រុមហ៊ុនឯកជន សភាពាណិជ្ជកម្ម កាកបាទក្រហមនៅថ្នាក់ជាតិ និងថ្នាក់ខេត្ត

ដើម្បីជួយជូនដំណឹងទៅកាន់អ្នកវិនិយោគទុនអ្នកជំនួញ។ល។ ដើម្បីលុបបំបាត់ទម្រង់ធ្ងន់ធ្ងរបំផុត នៃពលកម្មកុមារ ការជួញដូរកេងប្រវ័ញ្ចផ្លូវភេទមកលើកុមារ និងសុវត្ថិភាពកុមារក្នុងវិស័យទេសចរណ៍ និងលើកកម្ពស់ការងារសមរម្យសម្រាប់យុវជន។ វាក៏សបញ្ជាក់ពីការប្តេជ្ញាចិត្តរបស់ CAMFEBA និងសមាជិករបស់ខ្លួន នូវរាល់សកម្មភាពដែលកើតឡើងទាំងនៅក្នុងប្រទេសទាំងនៅថ្នាក់តំបន់ ថ្នាក់អន្តរជាតិ ក្នុងការលុបបំបាត់ទម្រង់ធ្ងន់ធ្ងរបំផុតនៃពលកម្មកុមារ ជាពិសេសឆ្ពោះទៅសម្រេចបានគោលដៅភ្លោះរបស់រាជរដ្ឋាភិបាលនៅឆ្នាំ ២០១៦។

**យុទ្ធសាស្ត្រទី ២** រួមបញ្ចូល **លទ្ធផលរំពឹងទុក ២** រួមមាន **សកម្មភាពសំខាន់ៗចំនួន ១០** ត្រូវបានសង្ខេបដូចខាងក្រោម:

**លទ្ធផលរំពឹងទុក ២.១: ការអភិវឌ្ឍគោលនយោបាយ និងស្ថាប័ន:** លទ្ធផលរំពឹងទុកនេះគាំទ្រ និងអនុម័តគោលនយោបាយពលកម្មកុមារ សំដៅទៅរកការលុបបំបាត់ទម្រង់ធ្ងន់ធ្ងរបំផុតនៃពលកម្មកុមារនៅឆ្នាំ ២០១៦។ លទ្ធផលរំពឹងទុកនេះ មាន**សកម្មភាពសំខាន់ៗចំនួន ៦** ដែលផ្តោតសំខាន់ទៅលើការផ្តួចផ្តើម និងការអភិវឌ្ឍ ឬការធ្វើបច្ចុប្បន្នភាពលើគោលនយោបាយ បទបញ្ញត្តិ ដែលរួមបញ្ចូលក្រមសីលធម៌ ទំនួលខុសត្រូវសង្គម ។ល។ ដែលទាក់ទងទៅនឹងការលុបបំបាត់ពលកម្មកុមារនៅក្នុងប្រទេសកម្ពុជា។ ពិនិត្យមើលឡើងវិញ និងបញ្ចូលតួនាទី និងការប្តេជ្ញាចិត្តរបស់ CAMFEBA និងនិយោជក ចូលទៅក្នុងគោលនយោបាយដែលទាក់ទងនឹងការលុបបំបាត់ពលកម្មកុមារនៅក្នុងប្រទេសកម្ពុជា និងបញ្ជ្រាបទម្រង់ធ្ងន់ធ្ងរបំផុតនៃពលកម្មកុមារទៅក្នុងយុទ្ធសាស្ត្ររបស់កាកបាទក្រហមកម្ពុជា និងផែនការសកម្មភាពជាការឆ្លើយតប និងដោះស្រាយជាបន្ទាន់ទៅនឹងពលកម្មកុមារ និងគាំទ្រការអនុវត្តក្របខ័ណ្ឌការងារថ្នាក់ជាតិស្តីពីការលុបបំបាត់ពលកម្មកុមារ ដូចជាផែនការសកម្មភាពថ្នាក់ជាតិស្តីពីការលុបបំបាត់ទម្រង់ធ្ងន់ធ្ងរបំផុតនៃពលកម្មកុមារ និងគាំទ្រលើការអនុវត្តយុទ្ធសាស្ត្រជាតិ ដែលបានអនុម័តលើការលុបបំបាត់ពលកម្មកុមារដូចជា NPA-WFCL យុទ្ធសាស្ត្រគាំពារសង្គមជាតិសម្រាប់ជនក្រីក្រ និងជនងាយរងគ្រោះ ការអប់រំដើម្បីទាំងអស់គ្នា និងគោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍កម្ពុជា (គអសក) ។ល។

**លទ្ធផលរំពឹងទុក ២.២: ច្បាប់ និងការអនុវត្ត.** ធាតុចេញនេះ គឺជាការធ្វើបច្ចុប្បន្នភាពនៃឧបករណ៍ច្បាប់ដែលមានស្រាប់ ដើម្បីឆ្លុះបញ្ចាំងពីការប្តេជ្ញាចិត្តរបស់ប្រទេសកម្ពុជា ដោយគោរពតាមអនុសញ្ញារបស់អង្គការពលកម្មអន្តរជាតិលេខ ១៣៨ និង ១៨២ និងគោលដៅភ្លោះរបស់រាជរដ្ឋាភិបាល។ លទ្ធផលរំពឹងទុកនេះមាន **សកម្មភាពសំខាន់ៗចំនួន ៤** ដោយផ្តោតទៅលើការផ្តួចផ្តើម ដើម្បីបង្កើត ឬធ្វើវិសោធនកម្ម លើបទបញ្ជារបស់ក្រសួង (ប្រកាស) ស្តីពីពលកម្មកុមារ ដែលឆ្លុះបញ្ចាំងពីការប្តេជ្ញាចិត្តរបស់ប្រទេសកម្ពុជា ចំពោះអនុសញ្ញារបស់អង្គការពលកម្មអន្តរជាតិលេខ ១៣៨ និង ១៨២ និងគោលដៅភ្លោះរបស់រាជរដ្ឋាភិបាល។ ចូលរួមនិងធ្វើបច្ចុប្បន្នភាពច្បាប់ការងារដែលមានស្រាប់ ពីព្រោះច្បាប់នេះមានទំនាក់ទំនងនឹងពលកម្មកុមារ និងការគាំទ្រក្នុងការបង្កើតឡើងនូវច្បាប់ថ្មីៗ ស្តីពីការដាក់ទោសទណ្ឌ (រួមបញ្ចូលសំណងប៉ះប៉ូវសម្រាប់ពលករកុមារ) ។

**យុទ្ធសាស្ត្រទី ៣** មាន **លទ្ធផលរំពឹងទុកចំនួន ៧** ដែលរួមបញ្ចូល **សកម្មភាពសំខាន់ៗចំនួន ៣០** ដែលត្រូវបានសង្ខេបដូចខាងក្រោម:

**លទ្ធផលរំពឹងទុក ៣.១: ការសិក្សា និងស្រាវជ្រាវ:** លទ្ធផលរំពឹងទុកនេះ មានគោលបំណងក្នុងការប្រមូល និងវិភាគទៅលើទម្រង់ធ្ងន់ធ្ងរបំផុតនៃពលកម្មកុមារទៅលើគ្រប់ផ្នែកទាំងអស់។ លទ្ធផលរំពឹងទុកនេះមាន**សកម្មភាពសំខាន់ចំនួន ៤** ដោយផ្តោតលើការកំនត់ទម្រង់ធ្ងន់ធ្ងរបំផុតនៃពលកម្មកុមារ ដោយការរាប់ចំនួនមនុស្ស តាមរយៈយុទ្ធសាស្ត្រនៃអត្តសញ្ញាណកម្មគ្រួសារក្រីក្រ និងកំណត់ទម្រង់ធ្ងន់ធ្ងរបំផុតនៃពលកម្មកុមារ និងក្រុមងាយរងគ្រោះដែលត្រូវបានជួយគាំទ្រតាមរយៈការដកហូត គាំពារ និងស្តារីតិសម្បទា ។ល។ កិច្ចការនេះតំរូវឱ្យកិច្ចសហការជាមួយ ILO-IPEC រាជរដ្ឋាភិបាលកម្ពុជា - (ក្រសួងផែនការ) សហជីព SCNACL ។ល។ ក្នុងការធ្វើការស្រាវជ្រាវលើទម្រង់ធ្ងន់ធ្ងរបំផុតនៃពលកម្មកុមារ និងស្វែងរកយុទ្ធសាស្ត្រក្នុងការដោះស្រាយក្នុងប្រទេស។ បន្ទាប់មកធ្វើការចែកចាយរបាយការណ៍ស្រាវជ្រាវទាំងនេះយ៉ាងទូលំទូលាយ ទៅកាន់ទៅដៃគូពាក់ព័ន្ធទាំងអស់ ទាំងឯកសារជាក្រដាស និងឯកសារជាអេឡិចត្រូនិច ដែលមាននៅក្នុងវិបសាយ។ ទាញយកព័ត៌មាន និង អនុសាសន៍ក្នុងរបាយការណ៍ ដើម្បីបង្កើតកម្មវិធី ឬគម្រោងក្នុងការចូលរួម ការអនុវត្ត CAMFEBA–PAECL, NPA-WFCL ក៏ដូចជាគោលនយោបាយជាតិផ្សេងៗទៀតសំដៅលុបបំបាត់ពលកម្មកុមារនៅឆ្នាំ ២០១៦។

**លទ្ធផលរំពឹងទុក ៣.២: លើកកម្ពស់សុខភាព និងសុវត្ថិភាពនៅកន្លែងការងារ (OSH):** លទ្ធផលរំពឹងទុកនេះនឹងជំរុញការលើកកម្ពស់ផ្នែកសុខភាព និងសុវត្ថិភាពនៅកន្លែងការងារ។ លទ្ធផលរំពឹងទុកនេះមាន **សកម្មភាពសំខាន់ៗចំនួន ៤** ដោយផ្តោតសំខាន់ទៅលើកិច្ចសហការជាមួយក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ អង្គការពលកម្មអន្តរជាតិ សហជីព និងនិយោជកក្នុងស្រុក ដើម្បីបង្កើតនូវបញ្ជីស្រង់ស្ថិតិដែលមានលក្ខណៈស្តង់ដារមួយសម្រាប់ការចុះធ្វើអធិការកិច្ច ក្នុងនោះមានរួមបញ្ចូលទាំងបញ្ហាពលកម្មកុមារ។ បន្ទាប់មកផ្តល់ជូនឧបករណ៍ និងសំភារៈការពារ (រួមមាន របាំងការងារមុខ សំលៀកបំពាក់ ស្បែកជើង ស្រោមដៃ ពន្លឺ សំលេង ។ល។) អាស្រ័យទៅលើប្រភេទការងាររបស់កម្មករ ការការពារពិសេសសម្រាប់កុមារ ឬយុវវ័យ ដែលធ្វើការនៅកន្លែងការងារ ការផ្តល់នូវឧបករណ៍សង្គ្រោះបន្ទាន់ និងការធ្វើឱ្យមានភាពងាយស្រួលសម្រាប់កម្មករក្នុងការប្រើប្រាស់ឧបករណ៍នៅពេលបន្ទាន់។ ឧបករណ៍ និងសំភារៈទាំងអស់ត្រូវតែត្រួតពិនិត្យជាប្រចាំ ដើម្បីធានាឱ្យបាននូវគុណភាព និងលក្ខខណ្ឌការងារនៅកន្លែងការងារជាពិសេសយកចិត្តទុកដាក់ចំពោះកុមារ/យុវវ័យ។

**លទ្ធផលរំពឹងទុក ៣.៣: បង្កើត និងអនុវត្តការត្រួតពិនិត្យពលកម្មកុមារ:** លទ្ធផលរំពឹងទុកនេះ នឹងបង្កើតប្រព័ន្ធត្រួតពិនិត្យពលកម្មកុមារមួយនៅកន្លែងការងារ និងគ្រឹះស្ថាន។ លទ្ធផលរំពឹងទុកនេះមាន**សកម្មភាពសំខាន់ៗចំនួន ៤** ផ្តោតសំខាន់លើការបង្កើត និងកំណត់ឱ្យបានច្បាស់នូវប្រព័ន្ធទិន្នន័យនៃកុមារ/យុវវ័យធ្វើនៅក្នុងកន្លែងការងាររបស់ពួកគេ និងបង្កើតឱ្យមាននូវការត្រួតពិនិត្យ។ ត្រួតពិនិត្យលក្ខខណ្ឌការងាររបស់កុមារ/យុវវ័យជាទៀងទាត់ និងធានាបាននូវការងារសមរម្យសម្រាប់យុវវ័យ និងគាំទ្រនិងផ្តល់ព័ត៌មានសំខាន់ៗទាំងអស់ទៅដល់អធិការករការងារ ដែលនេះគឺជាតម្រូវការសម្រាប់ការត្រួតពិនិត្យលើពលកម្មកុមារ។

**លទ្ធផលរំពឹងទុក ៣.៤: ការដកហូត/ការពារកុមារ និង បង្កើនជីវភាពរស់នៅរបស់ពួកគេ និងក្រុមគ្រួសាររបស់ពួកគេ:** លទ្ធផលរំពឹងទុកនេះធ្វើឡើងដើម្បីដកហូតកុមារដែលធ្វើការនៅក្នុងទម្រង់ធ្ងន់ធ្ងរបំផុត និងផ្តល់សេវាគាំទ្រផ្សេងៗ។ **ការការពារ និង លើកកម្ពស់ការជួលយុវវ័យសម្រាប់ការងារសមរម្យ** នឹងក្តោបលទ្ធផលរំពឹងទុកនីមួយៗផ្សេងៗគ្នា ដោយសារតែវាត្រូវការការយកចិត្តទុកដាក់ជាពិសេសរបស់ CAMFEBA និងសកម្មភាព

និយោជក។ លទ្ធផលរំពឹងទុកនេះមាន **សកម្មភាពសំខាន់ៗចំនួន ៥** ផ្តោតសំខាន់លើបទបញ្ញត្តិ និងសេវាគាំទ្ររបស់និយោជក ដល់ឪពុកម្តាយ នាយកសាលា គ្រូ អ្នកអប់រំ និងកុមារធ្វើការ ដើម្បីធ្វើសមាហរណកម្មឡើងវិញចំពោះកុមារដែលត្រូវបានដកហូតពីកន្លែងការងារដែលប្រកបដោយគ្រោះថ្នាក់ចូលទៅក្នុងសាលារៀន។ ជួយគាំទ្រឱ្យកុមារធ្វើសមាហរណកម្មឱ្យបានទទួលការអប់រំផ្លូវការ (ផ្តល់សំភារៈសិក្សា កង់ ជំនួយឧបត្ថម្ភ ។ល។) និងជួយគាំទ្រលើការត្រួតពិនិត្យបន្ថែមទៀតបន្ទាប់ពីមានការដកហូតហើយ និងផ្តល់ព័ត៌មានដល់រដ្ឋាភិបាល អង្គការក្រៅរដ្ឋាភិបាលក្នុងស្រុក ។ល។ សម្រាប់ធ្វើការតាមដានបន្ត។

**<u>លទ្ធផលរំពឹងទុក ៣.៥: </u>ការបង្ការ:**លទ្ធផលរំពឹងទុកនេះ ធានាថាកុមារដែលងាយរងគ្រោះដទៃទៀត នឹងមិនពាក់ព័ន្ធ ឬធ្លាក់ចូលទៅក្នុងទម្រង់ធ្ងន់ធ្ងរបំផុតនៃពលកម្មកុមារ។ លទ្ធផលរំពឹងទុកនេះមាន**សកម្មភាពសំខាន់ៗចំនួន ៥** ដោយផ្តោតសំខាន់លើការបង្កើតយុទ្ធសាស្ត្រសម្រាប់បង្ការ និងអនុវត្តយុទ្ធសាស្ត្រទាំងនោះ ដើម្បីធានាថាគ្មានកុមារដែលឋិតនៅក្រោមអាយុបម្រើការងារត្រូវបានជួលដោយនិយោជកទាំងនៅក្នុងវិស័យរៀបរយ និងវិស័យមិនរៀបរយ (រួមបញ្ចូលទាំងការងារបម្រើការតាមផ្ទះ ការងារពាក់កណ្តាលឧស្សាហកម្ម ការងារស្រែចំការលក្ខណៈគ្រួសារ ។ល។)។ ផ្តល់ការគាំទ្រកុមារ/កុមារបម្រើការងារដែលត្រលប់ទៅកាន់គ្រួសារ ឬទីកន្លែងកំណើតរបស់ពួកគេវិញឬសម្រាប់អ្នកធ្វើចំណាកស្រុក ឬក្មេងកំព្រា និងផ្តល់ជំនាញ ឬការអប់រំរហូតដល់ពួកគេឈានដល់អាយុបម្រើការងារ (១៥ ឆ្នាំ)។ ធ្វើការសហការជាមួយភ្នាក់ងារជ្រើសរើសពលករ ដើម្បីបញ្ជ្រាបនូវបញ្ហាពលកម្មកុមារ ក្របខណ្ឌច្បាប់ជាតិ និងអន្តរជាតិ ដូចជា NPA-WFCL CAMFEA-PAECL អនុសញ្ញាILO លេខ ១៣៨ ១៨២ UNCRC ដើម្បីសម្រេចឆ្ពោះទៅកាន់គោលដៅភ្លោះរបស់រដ្ឋាភិបាល នៅឆ្នាំ ២០១៦។ រៀបចំឡើងនូវមជ្ឈមណ្ឌលព័ត៌មាន និងបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈនៅក្នុងតំបន់ដែលមានប្រជាជនកកកុញ ដើម្បីលើកកម្ពស់ការងាររបស់យុវវ័យ ផ្សារភ្ជាប់ជាមួយនឹងការលុបបំបាត់ពលកម្មកុមារ និងបង្កើតសំភារៈ IEC (ការបោះពុម្ពសំឡេង រូបភាព និងគេហទំព័រ) ដើម្បីចូលរួមសម្រេចគោលដៅភ្លោះរបស់រាជរដ្ឋាភិបាល។

**<u>លទ្ធផលរំពឹងទុក ៣.៦:</u> ការការពារ:**លទ្ធផលរំពឹងទុកនេះ ការពារកុមារបម្រើការងារដែលឋិតនៅក្នុងអាយុបម្រើការការងារ និងធានាថា ច្បាប់ការងារ បទបញ្ញត្តិនិងការដាក់ទោសទណ្ឌ (រួមបញ្ចូល សំណងសម្រាប់ពលករកុមារ) ត្រូវបានអនុវត្ត។ លទ្ធផលរំពឹងទុកនេះមាន **សកម្មភាពសំខាន់ៗចំនួន ៥** ដោយផ្តោតសំខាន់លើការបង្កើតលក្ខខណ្ឌការងារសម្រាប់កុមារ/យុវវ័យ (អាយុ១៥ឆ្នាំ + ផ្អែកលើច្បាប់ការងារ និងឧបករណ៍ច្បាប់នានារបស់អង្គការពលកម្មអន្តរជាតិ) និងត្រួតពិនិត្យការការពារកុមារដែលមានអាយុ ១៥ឆ្នាំ និងលើសពី ១៥ឆ្នាំនៅកន្លែងការងារ។ សហការជាមួយក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ សហជីព និងសង្គមស៊ីវិល ដើម្បីបង្កើត "លក្ខខណ្ឌការងារកាន់តែប្រសើរ" សម្រាប់កុមារអាយុ ១៥ឆ្នាំ និងលើសពី ១៥ឆ្នាំ។ ពលករកុមារីត្រូវបានឱ្យអាទិភាពក្នុងការទទួលបាននូវផលប្រយោជន៍រាល់សកម្មភាពអន្តរាគមន៍ទាំងអស់។

**<u>លទ្ធផលរំពឹងទុក ៣.៧:</u> លើកកម្ពស់ការជួលយុវវ័យ សម្រាប់ការងារសមរម្យ:**លទ្ធផលរំពឹងទុកនេះ ធ្វើឡើងដើម្បីលើកកម្ពស់យុវវ័យដែលមានអាយុស្របច្បាប់ក្នុងការចូលបម្រើការងារ ឱ្យមានការងារធ្វើ និងមានលក្ខខណ្ឌការងារសមរម្យ ដើម្បីឱ្យពួកគេឈប់បញ្ជូនប្អូនៗរបស់ពួកគេ/កុមារទៅបម្រើការងារ ដោយឱ្យក្មេងៗទាំងនោះចូលសាលារៀនជំនួសវិញ។ លទ្ធផលរំពឹងទុកនេះមាន **សកម្មភាពសំខាន់ៗចំនួន ៥** ក្នុងការលើកកម្ពស់យុវវ័យ

ដែលមានអាយុអប្បបរមាសម្រាប់បម្រើការងារ (លើសពី ១៥ ឆ្នាំ) ឱ្យធ្វើការងារដែលមានលក្ខខណ្ឌសមរម្យ និងមានការការពារ។ គាំទ្រដល់កុមារដែលមានអាយុ ១៥ ឆ្នាំ ឬលើសពីនេះ ឱ្យទទួលបានឱកាសការងារសមរម្យ និងផ្តល់ឱ្យពួកគេនូវវគ្គបណ្តុះបណ្តាលវិជ្ជាជីវៈសម្រាប់ការងារ ដោយការសហការជាមួយ មជ្ឈមណ្ឌលនៅក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ឬយុទ្ធសាស្ត្របណ្តុះបណ្តាលកូនជាងដែលផ្សារភ្ជាប់ជាមួយនឹងកម្មវិធីនានារបស់អង្គការក្រៅរដ្ឋាភិបាលដោយផ្អែកលើទីផ្សារការងារ។ សហការជាមួយសមាគម ភ្នាក់ងារជ្រើសរើសពលករកម្ពុជា (ACRA) ដើម្បីធានាថា កុមារក្រោមអាយុ ១៥ឆ្នាំ មិនត្រូវបានអនុញ្ញាតឱ្យចូលបម្រើការងារ ប៉ុន្តែសម្រាប់កុមារដែលមានអាយុ ១៥ឆ្នាំ ឬលើសពីនេះ ពួកគេត្រូវបានផ្តល់នូវជំនាញ និងការងារសមរម្យ ដែលមានលក្ខខណ្ឌ និងប្រាក់ខែសមរម្យ។ ផ្តល់ភាពងាយស្រួលក្នុងការទទួលបានសេវាកម្មគាំទ្រ និង គៀងគរធនធានដើម្បីធានាថា កុមារមានឱកាសទទួលបានការអប់រំរហូតដល់អាយុ ១៥ឆ្នាំ តាមរយៈការផ្តល់ អាហារូបករណ៍ទាំងការអប់រំក្នុង និងក្រៅប្រព័ន្ធ។

**យុទ្ធសាស្ត្រទី ៤ រួមបញ្ចូល <u>លទ្ធផលរំពឹងទុក</u> ១ ដែលរួមមានសកម្មភាពសំខាន់ៗចំនួន ៧ ដែលត្រូវបានសង្ខេបដូចខាងក្រោម:**

**<u>លទ្ធផលរំពឹងទុក ៤.១:</u> បង្កើតសម្ព័ន្ធពាណិជ្ជកម្មកម្ពុជាប្រឆាំងនឹងពលកម្មកុមារ (CBaaC) សម្រាប់គៀងគរធនធាន និងការចូលរួម ដើម្បីចូលរួមចំណែកក្នុងគោលដៅភ្លោះរបស់រាជរដ្ឋាភិបាលកម្ពុជានៅឆ្នាំ ២០១៦ និងបន្តទៅទៀត.**លទ្ធផលរំពឹងទុកនេះគឺដើម្បីគៀងគរធនធានដើម្បីអនុវត្ត CAMFEBA's PAECLសម្រាប់ចូលរួមចំណែកក្នុងគោលដៅភ្លោះរបស់រាជរដ្ឋាភិបាលកម្ពុជានៅឆ្នាំ ២០១៦។ លទ្ធផលរំពឹងទុកនេះរួមមាន **សកម្មភាពសំខាន់ៗ ចំនួន ៧** ដូចជាការកសាងបណ្តាញដើម្បីគៀងគរធនធានពីភ្នាក់ងាររដ្ឋាភិបាល ភ្នាក់ងារអង្គការសហប្រជាជាតិ ភ្នាក់ងារដៃគូអភិវឌ្ឍន៍ និងវិស័យឯកជនផ្សេងៗទៀត រួមមានអ្នកបញ្ជាទិញ (ក្នុង និងក្រៅប្រទេស)។ កំនត់យុទ្ធសាស្ត្រលើកទឹកចិត្តក្នុងការគៀងគរធនធាន ដើម្បីគាំទ្រការឧបត្ថម្ភ សកម្មភាពណាដែលទាក់ទងនឹងការលុបបំបាត់ពលកម្មកុមារ ដែលកើតចេញពីការអនុវត្ត CAMFEBA-PAECL ឆ្ពោះទៅកាន់ ២០១៦។ ធ្វើការទាក់ទងក្រសួងផ្សេងៗ កាកបាទក្រហមកម្ពុជា និយោជក ក្រុមហ៊ុនឯកជន អង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុក ឬអន្តរជាតិសំខាន់ៗ និងដៃគូរអភិវឌ្ឍន៍ ក្នុងការរៀបចំតន្ត្រី កីឡា និងការជួបជុំរបស់សង្គមស្តីអំពីពលកម្មកុមារ ដើម្បីរៃអង្គាសថវិកាសម្រាប់ចូលរួមក្នុងការលុបបំបាត់ពលកម្មកុមារនៅឆ្នាំ ២០១៦ និងបន្តទៅមុខទៀត និងធានាឱ្យបាននូវគណនេយ្យភាព និងតម្លាភាពសម្រាប់ការប្រើប្រាស់នូវថវិកា។

**យុទ្ធសាស្ត្រទី ៥ រួមបញ្ចូល <u>លទ្ធផលរំពឹងទុក</u> ១ រួមមាន សកម្មភាពសំខាន់ៗចំនួន ៧ ដែលត្រូវបានសង្ខេបដូចខាងក្រោម:**

**<u>លទ្ធផលរំពឹងទុក ៥.១:</u> ការតស៊ូមតិ និងបញ្ជ្រាបទៅដល់និយោជក ទាំងវិស័យរៀបរយ និងវិស័យមិនរៀបរយ:**លទ្ធផលរំពឹងទុកនេះ បង្កើតនូវយុទ្ធសាស្ត្រតស៊ូមតិ និងការបង្កើនការយល់ដឹងសម្រាប់ និយោជក កម្មករ អ្នករៀបចំគោលនយោបាយ សាធារណជន អំពីការប្រយុទ្ធប្រឆាំងទម្រង់ធ្ងន់ធ្ងរបំផុតនៃពលកម្មកុមារ នៅឆ្នាំ ២០១៦។ យុទ្ធសាស្ត្រនេះរួមមាន **សកម្មភាពសំខាន់ៗចំនួន ៥** ដូចជាការបង្កើត និងចែកចាយសំភារៈ ដើម្បីអប់រំ និងទាក់ទំនងព័ត៌មាន (បោះពុម្ព សំឡេង និង រូបភាព) ស្តីពីការប្រយុទ្ធប្រឆាំងទម្រង់ធ្ងន់ធ្ងរបំផុតនៃពលកម្មកុមារ

នៅឆ្នាំ ២០១៦ ក្នុងប្រទេសកម្ពុជា ទៅកាន់សាធារណជន និយោជក GMAC អ្នករៀបចំគោលនយោបាយ ឪពុកម្តាយ កូន និង យុវវ័យ។ សហការជាមួយក្រសួងនានាដូចជា ក្រសួងមហាផ្ទៃ និងក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ សភាពាណិជ្ជកម្ម កាកបាទក្រហម និងសហជីព ដើម្បីបង្កើតយុទ្ធសាស្ត្រប្រព័ន្ធផ្សព្វផ្សាយសម្រាប់លើកកម្ពស់ការលុបបំបាត់ពលកម្មកុមារ និងការប្តេជ្ញាចិត្តរបស់រាជរដ្ឋាភិបាលកម្ពុជាចំពោះគោលដៅភ្លោះនៅឆ្នាំ ២០១៦។ ធានាថាប្រទេស ដែលជាអ្នកបញ្ជាទិញទទួលស្គាល់ និងគាំទ្រ គោលដៅភ្លោះរបស់រាជរដ្ឋាភិបាលកម្ពុជាក្នុងការបញ្ចប់ទម្រង់ធ្ងន់ធ្ងរបំផុតនៃពលកម្មកុមារនៅឆ្នាំ ២០១៦។

## យុទ្ធសាស្ត្រ និង ធាតុចេញសំខាន់ៗរបស់ CAMFEBA's PAECL ដែលនឹងត្រូវដាក់ឱ្យអនុវត្ត

- ***យុទ្ធសាស្ត្រទី ១:*** *បង្កើន និងពង្រឹងសមត្ថភាពស្ថាប័នរបស់ CAMFEBA ក្នុងការដឹកនាំ សម្របសម្រួលក្នុងការត្រួតពិនិត្យ និងរាយការណ៍ ដើម្បីចូលរួមសម្រេចឱ្យបាននូវគោលដៅភ្លោះរបស់រាជរដ្ឋាភិបាលកម្ពុជា*
- *នៅឆ្នាំ ២០១៦ ដោយបញ្ចប់ឱ្យអស់នូវទម្រង់ធ្ងន់ធ្ងរបំផុត ។*

***បង្កើនសមត្ថភាពស្ថាប័នរបស់ CAMFEBA's***

***សម្របសម្រួលឱ្យមានការអនុវត្តល្អប្រសើរនូវ CAMFEBA - PAECL ស្របទៅតាមគោលនយោបាយជាតិនានាដ៏ទៃទៀតក្នុងការប្រឆាំងនឹងពលកម្មកុមារនៅក្នុងប្រទេសកម្ពុជា ។***

***បង្កើនសមត្ថភាព និងផ្សព្វផ្សាយទៅដល់ GMAC និយោជកនានា និងសមាជិករបស់ពួកគេ និងទៅកាន់គ្រប់ វិសយ័ឯកជន ដើម្បីរួមគ្នាក្នុងការលុបបំបាត់ពលកម្មកុមារដើម្បីសម្រេចឆ្ពោះទៅកាន់គោលដៅភ្លោះរបស់រាជរដ្ឋាភិបាលកម្ពុជា ។***

- ***យុទ្ធសាស្ត្រទី ២:*** *ពង្រឹងសមត្ថភាព ដៃគូពាក់ព័ន្ធទាំងអស់ CAMFEBA និង សមាជិករបស់ពួកគេ រួមមាន សមាជិករបស់ GMAC ក្នុងការលើកកម្ពស់ និងអនុវត្ត CAMFEBA – PAECL និងយុទ្ធសាស្ត្រផ្សេងៗទៀត និងក្រមខ័ណ្ឌគោលនយោបាយ និងច្បាប់នានា ដែលរួមបញ្ចូលក្រមសីលធមិ ទំនួលខុសត្រូវរបស់ក្រុមហ៊ុន ចំពោះសង្គម ។ល ។ ដើម្បីបង្កើនល្បឿនការលុបបំបាត់ពលកម្ម កុមារនៅកម្ពុជានៅឆ្នាំ ២០១៦ ។*

***ការអភិវឌ្ឍន៏គោលនយោបាយ និងស្ថាប័ន***

***ច្បាប់ និងការដាក់ឱ្យអនុវត្ត***

- ***យុទ្ធសាស្ត្រទី ៣:*** *លើកកម្ពស់ការចូលរួម របស់ CAMFEBA និងសមាគមនិយោជកទាំងនៅក្នុងវិស័យរៀបរយ និងវិស័យមិនរៀបរយឱ្យដកហូតទប់ស្កាត់ ការពារ សុវត្ថិភាព និងសុខភាពនៅកន្លែងការងារ និងប្រព័ន្ធត្រួតពិនិត្យ តាមដានពលកម្មកុមារ (CLMS) និងផ្តល់ការគាំទ្រសមរម្យដល់កុមារ/យុវវ័យ ដូចជាការអប់រំ និងជំនាញចាំបាច់សម្រាប់កុមារ និងយុវវ័យ ដើម្បីមានការងារធ្វើ និងទទួលបានការងារសមរម្យ និងប្រយុទ្ធប្រឆាំងនឹងការជួញដូរ កេងប្រវ័ញ្ចផ្លូវភេទមកលើកុមារ និងពលកម្មកុមារ ដើម្បីសម្រេចបាននូវគោលដៅភ្លោះរបស់រដ្ឋាភិបាលនៅឆ្នាំ ២០១៦*

***ការធ្វើការសិក្សា និងស្រាវជ្រាវ***

***លើកកម្ពស់សុវត្ថិភាព និង សុខភាពនៅកន្លែងការងារ***

***បង្កើត និងអនុវត្តការឃ្លាំមើលពលកម្មកុមារ***

***ការដកហូត/ការបង្ការ និង ការការពារ កុមារ និងលើកកម្ពស់ជីវភាពពួកគេ និងគ្រួសាររបស់ពួកគេ***

***ការបង្ការ***

***ការការពារ***

***ការលើកកម្ពស់ការងារសមរម្យសម្រាប់យុវវ័យ***

- ***យុទ្ធសាស្ត្រទី ៤:*** *កៀងគរធនធាន ដើម្បីធានា CAMFEBA និងសមាគមនិយោជកដែលជាសមាជិករបស់ពួកគេ និងដៃគូសង្គមដែលរួមបញ្ចូលសហជីព និងភាគីរដ្ឋាភិបាល នឹងមានធនធានគ្រប់គ្រាន់ក្នុងប្រយុទ្ធប្រឆាំងនឹងពលកម្មកុមារឆ្ពោះទៅកាន់គោលដៅភ្លោះកម្ពុជានៅឆ្នាំ ២០១៦ ។*

***ការកៀងគរធនធាន***

- ***យុទ្ធសាស្ត្រទី ៥:*** *បង្កើតយុទ្ធសាស្ត្រតស៊ូមតិ និងលើកកម្ពស់ការយល់ដឹងស្តីពីផលវិបាកជាអវិជ្ជមាននៃពលកម្មកុមារមកលើសង្គម ជាពិសេសធានាថា CAMFEBA និងសមាគមនិយោជកដែលជាសមាជិករបស់ពួកគេ នឹងបន្តចូលរួមចំណែកគាំទ្រសម្រេចគោលដៅភ្លោះរបស់រដ្ឋាភិបាលនៅ ឆ្នាំ ២០១៦ និង និរន្តភាពនៃសកម្មភាពទាំងនេះនៅក្នុងប្រទេសកម្ពុជាបន្ទាប់ពីឆ្នាំ ២០១៦ ។*

***ការតស៊ូមតិ និង បញ្ច្រាបទៅកាន់និយោជកទាំងវិស័យសេដ្ឋកិច្ចរៀបរយ និងសេដ្ឋកិច្ចមិនរៀបរយ***

## ៥. ការអនុវត្តផែនការសកម្មភាពក្នុងការលុបបំបាត់ពលកម្មកុមារ នៅក្នុងប្រទេសកម្ពុជា

តារាងការអនុវត្តផែនការសកម្មភាពរបស់ CAMFEBA ស្តីពីការលុបបំបាត់ទម្រង់ធ្ងន់ធ្ងរបំផុតនៃពលកម្មកុមារនៅប្រទេសកម្ពុជា (២០១២-២០១៦) ត្រូវបានភ្ជាប់នៅក្នុងឧបសម្ព័ន្ធ "ក"។

## ៦. ការរាយការណ៍ ត្រួតពិនិត្យ និងការវាយតម្លៃ

### ៦.១. ការត្រួតពិនិត្យ និងការវាយតម្លៃ

ដើម្បីធានាឱ្យបាននូវនិរន្តរ៍ភាពនៃគោលនយោបាយ និងកម្មវិធីជាតិ ផែនការសកម្មភាពរបស់ CAMFEBA ស្តីពីការលុបបំបាត់ក្នុងទម្រង់ធ្ងន់ធ្ងរបំផុតនៅក្នុងប្រទេសកម្ពុជា ត្រូវការការពិនិត្យមើលឡើងវិញជាទៀងទាត់។ ការត្រួតពិនិត្យមើលឡើងវិញជាទៀងទាត់នេះ ធ្វើឡើងក្នុងគោលបំណងដើម្បីវាស់ស្ទង់ពីភាពរីកចម្រើននៃសកម្មភាពធៀបទៅនឹងយុទ្ធសាស្ត្រ និងគោលដៅដែលបានកំណត់។ ការពិនិត្យមើលវិញ គឺជាវិធីសាស្ត្រក្នុងការកំនត់បាននូវការងារដែលអាចធ្វើខុសពីផែនការ កំនត់កត្តាដែលរារាំង ឬពន្លឿននូវការអនុវត្ត និងវិភាគលើចំនុចខ្លាំង និងចំនុចខ្សោយនៅក្នុងការអនុវត្ត។

ការត្រួតពិនិត្យ និងការវាយតម្លៃ ត្រូវមានសូចនាករជាក់លាក់ សម្រាប់ធ្វើការវាស់វែង។ បទដ្ឋានសូចនាករ រួមមានសំណុំនៃសកម្មភាពនានា ចំនួនគោលដៅនៃលទ្ធផល តារាងពេលវេលាសម្រាប់សកម្មភាព វចនាសម្ព័ន្ធនៃសកម្មភាពដែលត្រូវអនុវត្ត តម្រូវការបរិក្ខារនានា និងលទ្ធផលរំពឹងទុក។

ព័ត៌មានចាំបាច់សម្រាប់ការពិនិត្យមើលឡើងវិញ តែងតែបានមកពីរបាយការណ៍តាមមូលដ្ឋាន ការវាយតម្លៃជាទៀងទាត់ និងកិច្ចប្រជុំផែនការ ការផ្តល់ព័ត៌មានត្រឡប់ពីក្រុមគោលដៅ ។ល។ ផែនការក្នុងការស្រាវជ្រាវ និងការសិក្សា នឹងឆ្លុះបញ្ចាំងពីការពិនិត្យបញ្ជាក់ ដូចជាការរាយការណ៍ប្រចាំឆ្នាំ ការវាយតម្លៃពាក់កណ្តាលត្រីមាស ការវាយតម្លៃនៅពេលបញ្ចប់គម្រោង ការស្រាវជ្រាវលើសកម្មភាព ការផលិតឯកសារស្តីពីដំណើរការត្រួតពិនិត្យ និងចុះតាមមូលដ្ឋាន និងយុទ្ធសាស្ត្រចូលរួមផ្សេងៗទៀត។

ដើម្បីផ្តល់សូចនាករជាក់លាក់ឱ្យកាន់តែច្រើន ដែលគោលដៅទាំងអស់នឹងត្រូវបានវាស់វែងជាមួយនឹងផែនការសកម្មភាពរបស់ CAMFEBA ក្នុងការលុបបំបាត់ WFCL នៅក្នុងប្រទេសកម្ពុជា CAMFEBA - PAECL នឹងកែសម្រួលទៅជាកម្មវិធីសកម្មភាពមួយចំនួនទៀត ដើម្បីកំនត់នូវកំរិតនៃការប្តេជ្ញាចិត្ត និងទំនួលខុសត្រូវក្នុងចំនោមដៃគូអនុវត្តនានា។

### ៦.២. យន្តការក្នុងការត្រួតពិនិត្យ និងការវាយតម្លៃ

ការអនុវត្តCAMFEBA-PAECL តម្រូវឱ្យមានការសហការក្នុងចំណោមភ្នាក់ងារមួយចំនួន ដែលនឹងត្រូវបានត្រួតពិនិត្យ និងវាយតម្លៃដោយ និយោជក រដ្ឋាភិបាល និងប្រទេសដែលជាដៃគូអភិវឌ្ឍន៏។ ក្របខ័ណ្ឌស្ថាប័នដែលត្រូវបានបង្ហាញក្នុងការអនុវត្តCAMFEBA-PAECL ក៏ជាក្របខ័ណ្ឌក្នុងការត្រួតពិនិត្យ និងវាយតម្លៃផងដែរ។ នៅថ្នាក់ជាតិ វចនាសម្ព័ន្ធខាងក្រោមត្រូវបានកំណត់ដូចតទៅ:

- ក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ និងអនុគណៈកម្មាធិការពលកម្មកុមាររបស់វា
- ក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ(CNCC) និង ក្រុមប្រឹក្សាគណកម្មាធិកាខេត្ត/ក្រុង(P/MCC)
- អនុគណៈកម្មាធិការជាតិពលកម្មកុមារ និងទម្រង់នៃការកេងប្រវ័ញ្ចផ្សេងៗទៀតមកលើកុមារ (NSC-CL)
- គណៈកម្មការពលកម្មកុមារខេត្ត/ក្រុង និងទម្រង់នៃការកេងប្រវ័ញ្ចផ្សេងៗទៀតមកលើកុមារ
- គណៈកម្មការជាតិស្តីពីការស្តីពីការបង្ក្រាបអំពើជួញដូរ ការរត់ពន្ធ ការធ្វើអាជីវកម្មពលកម្ម លើមនុស្ស និងការធ្វើអាជីវកម្មផ្លូវភេទ (S.T.S.L.S.)
- យន្តការសម្របសម្រួលរវាងអន្តរក្រសួង និងត្រីភាគី និង/ឬទ្វេភាគី និង អង្គការអន្តរជាតិ និង NGO
- CAMFEBA/យន្តការរបស់និយោជក/សភាពាណិជ្ជកម្មនៅថ្នាក់ជាតិ និងថ្នាក់ខេត្ត បណ្តាញសមាគមវិស័យឯកជន
- ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាស្រុក និងក្រុមប្រឹក្សាឃុំ

# ៧.ការសន្និដ្ឋាន

CAMFEBA/សមាគមនិយោជកបង្កើត CAMFEBA PAECLនេះឡើង ក្នុងគោលបំណងចូលរួមចំណែកគាំទ្រដល់គោលដៅភ្លោះរបស់រាជរដ្ឋាភិបាល ក្នុងការបញ្ចប់នូវទម្រង់ធ្ងន់ធ្ងរបំផុតនៃពលកម្មកុមារនៅឆ្នាំ ២០១៦ និងកាត់បន្ថយចំនួននៃការកើនឡើងពលកម្មកុមារក្នុងចំណោមកុមារអាយុ ៥ ដល់ ១៧ ឆ្នាំ ពី ១៦.៥% នៅឆ្នាំ ១៩៩៩ មកត្រឹម ១៣% នៅឆ្នាំ ២០០៥ និង ត្រឹម ៨% នៅឆ្នាំ ២០១៥។

PAECL របស់ CAMFEBAមិនទាន់បានបញ្ចូល "សមាសភាពយេនឌ័រ" ដើម្បីអនុវត្តនៅឡើយទេ។ ប៉ុន្តែយេនឌ័រ និងការបញ្ជ្រាបយេនឌ័រ គឺជាបញ្ហាដែលទាក់ទងទៅនឹងគ្រប់វិស័យទាំងអស់ ឬជាសមាសភាពមួយក្នុងការអនុវត្ត PAECL របស់ CAMFEBA។ ដើម្បីដោះស្រាយបញ្ហាទាក់ទងនឹងពលករដែលជាកុមារី PAECL របស់ CAMFEBA ព្យាយាមបង្កើនចំនួនកុមារីដើម្បីចូលមក និងទទួលបាននូវផលប្រយោជន៍ពីរាល់ការធ្វើអន្តរាគមន៍ដូចជាការដកហូត ការទប់ស្កាត់ ការការពារ ការស្តារនីតិសម្បទា រួមទាំងសេវាកម្មអប់រំ និងជំនាញ។

# តារាងសម្រាប់ការអនុវត្តផែនការសកម្មភាពរបស់ CAMFEBA ក្នុងការលុបបំបាត់ទម្រង់ធ្ងន់ធ្ងរបំផុតនៃពលកម្មកុមារ (CAMFEBA – PAECL) នៅក្នុងប្រទេសកម្ពុជា (២០១២-២០១៦)

| លទ្ធផល | សកម្មភាពសំខាន់ៗ | ស្ថាប័នទទួលខុសត្រូវ | តារាងពេលវេលា | លទ្ធផលរំពឹងទុក | សូចនាករ | ធនធាន និងថវិកា |
|---|---|---|---|---|---|---|
| ▪ **យុទ្ធសាស្ត្រទី១:** ជម្រុញ និងពង្រឹងសមត្ថភាពស្ថាប័នរបស់ *CAMFEBA* ក្នុងការដឹកនាំ សម្របសម្រួលសម្រាប់ការត្រួតពិនិត្យ និងរាយការណ៍អំពីបញ្ហាពលកម្មកុមារ ជាពិសេសនូវរាល់ទម្រង់ធ្ងន់ធ្ងរបំផុតរបស់វានៅក្នុងប្រទេស និងតំបន់រួមទាំងពីអ្នកបញ្ជាទិញ។ | | | | | | |
